ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ

# SCHOOL PRINCIPAL´S ACCOUNTABILITY ON TEACHING PROCESS OF HIGH SCHOOL TEACHERS IN MEMOT DISTRICT TBONG KHMUM PROVINCE


ផាន់ ម៉ៅ

PHAN MAO


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩
ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា៖ ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិត មធ្យមសិក្សា ទុតិយភូមិ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

# SCHOOL PRINCIPAL´S ACCOUNTABILITY ON TEACHING PROCESS OF HIGH SCHOOL TEACHERS IN MEMOT DISTRICT TBONG KHMUM PROVINCE

ផាន់ ម៉ៅ

PHAN MAO

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩
ឯកទេសៈ គ្រប់គ្រងអប់រំ
ឆ្នាំសិក្សាៈ ២០២០-២០២២

គ្រូណែនាំគោលៈ លោកបណ្ឌិត សោន វណ្ណ:
គ្រូណែនាំរងៈ លោកបណ្ឌិត មឿន លិនណា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទ **ផាន់ ម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៩ ឯកទេស គ្រប់គ្រងអប់រំ នៃ វិទ្យាស្ថានជាតិ អប់រំ។

សូមធ្វើការអះអាងថា ខ្លឹមសារក្នុងនិក្ខេបបទស្តីពី «**គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**» គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំពិតៗ ដោយមិនបានក្លែងបន្លំ ឬពាក់ព័ន្ធជាមួយនឹងនិក្ខេបបទអ្នកដទៃទេ ក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីទទួលបានសញ្ញាបត្រ។ ទិន្នន័យ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលបានលើកឡើងនៅក្នុងនិក្ខេបបទ គឺថ្មី ហើយមិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងនិក្ខេបបទរបស់គេឡើយ។

ខ្ញុំបាទសូមសន្យាថា និក្ខេបបទនេះមិនមានការក្លែងបន្លំ និងមិនមានការលួចចម្លងពីនិស្សិត ឬស្នាដៃអ្នកទៃ។ ក្នុងករណីដែលវិទ្យាស្ថានជាតិអប់រំពិនិត្យឃើញថា មានករណីខាងលើកើតឡើងពិតប្រាកដមែន ខ្ញុំបាទ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃចន្ទ ១២រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

សៀមរាប ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២

**ផាន់ ម៉ៅ**

# លិខិតបញ្ជាក់

**បណ្ឌិត សោន វណ្ណៈ** ៖ជាគ្រូណែនាំគោល

**បណ្ឌិតមឿន លិនណា** ៖ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ផាន់ ម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**» ពិតប្រាកដមែន។

ថ្ងៃ អាទិត្យ ១៣ កើត ខែ.កត្តិក.ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ ២០២២

................................................ ....................................................

**បណ្ឌិត សោន វណ្ណៈ**

គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិត មឿន លិនណា**

គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះលោកអ្នកមានគុណទាំងពីរគឺលោកឪពុកអ្នកម្ដាយ ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតរូបកូនមានថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងច្រើនបំផុតដល់លោកគ្រូអ្នកគ្រូជាទីគោរពស្រលាញ់ មិត្តភក្ដិទាំងអស់ ពិសេសភរិយារបស់ខ្ញុំផ្ទាល់ ដែលតែគាំទ្រ និងលើកទឹកចិត្តខ្ញុំនៅក្នុងកំឡុងពេលសិក្សានេះ។

សូមគោរពថ្លែងអំណរគុណដល់ក្រសួងអប់រំយុវជន និងកីឡា និង វិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំការប្រឡង និងផ្ដល់ឱកាសដល់រូបខ្ញុំបាទដើម្បីបានចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនេះ។ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មការគ្រប់គ្រង ការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹកបំផុត មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ ចំពោះលោកបណ្ឌិត **សោន ចន្ណា** ជាគ្រូណែនាំគោល និងលោកបណ្ឌិត **មឿន លិនណា** ជាគ្រូណែនាំរង នៃការសរសេរនិក្ខេបបទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការត្រួតពិនិត្យ វាយតម្លៃ ជួយណែនាំ និងផ្ដល់យោបល់ណែនាំដល់រូបខ្ញុំបាទក្នុងការសរសេរនិក្ខេបបទស្ដីពី «**គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**»។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ ការិយាល័យអប់រំ យុវជន និងកីឡាស្រុកមេមត់ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅតាមសាលាគោលដៅទាំងអស់ដែលបានអនុញ្ញាត និងចូលរួមសហការ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោកលោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៧០២៤ អយក.ឧទន

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្ដមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ឧទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្ដមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ឧទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្ដម | យក់ ង៉ុយ | ឧទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្ដម | លាង សេងហាក់ | ឧទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្ដម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្ដមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្ដមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្ដមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្ដមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្ដមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វី៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ រជអ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:..៣៧២៦..អយក.ខទន**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គីមឡុង | សាកលវិទ្យាភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ ប៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សូគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# មូលន័យសង្ខេប

គ្រប់ប្រទេសទាំងអស់នៅលើពិភពលោក រួមទាំងសហរដ្ឋអាមេរិកផងដែរ តែងតែធ្វើកំណែទម្រង់វិស័យអប់រំ ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ។ដោយប្រទេសទាំងអស់យល់ឃើញថា ធនធានមនុស្ស គឺជាធនធាន ដ៏សំខាន់បំផុត ក្នុងការអភិវឌ្ឍប្រទេសជាតិ ហើយវិស័យអប់រំ ក៏ជាវិស័យឧស្សាហកម្មមួយដ៏សំខាន់ផងដែរក្នុងចំណោមវិស័យនានាដើម្បីជួយដល់សេដ្ឋកិច្ចជាតិ។សព្វថ្ងៃនេះ នៅក្នុងប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានកំពុងតែធ្វើកំណែទម្រង់វិស័យអប់រំផងដែរ ដើម្បីពង្រឹងដល់គុណភាពអប់រំ។ក្នុងនេះដែរ គណនេយ្យភាពនាយកសាលា កំពុងតែបានដើរតួយ៉ាងសំខាន់ ក្នុងការជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពអប់រំ។ដោយឃើញថា គណនេយ្យភាពនាយកសាលា មានសារៈសំខាន់ ចំពោះគុណភាពអប់រំ ទើបអ្នកសិក្សាស្រាវជ្រាវបានជ្រើសរើស ប្រធានបទ «គណនេយ្យភាពនាយកសាលា លើដំណើរបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ» មកសិក្សាស្រាវជ្រាវ។ អ្នកសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានគោលបំណង ២សំខាន់ៗ៖ (១) ដើម្បីសិក្សាស្រាវជ្រាវពី គណនេយ្យភាពនយកសាលា លើដំណើរការបង្រៀនរបស់គ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។គោលបំណងទីមួយនេះ ផ្តោតលើភាពទទួលខុសត្រូវ របស់នាយកសាលា ក្នុងការដឹកនាំ ការគ្រប់គ្រង ការបំពេញនូវភារកិច្ច និងតួនាទី នៅតាមអង្គភាពនីមួយៗ។ (២)ដើម្បីសិក្សាពីបញ្ហាប្រឈម និងដំណោះស្រាយ ក្នុងការអនុវត្តគណនេយ្យភាពនាយកសាលា លើដំណើរបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូង។ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងក្នុងវិទ្យាល័យចំនួន ៥ ដែលស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំតែម្តង។អ្នកចូលរួមធ្វើសំណាក ក្នុងការសិក្សាស្រាវជ្រាវនេះ មាននាយកសាលា៥នាក់ គ្រូបង្រៀន ៥២នាក់ និងសិស្សានុសិស្ស ចំនួន ២៥០នាក់។ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ គឺបានមកពី (**កម្រងសំណួរបំពេញ និងកម្រងសំណួរសម្ភាសន៍**) សម្រាប់នាយកសាលា គ្រូបង្រៀន និងសិស្ស។ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវយកទៅវិភាគ តាមមធ្យមភាគ បណ្តុំគំនិត និងការបង្ហាញជាតារាង។

លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថាៈការអនុវត្តគណនេយ្យភាពរបស់នាយកសាលា ក្នុងការបំពេញតួនាទី និងភារកិច្ចនៅតាមអង្គភាពមានកម្រិតល្អ (មធ្យមភាគ ៣.៧៦)។ ប៉ុន្តែទន្ទឹមនឹងនេះដែរ គណៈគ្រប់គ្រងសាលា ក៏មានបញ្ហាប្រឈមមួយចំនួនផងដែរ ដែលអ្នកសិក្សាស្រាវជ្រាវទទួលបានតាមរយៈការចុះសម្ភាសន៍ផ្ទាល់។ បញ្ហាប្រឈមទាំងនោះគឺៈ(១) គ្រូបង្រៀនមួយចំនួនមិនគោរពវិន័យ ដែលបង្កឱ្យមានការលំបាកដល់ដំណើរបង្រៀន និងរៀន (២) មិនចូលរួមធ្វើការងារបរិស្ថាន (៣) ខ្វះគ្រូបង្រៀន (៤) នាយកបង្រៀនច្រើនម៉ោង (៥)គ្រូឯកទេសកមហើយ ផ្ទេរទៅវិញដោយមូលហេតុ សហព័ន្ធ (៦) ខ្វះគ្រូឯកទេស (៧) គ្រូមួយចំនួនបំពេញភារកិច្ចមិនបានល្អ (៨) សិស្សមួយចំនួនឡើងកមពីថ្នាក់ក្រោមមិនសូវចេះ។

ដើម្បីឆ្លើយតមទៅនឹងបញ្ហាប្រឈមខាងលើ ការសិក្សាស្រាវជ្រាវ សូមសំណូមពរមួយចំនួនៈ (១) ក្រសួងអប់រំ យុវជន និងកីឡា គួរតែផ្តល់គ្រូឯកទេសដល់សាលាណា ដែលមានតម្រូវការ (២) ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យ អប់រំស្រុក អាជ្ញាធរដែនដី និងអង្គភាពពាក់ព័ន្ធ ចូលរួមសហការ គាំទ្រ ដល់ការងារគ្រប់គ្រងសាលារៀន ឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព ដើម្បីឆ្លើយតបទៅនឹង គោលនយោបាយអប់រំ និងតម្រូវការមូលដ្ឋាន។

# Abstract

Every country in the world, including the United States, is constantly reforming its education sector in order to improve the quality of education. In Cambodia, the Ministry of Education, Youth and Sports is also reforming the education sector to strengthen the quality of education.

In this regard, the accountability of principals has played an important role in helping the Ministry of Education, Youth and Sports to improve the quality of education. Of teachers at the upper secondary level ».In this research study. The researchers on this topic have two main objectives: (1) To study the accountability of the principal on the teaching process at the upper secondary school level. The first objective focuses on the responsibility of the principal in leading ,school management,and the completion of all tasks and roles in each school. (2) To study the challenges and solutions in implementing the accountability of school principals on the teaching process of high school teachers in Memot district, Tbong Khmum province. The study was conducted in 5 high schools in Memot district, Tbong Khmum province. The participants in this research study were 5 school principals, 52 teachers and 250 students.Data collection methods are based on questionnaires and interview questionnaires for principals, teachers and students.

The results of this research show that the performance of the school principals in completing the roles and responsibilities in the unit is good (average 3.76). But at the same time, some school principals also have some challenges that the researchers have received through face-to-face interviews. These challenges are: (1) Some

teachers do not respect the discipline that causes difficulties in teaching and learning (2) Do not participate in environmental work (3) Lack of teachers (4) Teachers spend many hours to help teach(5) Specialized teachers come and transfer due to the federation (6) lack of specialized teachers (7) some teachers do not perform their duties well (8) some students from the lower level do not know.In order to meet the above challenges, the research study would like to make some suggestions: (1) The Ministry of Education Youth and Sports should provide specialized teachers to schools in need; (2) Ministry of Education, Youth and Sports, Department of Education Youth and Sports, District Education Office, Local Authority And relevant units to should work together to support more effective and quality school management in response to education policies and local needs.

# មាតិកា

**ខ្លឹមសារ** **ទំព័រ**


សេចក្តីអះអាងរបស់បេក្ខជន....................i
លិខិតបញ្ជាក់ .................... ii
សេចក្តីថ្លៃអំណរគុណ....................iii
លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ.................... iv
មូលន័យសង្ខេប....................viii
មាតិកា....................xii
បញ្ជីអក្សរកាត់ ....................xv
**ជំពូក១៖ សេចក្តីផ្តើម**....................1
១.១ លំនាំបញ្ហានៃការស្រាវជ្រាវ .................... 1
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ....................3
១.៣ គោលបំណងនៃការស្រាវជ្រាវ....................4
១.៤ សំណួរនៃការស្រាវជ្រាវ ....................5
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ....................5
១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ....................6
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....................6
១.៨. កាលបរិច្ឆេទនៃការស្រាវជ្រាវ....................8
**ជំពូក២៖ រំលឹកទ្រឹស្តី** ....................10
២.១ ឯកសារពាក់ព័ន្ធ គណនេយ្យភាពនាយកសាលា ....................10
២.២ គណនេយ្យភាពនាយកសាលា.................... 11
២១ ភារកិច្ចរបស់នាយកសាលា.២. ....................12

២.២២ តួនាទីរបស់នាយកសាលា. .......................................................... 16

២.៣ គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ .................................25

២១ ការបង្រៀន និង រៀន.៣. ..........................................................................25

២ ២ វប្បធម៌សាលារៀន ឬការរៀបចំរបៀបរបបដំណើរការ.៣. ...............................27

២) ៣ ការដឹកនាំ និងការគ្រប់គ្រង.៣.ស្វ័យភាព និងគណនេយ្យភាព( ..................... 31

២.៤ សារៈសំខាន់ លើគណនេយ្យភាពនាយសាលា .......................................................36

**ជំពូក៣៖ វិធីសាស្រ្តស្រាវជ្រាវ**.......................................................................38

៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ .......................................................................38

៣.២ គម្រោងនៃការស្រាវជ្រាវ ......................................................................................38

៣.៣ វិធីសាស្រ្តបែបបរិមានវិស័យ ..................................................................................38

៣.៤ វិធីសាស្រ្តបែបគុណវិស័យ......................................................................................39

៣.៥ ការប្រមូលទិន្នន័យ .............................................................................................39

៣.៦ ឧបករណ៍ស្រាវជ្រាវ .............................................................................................39

៣.៧ ការជ្រើសរើសសំណាក ......................................................................................... 41

៣.៨ ការវិភាគទិន្នន័យ .............................................................................................. 41

៣.៩ ក្រមសីលធម៌នៃការស្រាវជ្រាវ ..............................................................................42

**ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ និងវិភាគ្យា** ....................................................43

៤.១ ព័ត៌មានទូទៅនៃសំណាក .....................................................................................43

៤១ ព័ត៌មានទូទៅរបស់នាយកសាលា.១. ......................................................................44

៤២ ព័ត៌មានទូទៅរបស់គ្រូបង្រៀន.១............................................................................46

៤៣ ព័ត៌មានទូទៅរបស់សិស្ស.១.................................................................................47

៤.២ ព័ត៌មានទូទៅអំពីសាលារៀនទាំង៥ .........................................................................48

៤.៣ គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ ....... 49

៤.៤ បញ្ហាប្រឈមនានា ក្នុងការអនុវត្ត គណនេយ្យភាពនាយកសាលា លើដំណើរការ បង្រៀនរបស់គ្រូ ....... 55

៤១ បញ្ហាប្រឈមរបស់នាយក លើកដំណើរការបង្រៀនរបស់គ្រូ.៤. ....... 55

៤២ បញ្ហាប្រឈមរបស់គុ.៤.រូបង្រៀន ....... 58

៤.៥ គណនេយ្យភាពនាយកសាលា ទទួលបានពីកម្រងសំណួរសិស្ស ....... 60

**ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ....... 62

៥.១ សេចក្តីសន្និដ្ឋាន ....... 62

៥.២ សំណូមពរ ....... 64

៥.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត ....... 66

**ឯកសារយោង** ....... 67

**ឧបសម្ព័ន្ធ** ....... 69

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| % | Percent | ភាគរយ |
| A3 | Accountability Autonomy and Assessment | គណនេយ្យភាព ស្វ័យភាព និង ការវាយតម្លៃ |
| ICT | Information Communication Technology | បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន |
| M&E | Monitoring and Evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ |
| P#1 | Principal | នាយកសាលា |
| PLC | Professional Learning Communities | សហគមន៍សិក្សាវិជ្ជាជីវៈ |
| SDG4 | Sustainable Development Goal 4 | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរ |
| T#1 | Teacher | គ្រូបង្រៀន |

# ជំពូក១

# សេចក្ដីផ្ដើម

# ជំពូក១៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

គ្រប់ប្រទេសទាំងអស់នៅលើពិភពលោករួមទាំងសហរដ្ឋអាមេរិកផងដែរ បានកំពុងតែងតែធ្វើកំណែទម្រង់វិស័យអប់រំជារៀងរាល់ឆ្នាំទៅតាមកាលានុវត្តភាព និងតម្រូវការចាំបាច់របស់សិស្សនៃប្រទេសនីមួយៗរួមទាំងប្រទេសកម្ពុជា ផងដែរ។វិស័យអប់រំគឺជាវិស័យដែលសំខាន់បំផុត និងជាអាវុធដ៏មានប្រសិទ្ធភាពសម្រាប់ធ្វើការផ្លាស់ប្តូរពិភពលោកឱ្យរីកចម្រើនរុងរឿង និងមានសុខសន្តិភាព។ប្រទេសជាតិមួយមានការរីកចម្រើនទៅបាន ត្រូវពឹងផ្អែកជាចំបាច់លើវិស័យអប់រំដែលជាវិស័យអាទិភាព។ ជាក់ស្តែង គ្រប់ប្រទេសអភិវឌ្ឍន៍ទាំងអស់នៅលើពិភពលោកសុទ្ធតែពឹងផ្អែកលើវិស័យអប់រំក្នុងការប្រែក្លាយប្រទេសរបស់ខ្លួនឱ្យទៅជាប្រទេសអភិវឌ្ឍន៍។ មានន័យថាប្រទេសទាំងនោះសំបូរទៅដោធនធានមនុស្សដែលជាធនធានមិនចេះរីងស្ងួត។

ការអប់រំប្រកបដោយគុណភាព ទាមទារនូវធនធានមនុស្ស ធនធានថវិការ និងធនធានសម្ភារៈរូបវន្តសម្រាប់ឆ្លើយតបនឹងតម្រូវការជាក់ស្តែង និងបរិបទក្នុងតំបន់និងពិភពលោក។ប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍ ដូច្នេះការធ្វើកំណែទម្រង់វិស័យអប់រំ គឺជាកាតព្វកិច្ចចាំបាច់បំផុតរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹងនូវគុណភាពអប់រំឱ្យមានប្រសិទ្ធភាពកាន់តែខ្ពស់ ប្រកបដោយសមធម៌ និងបរិយាបន្ននិងផ្តល់ឱកាល ពេញមួយជីវិត សម្រាប់ទាំងអស់គ្នាក្នុងការទទួលបានការអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ហង់ ជួនណារ៉ុន** លោកបានធ្វើកំណែទម្រង់វិស័យអប់រំជារៀងរាល់ឆ្នាំ ដូចជា៖ (**យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៨-២០២៣, កំណែទម្រង់សាលារៀន នៅកម្ពុជា ឆ្នាំ២០២០**) ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា ដោយបានចាត់ទុកការអភិវឌ្ឍធនធានមនុស្ស ជាអាទិភាពទី១ ហើយក្រសួងអប់រំយុវជន និងកីឡានឹងប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១គឺ៖១)**ពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហាររូបបត្ថម្ភ និងទី៤) ការពង្រឹងសមភាពយេនឌ័រ**។ដើម្បី

ចូលរួមជាមួយរាជរដ្ឋាភិបាល កម្ពុជា សម្រេចឱ្យបាននូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤នេះ ក្នុងគោលបំណង ប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ទៅជាប្រទេសដែលមានចំណូលកម្រិតខ្ពស់នាឆ្នាំ២០៥០។ម្យ៉ាងទៀតរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខណ្ឌគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព ឆ្នាំ២០១៦-២០៣០ ស្របតាមបរិបទសាកលលោក។ ជាមួយគ្នានេះផងដែរ ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តឯកសារផ្លូវការស្តីពីៈ «**ផែនទីបង្ហាញផ្លូវរបស់ក្រសួងអប់រំនៅកម្ពុជាឆ្នាំ២០៣០(SDG4)**» ដើម្បីឆ្លើយតបទៅនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់រាជរដ្ឋាភិបាលកម្ពុជា លើអាទិភាពសំខាន់ៗចំនួន៥ ដែលផ្តោតលើការព្រឹងគុណភាពអប់រំផងដែរ។ដោយសារតែបរិបទជំងឺកូវីត១៩ **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ហង់ ជួនណារ៉ុន** បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់វិស័យអប់រំថ្មីៗដូចជាៈ (**បរិវត្តកម្មឌីជីថលនៃការអប់រំ បំណិនសតវត្សទី២១ និងកំណែទម្រង់វិធីសាស្រ្តបង្រៀន**)ជាដើម ដើម្បីពង្រឹងគុណភាពអប់រំឱ្យកាន់តែប្រសើរឡើងថែមទៀត ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ដូចនេះដើម្បីសម្រេចបាននូវការអប់រំមួយប្រកបដោយគុណភាពពិតប្រាកដ លុះត្រាតែមានការចូលរួមពីគ្រប់ភាគីដែលពាល់ព័ន្ធដូចជា ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំក្រុង/ខេត្ត ការិយាល័យ ខ័ណ្ឌ/ស្រុក អាជ្ញាធរ និងសហគមន៍ ក្នុងការជួយដល់ដំណើរការបង្រៀន និងរៀននៅតាមអង្គភាពនានា ឱ្យមានប្រសិទ្ធភាពខ្ពស់ និងទិន្នផលល្អ។លើសពីនេះទៀត «**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ហង់ ជួនណារ៉ុន**» បានលើកឡើង ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ការអនុវត្តគម្រោងគាំទ្រផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ថាៈ(**គណនេយ្យភាពសាលារៀន ចំពោះសង្គម គឺពង្រឹងគុណភាពអប់រំនៅកម្ពុជា**) មានន័យថាៈដើម្បីសម្រេចបាននូវគោលនយោបាយកំណែទម្រង់វិស័យអប់រំនិងការអប់រំមួយប្រកបដោយគុណភាព និង ប្រសិទ្ធភាព លុះត្រាតែ នាយកសាលានីមួយៗ មាន «**គណនេយ្យភាព តម្លាភាព និងស្វ័យភាព**» នៅក្នុងដំណើរការដឹកនាំគ្រប់គ្រងរបស់ខ្លួន ហើយថ្នាក់ដឹកនាំនាយកសាលារូបនោះគឺជាបុគ្គលដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ មានសមត្ថភាពខ្ពស់ មានឆន្ទៈ មានភាពច្នៃប្រឌិតរស់រវើក មានការប្រាស្រ័យទាក់ទងល្អ ក្នុងការដឹកនាំគ្រប់គ្រងសាលារៀន និងការអភិវឌ្ឍន៍ធនធាន

មនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹង បរិបទនៃការអប់រំ ក្នុងប្រទេស តំបន់ និងពិភពលោក។ពីមួយឆ្នាំទៅមួយឆ្នាំ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងអប់រំ យុវជន និង កីឡា បានយកចិត្តទុកដាក់យ៉ាងខ្លាំង លើការបណ្តុះបណ្តាលលើគុណវុឌ្ឍិគ្រូបង្រៀន តាមរយៈការប្រឡងជ្រើសរើសក្របខ័ណ្ឌ គ្រូបង្រៀន គ្រប់កម្រិត ដើម្បីបំពេញតម្រូវការ របស់សិស្ស ទៅតាមតំបន់។ ការប្រឡងជ្រើសរើស ក្របខ័ណ្ឌបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកសាលា ហើយបានបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ(NIE)។ ការរៀបចំសិក្ខាសាលាផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡា រាជធានី ក្រុង ខេត្ត ស្រុក ជារៀងរាល់ឆ្នាំ ក្នុងគោលបំណងពង្រឹងគុណភាពអប់រំ។ដោយយល់ឃើញថា នាយកសាលា បានដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងនូវគុណភាពអប់រំ នាយកសាលាជាបេះដូងសាលារៀន ។ទើបអ្នកសិក្សាស្រាវជាវជ្រើសរើសប្រធានបទមួយកមសិក្សាស្រាវជ្រាវគឺ៖ «**គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**»។

សរុបសេចក្តីមក គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ គឺពិតជាបានកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ការកែលម្អសាលារៀន ការអភិវឌ្ឍសាលារៀន ពង្រឹងដល់គុណភាពអប់រំ និងជាពិសេសជួយដល់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបាននូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា គឺថាសម្រេចនូវចក្ខុវិស័យដើម្បីប្រែក្លាយសេដ្ឋកិច្ចកម្ពុជាឱ្យបានពីចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០ និងរួមចំណែកជួយដល់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។តើហេតុអ្វីបានជា«គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ »មានសារៈសំខាន់ក្នុងការពង្រឹងដល់គុណភាពអប់រំ?ហើយតើអ្វីទៅជាគណនេយ្យភាពរបស់នាយកសាលា?តើគណនេយ្យភាពនាយកសលាផ្តោតលើអ្វីខ្លះ?

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

សាលារៀនគឺជាថ្នាលបណ្តុះបណ្តានូវធនធានមនុស្ស និងបង្រៀនមនុស្សឱ្យក្លាយទៅពលរដ្ឋពេញលេញ។ទន្ទឹមនិងនេះដែរ គណនេយ្យភាពនាយកសាលា លើដំណើការបង្រៀនរបស់គ្រូ គឺជាពិតជាមានសារៈសំខាន់បំផុត ចំពោះការពង្រឹងគុណភាពអប់រំឱ្យមានប្រសិទ្ធភាពនៅតាមសាលារៀន ក៏ដូចជាជួយ

ដល់ក្រសួង អប់រំយុវជន និងកីឡា ក្នុងការលើកកម្ពស់វិស័យអប់រំនៅកម្ពុជា។ដើម្បីឱ្យដំណើរការបង្រៀន និងរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ លុះត្រាតែនាយកសាលានីមួយៗ មានសមត្ថភាពខ្ពស់ ហើយស្របតាមលក្ខណ្ឌដូចជា៖១)មានកម្រិតវប្បធម៌យ៉ាងទាបបំផុតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ២)មានវិញ្ញាបត្រ វិជ្ជាជីវៈនាយកសាលារៀន ៣) មានសមត្ថភាពផ្នែក ICT ៤)ចេះភាសាបរទេស និង៥)មានបទពោសោធន៍ យ៉ាងតិច៥ឆ្នាំក្នុងការបង្រៀន។ លើសពីនេះទៀតនាយកសាលា គួរតែត្រូវបានជ្រើសរើសចេញពី ស្តង់ដារនាយកសាលាល្អ (ស្តង់ដារទាំង៦)ហើយត្រូវតែមានសមត្ថភាពខ្ពស់ និងគុណសម្បត្តិល្អ ដើម្បីបង្ហាញពីប្រសិទ្ធភាពក្នុងការគ្រប់គ្រងរបស់ខ្លួន។នាយកសាលា ដែលទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការដឹកនាំ គ្រប់គ្រង ត្រូវតែដឹកនាំធ្វើជាគំរូល្អដូចខាងក្រោម៖១)បង្ហាញសកម្មភាពល្អៗប្រចាំថ្ងៃ ២)ហ៊ានបង្ហាញពីតម្លាភាព និងគណនេយ្យភាព ៣)អ្វីៗដែលបានធ្វើត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ៤)មានមោទកភាពលើវិជ្ជាជីវៈរបស់ខ្លួន និងមានការប្តេជ្ញាខ្ពស់ក្នុងការកសាងនូវឆន្ទៈនិងជំនឿទុកចិត្តដល់អង្គភាព ហ៊ាននិយាយ ហ៊ានធ្វើ និងហ៊ានទទួលខុសត្រូវ និងដឹកនាំគ្រប់គ្រងប្រកបដោយស្វ័យភាព តម្លាភាព និងគណនេយ្យភាព។បើនាយកសាលាមានគណនេយ្យភាពច្បាស់លាស់ក្នុងការគ្រប់គ្រង និងដឹកនាំហើយ សាលារៀននោះនឹងទទួលបានការអប់រំមួយប្រកបដោយគុណភាព និងប្រសិទ្ធភាព។ដូចនេះគណនេយ្យភាពនាយកសាលា លើដំណើការបង្រៀនរបស់គ្រូ គឺពិតជាបានដើរតួយ៉ាងសំខាន់ក្នុងការ លើកកម្ពស់ដល់គុណភាពអប់រំយ៉ាងពិតប្រាកដ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវមានគោលបំណងធំសំខាន់ៗចំនួន២គឺ៖

១) ដើម្បីសិក្សាស្រាវជ្រាវពីគណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

២) ដើម្បីសិក្សាពីបញ្ហាប្រឈម និងដំណោះស្រាយពីការអនុវត្ត គណនេយ្យភាពរបស់នាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

## ១.៤ សំណួរនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនិងគោលបំណងនៃប្រធានបទខាងលើ ការសិក្សាស្រាវជ្រាវនេះ មានសំណួរស្រាវជ្រាវចំនួន២ គឺៈ

១) តើហេតុអ្វីបានជាគណនេយ្យភាពនាយកសាលា មានសារៈសំខាន់ លើដំណើរការបង្រៀនរបស់គ្រូ ក្នុងការពង្រឹងនូវគុណភាពអប់រំ?

២) តើនាយកសាលាមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តគណនេយ្យភាពរបស់ខ្លួន លើដំណើរបង្រៀនរបស់គ្រូ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ដូចជាៈ

- ដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅ នូវការអនុវត្តគណនេយ្យភាពរបស់ នាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ (*ការបំពេញតួនាទី ភារកិច្ច ការដឹកនាំ និងការគ្រប់គ្រងប្រកបដោយឆន្ទៈ និងទំនួលខុសត្រូវខ្ពស់*) ដើម្បីឱ្យអង្គភាពរបស់ខ្លួនមានដំណើរការល្អក្នុងការបង្រៀន និងរៀន។
- ដើម្បីចូលរួមចំណែក ក្នុងការលើកកម្ពស់ដល់គុណភាពអប់រំ និងដកស្រង់បទពិសោធន៍ល្អៗតាមរយៈ ការប្រែក្លាយពីបញ្ហាប្រឈមនានាទៅជាកាលានុវត្តភាព ក្នុងការគ្រប់គ្រង លើដំណើការបង្រៀនរបស់គ្រូ ប្រកបដោយប្រសិទ្ធភាព។
- ដើម្បីជួយដោះស្រាយនូវបញ្ហាប្រឈមនានា ក្នុងដំណើរការដឹកនាំ និងគ្រប់គ្រង លើដំណើរការបង្រៀនរបស់គ្រូ និងលើកកម្ពស់ដល់លទ្ធផលនៃការសិក្សារបស់សិស្ស និងជួយទាក់ទាញសហគមន៍ឱ្យចូលរួមចំណែកក្នុងការអភិវឌ្ឍសាលារៀន និងការកែលម្អសាលារៀន។ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវនេះ ដើម្បីទុកជាធនធានឯកសារ សម្រាប់ជំនួយដល់អ្នកសិក្សាក្រោយៗ ក្នុងការសិក្សាស្រាវជ្រាវបន្តទៀត ជាពិសេសគឺទាក់ទង់ទៅនិងគណនេយ្យភាពនាយកសាលា។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ខេត្តត្បូងឃ្មុំគឺជាខេត្តកូនពៅគេ ហើយជាខេត្តថ្មី ដែលមានស្រុកចំនួន៦ និងក្រុង១ និងវិទ្យាល័យចំនួន២៧ទូទាំងខេត្ត ដែលធ្វើឱ្យខ្ញុំជាអ្នកសិក្សាស្រាវជ្រាវត្រូវជួបនូវបញ្ហាប្រឈមនានាក្នុងការសិក្សាស្រាវជ្រាវ ដូចជាមិនមានពេលវេលាគ្រប់គ្រាន់ ខ្វះធនធានថវិកា ក្នុងការចុះប្រមូលទិន្នន័យ ឱ្យបានគ្រប់វិទ្យាល័យទូទាំងខេត្តទេ។ទើបការសិក្សាស្រាវជ្រាវនេះ គឺនឹងធ្វើឡើង តែនៅក្នុងវិទ្យាល័យ ចំនួន៥ ដែលស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំប៉ុណ្ណោះ។វិទ្យាល័យទាំង៥នោះគឺ៖ *១) វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនដារ ២)វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន មេមត់ ៣)វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន កុលផ្សារ ៤) វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្រែតានងកើត និង៥) វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនលាចលើ)*។ការសិក្សាស្រាវជ្រាវនេះគឺផ្តោតលើគណនេយ្យភាពរបស់នាយកសាលា*( ភាពទទួលខុសត្រូវ ក្នុងការបំពេញតួនាទី ភារកិច្ច និងការដឹកនាំគ្រប់គ្រងរបស់នាយកសាលា )* លើដំណើរការបង្រៀនរបស់គ្រូ តាមរយៈការធ្វើ (ការវង្វាយតម្លៃលើលទ្ធផលសិក្សារបស់សិស្ស) ។ដូចនេះចំនួនដែលត្រូវជ្រើសរើសយកមកធ្វើសំណាកគឺ៖នាយកសាលាវិទ្យាល័យចំនួន៥ នាក់ គ្រូបង្រៀននៅកម្រិតវិទ្យាល័យចំនួន៥២នាក់ សិស្សនៃសាលាវិទ្យាល័យទាំង៥មានចំនួន២៥០នាក់។សរុបចំនួនសំណាក ៣០៧នាក់។ចំនួននេះ បើទោះបីជាទំហំចំនួននៃការសិក្សាស្រាវជ្រាវតិចតួច ហើយធ្វើឡើងតែក្នុងស្រុកមេមត់ តែមួយក៏ដោយ វាគ្រាន់តែជាការសន្មត់ប៉ុណ្ណោះ។ដូចនេះអ្នកស្រាវជ្រាវ ក្រោយៗទៀតអាចធ្វើការស្រាវជ្រាវដោយកំណត់យកទំហំសំណាកឱ្យធំជាងនេះ ឬអាចធ្វើទូទាំងខេត្តតែម្តង។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដំណើរការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា៥ជំពូកធំៗគឺ៖

### ជំពូក១៖ សេចក្តីផ្តើម

បង្ហាញពីសារតានៃការសិក្សាស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាពនិងដែនកំណត់ និងរចនាសម្ព័ន្ធនៃ

ការស្រាវជ្រាវ លើប្រធានបទ (**គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**)។

**ជំពូក២៖ រំលឹកទ្រឹស្តី**

ការស្រាវជ្រាវនេះ នឹងលើកយកទ្រឹស្តីរបស់អ្នកស្រាវជ្រាវមុនៗ កម្រងអត្ថបទស្រាវជ្រាវជាតិ និងអន្តរជាតិ លិខិតបទដ្ឋានគតិយុត្ត ប្រកាស សារាចរណ៍ណែនាំ និងឯកសារនានា របស់ក្រសួង និងស្ថាប័ននានា ដែលពាក់ព័ន្ធនឹងប្រធានបទនេះ ត្រូវបានលើកឡើង ដើម្បីធ្វើជាគំនិតឆ្លុះបញ្ចាំងទៅនឹងការរកឃើញថ្មីៗក្នុងស្នាដៃនៃការសិក្សាស្រាវជ្រាវនេះ។

**ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ**

អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីឧបករណ៍ស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្រាវជ្រាវក្នុងការប្រមូលទិន្នន័យ និងគម្រោងស្រាវជ្រាវដែលបញ្ជាក់ពីអត្ថប្រយោជន៍នៃប្រធានបទ និងបង្ហាញពីទំនាក់ទំនងពីចំណុចនីមួយៗដែលបានចោទនៅក្នុងចំណោទបញ្ហាទៅជាមួយនឹងប្រធានបទ។

**ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវ និងការវិភាគ**

អ្នកស្រាវជ្រាវលើកពីលក្ខណៈជាក់ស្តែងដែលបានធ្វើការស្រាវជ្រាវនិងវិភាគទៅលើចំណុចទាំងអស់ដែលបានអនុវត្តជាក់ស្តែងដើម្បីរកឱ្យឃើញថា តើវាដូចគ្នាទៅនឹងទ្រឹស្តីឬទេ គឺក្នុងគោលបំណងវិភាគរកឱ្យឃើញចំណុចខ្វះខាតដើម្បីកែលម្អបន្ថែមទៀត។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

អ្នកស្រាវជ្រាវធ្វើការសន្និដ្ឋានលើគ្រប់ចំណុចទាំងអស់ដែលបានវិភាគ និងផ្តល់យោបល់ទៅលើចំណុចដែលត្រូវកែលម្អនិងចំណុចខ្វះខាតនានា និងលើកឡើងនូវសំណូមពរមួយចំនួនដល់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក ។

សរុបសេចក្តីមក ការសិក្សាស្រាវជ្រាវលើប្រធានបទ៖ (**គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**)នេះ គឺផ្តោតលើ ភាពទទួលខុសត្រូវរបស់លោកនាយកសាលាក្នុងការបំពេញនូវតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការដឹកនាំគ្រប់គ្រង

ដំណើរការបង្រៀនរបស់លោកគ្រូ នៅក្នុងអង្គភាពនីមួយៗ ពិសេសគឺផ្តោតលើ *(ការធ្វើវាយតម្លៃលើលទ្ធផលសិក្សារបស់សិស្ស)* ។គណកម្មការគ្រប់គ្រងសាលា/គណកម្មការទ្រទ្រង់សាលា និងការចូលរួមពីសហគមន៍ ដើម្បីកែលម្អសាលារៀន និងចូលរួមចំណែកក្នុងការពង្រឹងនូវគុណភាពអប់រំ។គុណភាពអប់រំ នាំមកនូវការអភិវឌ្ឍន៍ឥតឈប់ឈរ។គុណភាពអប់រំ បង្កើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។

## ១.៨. កាលបរិច្ឆេទនៃការស្រាវជ្រាវ

| ល.រ | **ខ្លឹមសារ** | **កាលបរិច្ឆេទធ្វើបទបង្ហាញ** |
|---|---|---|
| ១ | គម្រោងការពារប្រធានបទស្រាវជ្រាវ | ២៧មករា២០២២ |
| ២ | គម្រោងស្រាវជ្រាវ | ខែមេសា |
| ៣ | បង្កើតឧបករណ៍ស្រាវជ្រាវ | |
| ៤ | ប្រមូលទិន្នន័យ | ឧសភានិងមិថុនា |
| ៥ | សេចក្តីផ្តើម | កក្កដាដល់កញ្ញា |
| ៦ | រំឭកទ្រឹស្តី | កក្កដាដល់កញ្ញា |
| ៧ | វិធីសាស្ត្រស្រាវជ្រាវ | កក្កដាដល់កញ្ញា |
| ៨ | លទ្ធផលស្រាវនិងការពិភាក្សា | កក្កដាដល់កញ្ញា |
| ៩ | ការពារនិក្ខេបបទសាកល្បង | ០៣ តុលា២០២២ |
| ១០ | ការពារនិក្ខេបបទបញ្ចប់ការសិក្សា | ៥ ដល់៦ វិច្ឆិកា ២០២២ |
| ១១ | ប្រគល់និក្ខេបបទបញ្ចប់ការសិក្សា | |

<u>ដ្យាក្រាម</u>៖ *គណនេយ្យភាពរបស់នាយកសាល*



# ជំពូក២

# រំឭកទ្រឹស្តី

# ជំពូក២៖ រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ ជាការសំយោគទ្រឹស្តី និងឯកសារពាក់ព័ន្ធមួយ ដើម្បីបានទ្រឹស្តីសម្រាប់ធ្វើការពិភាក្សានៅក្នុងជំពូកទី ៤។ ដោយអ្នកស្រាវជ្រាវបានចែកជា ៥ ចំណុចដូចខាងក្រោម៖

**១) ឯកសារពាក់ព័ន្ធ គណនេយ្យភាពនាយកសលា**

**២) គណនេយ្យភាពនាយកសាលា**

**៣) គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ**

**៤) សារៈសំខាន់ លើគណនេយ្យភាពនាយកសាលា**

**៥) សរុប**

## ២.១ ឯកសារពាក់ព័ន្ធ គណនេយ្យភាពនាយកសាលា

មុននឹងធ្វើការបកស្រាយជំពូកនេះ ឱ្យបានស៊ីជម្រៅ និងក្បោះក្បាយ គប្បីកំណត់ពាក្យគន្លឹះ និងពន្យល់ពាក្យគន្លឹះជាមុនសិន។តើពាក្យ «**គណនេយ្យភាព**» មានន័យដូចម្តេច? តើ «ជាគណនេយ្យភាពនាយកសាលាផ្តោតសំខាន់លើអ្វីខ្លះ?» តើ «គណនេយ្យភាពនាយកសាលាសាលា លើដំណើរការបង្រៀន» សំដៅលើអ្វី?។ ពាក្យ «គណនេយ្យភាព» ក្នុងទីនេះសំដៅលើ **«ការទទួលស្គាល់ និងការទទួលខុសត្រូវចំពោះសកម្មភាព និងការសម្រេចចិត្ត និងគោលនយោបាយដែលបានអនុវត្តនៅក្នុងតួនាទី ភារកិច្ច និងដែនសមត្ថកិច្ចរបស់ខ្លួន »**។ ដូច្នេះ «**គណនេយ្យភាពនាយក លើដំណើរការបង្រៀនរបស់គ្រូ**» គឺសំដៅលើ ភាពទទួលខុសត្រូវ របស់នាយកសាលា ក្នុងការអនុវត្តការងារដឹកនាំ និង គ្រប់គ្រង និងការបំពេញនូវ តួនាទី ភារកិច្ចរបស់ខ្លួន ទៅតាមអង្គភាពផ្សេងៗឱ្យមានប្រសិទ្ធភាព ហើយសម្រេចបានទៅតាមផែនការ។នាយកសាលាគឺជាដំណាងឱ្យជាតុផ្សំដ៏សំខាន់ បំផុតនៃប្រព័ន្ធអប់រំ ដើម្បីជំរុញការកែលម្អសាលារៀន និងប្រសិទ្ធភាពសាលារៀន។គណនេយ្យភាពនាយកសាលាគឺឆ្លុះបញ្ចាំងពីតួនាទី ភារកិច្ចរបស់នាយក ដែលបានរួមចំណែកក្នុងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាពលើដំណើរការបង្រៀ (DayGu, &Sammons, 2016; Gumus, Bellibas, Esen, $Gumus, 2016; Moos, Johansson, & Day, 2016) ។ នាយកសាលា គឺជាអ្នកដឹកនាំចម្បងដែលមានឥទ្ធិពល លើការកែលម្អសាលារៀនក្នុងបរិបទជាក់លាក់ដែលកំណត់ដោយការផ្លាស់ប្តូរក្នុង

ប្រព័ន្ធគណនេយ្យភាពរបស់សាលា (គណៈកម្មការអឺរ៉ុប/EACD/Eurydice,2015;OECD,2013) ភាពទទួលខុសត្រូវ របស់នាយកសាលា ក្នុងការអនុវត្តផែនការ អភិវឌ្ឍសាលារៀន។នៅក្នុងសាលា កំណែទម្រង់សាលារៀននៅកម្ពុជា ឆ្នាំ២០២០ គឺត្រង់ចំណុច២ ប្រសិទ្ធភាព គណនេយ្យភាព និងការកែលម្អសាលារៀន ផ្តោតលើ ការធ្វើផែនការអភិវឌ្ឍសាលារៀន និងការកែលម្អសាលារៀន (បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន)។ គណនេយ្យភាពសាលារៀន ពង្រឹងគុណភាពអប់រំនៅកម្ពុជា (បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន)។គណនេយ្យភាពសាលារៀន ជាផ្នែកសំខាន់**នៃប្រព័ន្ធគ្រប់គ្រង ៣A បិទជិត** (គណនេយ្យភាព ស្វ័យភាព និងការវាយតម្លៃ) ដែលផ្តោតលើ គណនេយ្យភាពលើដំណើរសាលារៀន គណនេយ្យភាពសិក្សា និងគណនេយ្យភាពហិរញ្ញវត្ថុ(*សៀវភៅ កំណែទម្រង់សាលារៀន នៅកម្ពុជា ឆ្នាំ២០២០,ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួនណារ៉ុន)*។ ការអប់រំ និងគោលនយោបាយអប់រំ បាននិយាយថាៈ គនេយ្យភាព គឺសំដៅលើការកែលម្អសាលា និងការធ្វើកំណែទម្រង់សាលារៀន សូម្បីតែបរទេសមួយចំនួន ក៏ធ្វើកំណែទម្រង់អប់រំ រួមទាំងសហរដ្ឋអាមេរិកផងដែរ ដើម្បីបង្ហាញពីកម្រិតនៃការអប់រំ បង្កើតនូវជម្រើសសាលារៀន និងទាមទារឱ្យមានទម្រង់នៃការរៀបចំ គ្រូឱ្យបានត្រឹមត្រូវ និងតឹករឹងបន្ថែមទៀត ដោយសារគ្រូ និងសាលារៀន សមស្រប ឆ្លើយតបទៅនឹងសង្គម (Chheang Sangvath, Ed.D, Oct 02,2021)។

## ២.២ គណនេយ្យភាពនាយកសាលា

ការអភិវឌ្ឍសាលារៀន គឺជាកត្តាគន្លឹះក្នុងយុទ្ធសាស្ត្រនៃកំណែទម្រង់វិស័យអប់រំ។ពាក្យថា «ការអភិវឌ្ឍសាលារៀន» បានបង្កប់នៅបេសកកម្មជាច្រើនដែលគ្រប់អ្នកពាក់ព័ន្ធ ត្រូវតែប្តេជ្ញាចិត្ត និងចូលរួមទាំងអស់គ្នា ក្នុងការគិត និងធ្វើ។កត្តាចម្បងនៃការអភិវឌ្ឍសាលាគឺ **«ការគ្រប់គ្រងសាលារៀន»** ដែលជាកាតព្វកិច្ចដ៏សំខាន់របស់នាយកសាលាគ្រប់ៗរូប។ តាមបទពិសោធនៃការគ្រប់គ្រងសាលារៀនកន្លងមក យើងរកឃើញថាមានយន្តការ «ស៤» ដែលត្រូវតែមានដំណើរការស៊ីចង្វាក់គ្នា។ «ស» បួននោះគឺ សាលារៀន សហគមន៍ សាសនា និងសប្បុរសជន។ចំពោះសាលារៀន ភារកិច្ចចម្បងបំផុតរបស់នាយកសាលាគឺ «ការគ្រប់គ្រងសាលារៀន»។ដើម្បីឈានទៅដល់ភាពជោគជ័យនៃការគ្រប់គ្រង នាយកសាលា ត្រូវប្រកាន់ខ្ជាប់នៅសិល្ប៍៤គឺៈ**១. តម្លាភាព ២. គណនេយ្យភាព ៣. កិត្តិយស និង៤. ភាពជាតំណាង**។ ភាពទទួល

ខុសត្រូវរបស់នាយកសាលា បានដើរតួយ៉ាងសំខាន់ ក្នុងការពង្រឹងដល់គុណភាពអប់រំ នៅតាមគ្រឹស្ថានសិក្សាសាធារណៈ។ សាលារៀន មានការរីកចម្រើនទៅបាន អាស្រ័យលើ នាយកជាអ្នកដឹកនាំល្អ។ គណនេយ្យភាពរបស់នាយកសាលាក្នុងទីនេះ គឺសំដៅលើ ភាពទទួលខុសត្រូវ លភារកិច្ច និងតួនាទីរបស់នាយកសាលា ក្នុងការដឹកនាំ និងគ្រប់គ្រង។នាយកសាលាមានភារកិច្ចសំខាន់ៗ ក្នុងការដឹកនាំ និងគ្រប់គ្រងដូចខាងក្រោម៖

## ២.២.១ ភារកិច្ចរបស់នាយកសាលា

នាយកសាលា គឺបុគ្គលដែលមានភារកិច្ចក្តាប់រួមរាល់ការងារទាំងអស់នៅក្នុងសាលារៀនរបស់ខ្លួន នាយកត្រូវតែឈ្លាស់វៃក្នុងការដោះស្រាយនូវរាល់បញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងអង្គភាពរបស់ខ្លួន។នាយកត្រូវមានភារកិច្ចសំខាន់ៗចំនួន៣គឺ៖

**ក. ការងាររដ្ឋបាល**

**ខ. ការងារបច្ចេកទេសគរុកោសល្យ**

**គ. ការងារទំនាក់ទំនង**

### ក. ការងាររដ្ឋបាល

ដើម្បីធានានូវការងាររដ្ឋបាលឱ្យបានល្អ នាយកត្រូវតែអនុវត្តកិច្ចការមួយចំនួនដូចខាងក្រោម៖

- កសាងចក្ខុវិស័យ បេសកកម្ម និងផែនការសកម្មភាពដើម្បីអភិវឌ្ឍអង្គភាពរបស់ខ្លួន
- កសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង ការវិភាគមុខងារ
- រៀបចំផ្សព្វផ្សាយ និងបំផុសឱ្យអាណាព្យាបាលនាំកូនមកចូលរៀន
- ដឹកនាំការប្រជុំការងាររបស់សាលារៀន និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិ
- រៀបចំការលិខិតស្នាម និងរក្សាទុកឱ្យមានសណ្តាប់ធ្នាប់
- បែងចែកភារកិច្ចជូនបុគ្គលិកឱ្យអនុវត្តការងារទៅតាមតួនាទី និងភារកិច្ច
- ធានានិយ័តភាពក្នុងការសិក្សា
- ធានាឱ្យសាលារៀនបំពេញបាននូវការផ្តល់សេវាសាធារណៈ

- បែងចែកកម្មវិធីការងារប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដោយមានវិធានការតាមដានត្រួតពិនិត្យវាយតម្លៃការងារយ៉ាងល្អិតល្អន់
- រៀបចំតារាងស្ថិតិ ផែនទីសិក្សា (មធ្យមសិក្សា)
- ពិនិត្យសម្រេច លើការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងអង្គភាព និងចុះហត្ថលេខា លើលិខិតបទដ្ឋានផ្សេងៗរបស់អង្គភាព
- រៀបចំក្រុមប្រឹក្សា និងគណកម្មការនានារបស់អង្គភាព
- ចេញលិខិតបញ្ជាក់ការសិក្សា និងប័ណ្ណសម្គាល់ខ្លួនឱ្យសិស្ស
- រៀបចំទីចាត់ការ រក្សាសណ្តាប់ធ្នាប់ និងវិន័យក្នុងសាលារៀន
- រៀបចំចាត់ចែង ការបណ្តុះបណ្តាល នៅនឹងកន្លែង ឬការបំប៉នកន្លែងផ្សេងៗ
- ពិនិតនិងសម្រេចលើការរៀបចំបទបញ្ជាផ្ទៃក្នុង របស់សាលារៀន
- ពិនិត និងសម្រេច ជ្រើសរើសសិស្សទទួលបានអាហារូបករណ៍
- ពិនិត និងសម្រេច លើការផ្ទេរចេញ និងចូលរបស់សិស្ស
- ធ្វើការវាយតម្លៃ បុគ្គលិក និងដំឡើងថ្នាក់ប្រចាំឆ្នាំ
- ណែនាំដាស់តឿន ដល់បុគ្គលិកដែលអសកម្មការងារ
- បូកសរុបរបាយការណ៍ការងារ និងលទ្ធផលសិក្សារបស់សិស្សប្រចាំឆ្នាំជូនទៅអង្គភាពពាក់ព័ន្ធ
- ចូលរួមប្រជុំការងារជាមួយការិយាល័យ អប់រំ យុវជន និងកីឡា ក្រុង ស្រុក ខ័ណ្ឌ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់
- រៀបចំបញ្ជីសារពើភ័ណ្ឌ នូវចលនវត្ថុ និងអចលនវត្ថុទាំងឡាយ
- ទទួលខុសត្រូវលើការគ្រប់គ្រង និងប្រើប្រាស់ថវិកា(ចំណូល ចំណាយ)
- សហការជាមួយគណៈកម្មការទ្រទ្រង់សាលារៀនដើម្បីស្វែងរកថវិកា(ចំណូល និងប្រើប្រាស់)

- អនុវត្តឱ្យបានត្រឹមត្រូវ តាមកិច្ចបញ្ជីកាគណនេយ្យ ចំពោះថវិការសាលារៀន
- រៀបចំបរិស្ថានឱ្យមានអនាម័យ និងសោភ័ណភាពក្នុងសាលារៀន (ទីធ្លាថ្នាក់រៀន តូបលក់នំចំណី ដើមឈើធ្វើម្លប់ សួបច្បារ សួនជីវចម្រុះ....)
- ធ្វើជាអាជ្ញាកណ្តាលផ្សះផ្សាទំនាស់ផ្សេងៗដែលកើតមានឡើងនៅក្នុងសាលារៀន
- បំពេញភារកិច្ចចាំបាច់តាមការចាត់តាំងរបស់ថ្នាក់លើ។

**ក្នុងការងាររដ្ឋបាលនេះ លោកនាយកត្រូវចងចាំថា៖**

ក. រចនាសម្ព័ន្ធដែលរៀបចំមិនបានល្អ បង្កហេតុទាំងឡាយនៃទំនាស់

ខ. ទោះបីជាមានហេតុផលយ៉ាងណាក៏ដោយ រាល់ការសម្រេចចិត្តត្រូវផ្អែកលើសារាចរណ៍ណែនាំ។ប្រការនេះទាមទារឱ្យនាយកសាលាយល់ដឹងអំពីខ្លឹមសារសារាចរណែនាំនានាឱ្យបានច្បាស់លាស់។

គ. នាយកត្រូវតែទទួលស្គាល់ការពិតថាអំណាចដែលប្រើកម្លាំងនោះត្រូវបានគេស្អប់ខ្ពើមណាស់។ អំណាចក្នុងន័យប្រជាធិបតេយ្យធ្វើសកម្មភាពទាំងឡាយដោយគោរពភាពយុត្តិធម៌ និងបុគ្គលិកលក្ខណៈ

ឃ. ការអភិវឌ្ឍនៃសាលារៀននីមួយៗ បានមកពីការប្រមូលបទពិសោធល្អៗ និងគំនិតផ្តួចផ្តើមថ្មី

ង. គណនេយ្យភាព បង្កើតមិត្តភាព និងប្រសិទ្ធភាពការងារ។

## ខ. ការងារបច្ចេកទេសគរុកោសល្យ

ការគ្រប់គ្រង ការងារបង្រៀន និងរៀន គឺជាភារកិច្ចស្នូលចម្បងរបស់នាយកសាលា។ នាយកសាលាមិនត្រូវឃុំឃាំងខ្លួនឯងតែក្នុងទីចាត់ការដោយមិនព្រមទៅមើល ការបង្រៀន និងរៀឱ្យបានញឹកញាប់នោះទេ។ នាយកសាលាដ៏ល្អ គឺជាគ្រូបង្រៀនល្អផង និងជាទីបឹក្សាគរុកោសល្យល្អផង។នាយកសាលាត្រូវតែមានភាពច្បាស់លាស់ក្នុងការគ្រប់គ្រងរាល់សកម្មភាពបង្រៀនរបស់គ្រូ និងសកម្មភាពរៀនរបស់សិស្ស ដោយអនុវត្តតាមគោលការដូខាងក្រោម៖

- ពិនិត្យតាមដានការចូលរៀនរបស់សិស្ស ការបង្រៀន របស់គ្រូ និងការបើកបិទថ្នាក់រៀនឱ្យបានខ្ជាប់ខ្ជួន ជាទីបំផុត
- ពិនិត្យរដ្ឋបាលគ្រូ និងរដ្ឋបាលថ្នាក់ (កិច្ចតែងការបង្រៀន និង ការតុបតែងថ្នាក់រៀន)

- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា គ្រប់កម្រិតថ្នាក់ តាមមុខវិជ្ជា
- ដឹកនាំការប្រជុំបច្ចេកទេស ប្រជុំគរុកោសល្យ និងការផ្សព្វផ្សាយសារាចរណែនាំ នានា
- ជំរុញឱ្យមានការសិក្សាស្រាវជ្រាវមេរៀន
- ពិនិត្យលើដំណើការពិសោធន៍ កុំព្យូទ័រ បណ្ណាល័យ រោងជាង សិល្បៈ និងកីឡា
- .សហការជាមួយគ្រូទាំងអស់ដើម្បីពង្រឹងគុណភាពបង្រៀន និងរៀន
- ណែនាំគ្រូ ឱ្យបង្រៀនគ្រប់មុខវិជ្ជា ជៀសវាងការរំលងមុខវិជ្ជាណាមួយដែលខ្លួនមិនពេញចិត្ត ឬមិនមានបំណិនប្រសប់
- ផ្តត់ផ្គង់សៀវភៅសិក្សាគោល ឯកសារ និងសម្ភារៈផ្សេងៗ
- .រក្សាឱ្យបាននូវបរិយាកាសគរុកោសល្យ ក្នុងសាលារៀន និងថ្នាក់រៀន
- ចូលបង្រៀនជំនួស ពេលណាមានគ្រូអវត្តមាន និងមានធុរៈម្តងៗ
- ជំរុញណែនាំសិស្សានុសិស្ស ឱ្យរៀននៅផ្ទះ និងនៅក្លិបសិក្សា(រៀនថ្ងៃមិនគ្រប់ រៀនយប់បន្ថែម)
- ជំរុញការបញ្ចប់កម្មវិធីសិក្សាគ្រប់ថ្នាក់ គ្រប់មុខវិជ្ជាប្រកបដោយគុណភាព
- ជំរុញការសិក្សារបស់សិស្ស ឆ្លងពីភូមិសិក្សាមួយទៅភូមិមួយទៀតប្រកបដោយជោគជ័យ
- វង្វាយតម្លៃសិក្សារបស់សិស្សជាដំណាក់ និងជាបញ្ចប់។

**គ. ការងារទំនាក់ទំនង**

នាយកសាលា គ្រប់រូបត្រូវមានទំនាក់ទំនងផ្ទៃក្នុងល្អ ជាមួយ នាយករង នាយិការង និងនិងបុគ្គលិកទីចាត់ការទាំងអស់ គ្រូបង្រៀន បុគ្គលិកផ្សេងៗទៀត និងសិស្សានុសិស្ស ។នាយកសាលាត្រូវមានទំនាក់ទំនងខាងផ្ទៃក្រៅឱ្យបានល្អជាមួយសហគមន៍ ពោលគឺៈ មាតាបិតាសិស្ស អាណាព្យាបាលសិស្ស អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ។




## ២.២.២ តួនាទីរបស់នាយកសាលា

គណនេយ្យភាពនាយកសាលា បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការពង្រឹងដល់គុណភាពអប់រំ។តួនាទីរបស់នាយកសាលា គឺសំដៅលើភាពទទួលខុសត្រូវខ្ពស់ក្នុងការធ្វើអ្វីៗទាំងអស់ដែលខ្លួនមានលទ្ធភាពអាចធ្វើបានដើម្បីសម្រួល និងជំរុញឱ្យបុគ្គលិកទាំងអស់បំពេញការងារដោយជោគជ័យ។

សាលារៀនដ៏ល្អមួយ ទាមទារនូវនាយកដ៏ល្អមួយដែរ ពីព្រោះនាយកសាលាដ៏ល្អ គឺជាការចាំបាច់បំផុត ហើយសំខាន់ចំពោះដំណើរការបង្រៀន និងរៀនរបស់សិស្ស។នាយកសាលា ត្រូវតែមានគណនេយ្យភាពច្បាស់លាស់ ក្នុងការដឹកនាំ និងគ្រប់គ្រងរបស់ខ្លួន ដើម្បីឱ្យការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព ស្របនឹងពាក្យស្លោកមួយឃ្លាពោលថា៖ (**នាយកសាលាជាបេះដូងរបស់សាលារៀន**) ដូចនេះ នាយកសាលាត្រូវយល់ដឹងឱ្យកាន់តែខ្លាំងពីតួនាទីសំខាន់ជាសារវន្តរបស់ខ្លួន ហើយខំប្រឹងប្រែងធ្វើខ្លួនឱ្យក្លាយជា **បេះដូងរបស់សាលារៀន**។

គណនេយ្យភាពនាយកសាលា គឺសំដៅលើសកម្មភាពមួយដែលចាំបាច់បំផុតក្នុងការជួយដល់ប្រព័ន្ធអប់រំឱ្យដំណើរការ។នាយករៀបចំចាត់ចែង និងអនុវត្តរាល់ការងារទាំងអស់នៅក្នុងអង្គភាព ព្រមទាំងនាយកជាអ្នកបណ្តុះបណ្តាលនិងជំរុញឱ្យគ្រូបង្រៀនចេះរៀន ក្នុងនោះផងដែរ គ្រូបង្រៀនមានវិធីសាស្ត្រខ្ពស់ ក្នុងការធ្វើឱ្យសិស្សចេះរៀន និងទទួលបានលទ្ធផលខ្ពស់ ជួយឱ្យសាលារៀនមួយកាន់តែប្រសើរឡើងសម្រាប់សិស្សានុសិស្ស។

**គណនេយ្យភាពនាយកសាលា គឺសំដៅលើតួនាទីសំខាន់ៗដូចខាងក្រោម៖**

ក. ជាអាជ្ញាធម៌អប់រំ

ខ. ជាមន្ត្រីរដ្ឋបាល

គ. ជាទីប្រឹក្សាគរុកោសល្យ

ឃ. ជាអធិការអេចិន្ត្រៃយ៍

ង. ជាអ្នកចរចារ

ច. ជាអ្នកអប់រំ

ឆ. ជាអ្នកផ្តល់សេវាកម្ម

ជ. ជាអ្នកពិគ្រោះយោបល់

ញ.ជាភ្នាក់ងារអេភិវឌ្ឍសហគមន៍

**ក. ជាអាជ្ញាធម៌អប់រំ៖** នាយកសាលាជាប្រតិភូអចិន្ត្រៃយ៍ របស់ក្រសួងអប់រំយុវជន និងកីឡាប្រចាំភូមិសាស្ត្រសិក្សារបស់សាលារៀននីមួយៗ ជាអ្នកធានា ទំនាក់ទំនង ការងាររវាងសាលារៀនជាមួយថ្នាក់លើ ជាអ្នកឃ្លាំមើល និងជាអ្នកអនុវត្តបទបញ្ញាសិក្សា និងលិខិតបទដ្ឋាននានា ។នាយកសាលាដឹកនាំគ្រប់សកម្មភាព និងធានា ឱ្យបាននូវប្រសិទ្ធភាពតាមគោលដៅអប់រំ ដែលបានគ្រោងទុក និងទទួលខុសត្រូវទាំងស្រុងចំពោះមុខសាលារៀន និងថ្នាក់លើនូវរាល់អ្វីដែលកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។នាយកជាអ្នកសម្របសម្រួល និងបង្រួបបង្រួមគ្រប់កម្លាំងដើម្បីអនុវត្តការងារដោយរលូនជាមួយគ្នា។

គណនេយ្យភាពនាយកសាលា ៖ផ្តោតលើ ការធ្វើផែនការសាលារៀន ពីព្រោះការធ្វើផែនការសាលារៀនគឺជាត្រីវិស័យ សម្រាប់នាយកសាលាប្រតិបត្តិ។ការធ្វើផែនមានដូចខាងក្រោម៖

**១. ផែនការគោលនយោបាយសាលារៀនៈ** នាយកសាលាត្រូវផ្តោតលើការចូលរៀនរបស់សិស្ស(អត្រាត្រួតថ្នាក់ បោះបង់ អត្រាឡើងថ្នាក់) លទ្ធផលតេស្តតាមមុខវិជ្ជា។

ផែនការបងហារៀន និងបំណែងចែកកម្មវិធីសិក្សារបស់គ្រូៈនាយកសាលាត្រូវចេះរៀបចំផែនការការងារ (ដើមឆ្នាំ កណ្តាលឆ្នាំ ចុងឆ្នាំ ឆមាស ត្រីមាស) បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា តាមកម្រិត

ថ្នាក់ ពិនិត្យកិច្ចតែងការបង្រៀននៃមុខវិជ្ជានិងតាមកម្រិតថ្នាក់ លទ្ធផលសិក្សារបស់សិស្ស ចំនួនម៉ោងសិក្សារបស់សិស្ស។

**២. ផែនការជួបជាមួយមាតាបិតានិងសហគមន៍ជួយដល់ការរៀនសូត្រៈ** នាយកសាលាត្រូវចេះរៀបចំកម្មវិធីប្រជុំពិគ្រោះយោបល់រវាងមាតាបិតាសិស្ស គ្រូបង្រៀន សិស្ស គណៈកម្មការទ្រទ្រង់សាលារៀន។

**៣. ផែនការជួយសិស្ស និងសេវាជួយសិស្សៈ** នាយកសាលារៀបចំប្រើប្រាស់បណ្ណាល័យ បន្ទប់ពិសោធ បន្ទប់កុំព្យូទ័រ បន្ទប់ភាសាបរទេស ថ្នាក់មានក្រុមសិស្សជួយសិស្ស ក្រុមប្រឹក្សាកុមារយុវជន កម្មវិធីជួយសិស្សរៀនយឺត ស្ថានភាព និងការសិក្សារបស់សិស្សអាហារូបករណ៍ កម្មវិធីទស្សនកិច្ចសិក្សារបស់គ្រូបង្រៀន ទស្សនកិច្ចសិក្សារបស់សិស្ស ប្រអប់សង្គ្រោះបឋម។

**៤. ផែនការប្រមូលនិងលើកទឹកចិត្ត សិស្សពិការបានចូលរៀនៈ** ស្រង់ទិន្នន័យ កុមារ/ យុវជន ដែលមានបញ្ហាក្នុងការសិក្សា (បញ្ហាបញ្ញា បញ្ហាមើល បញ្ហាស្តាប់) កុមារ/យុវជនពិការ កុមារ/យុវជនកំព្រា ទីទ័លក្រ កុមារ/យុវជន ស្ថិតក្នុងគ្រួសារផ្ទុកមេរោគអេដស៍ កុមារ/យុវជនគ្មានទីពឹង កុមារ/យុវជនងាយរងគ្រោះ កុមារ/យុវជន ជនជាតិភាគតិច... ដែលស្ថិតនៅក្នុងផែនដីខ្នងផ្ទះសាលារៀន។

**៥. ផែនការដឹកនាំ និងគ្រប់គ្រងៈ** នាយកសាលាត្រូវបង្កើតនូវចក្ខុវិស័យ បេសកកម្ម មានគោលដៅ គោលបំណង ការវិភាគមុខងារ ពណ៌នាមុខតំណែង រចនាសម្ព័ន្ធគ្រប់គ្រង ...និងផែនការអភិវឌ្ឍរបស់អង្គភាពច្បាស់លាស់។ រៀបចំរដ្ឋបាលសាលារៀន (គណៈកម្មការទ្រទ្រង់សាលា ទីចាត់ការ កម្រងស្ថិតិសិស្ស និងថ្នាក់ ដ្យាក្រាមស្ថិតិសិស្ស គ្រូ លទ្ធផលប្រឡង តារាងព័ត៌មានបុគ្គលិកអប់រំ ផែនទីសិក្សាថ្មី របាយការណ៍ផ្សេងៗ) អធិការកិច្ចផ្ទៃក្នុង ប្រជុំក្រុមបច្ចេកទេស វង្វាយតម្លៃប្រចាំឆ្នាំ លើការអនុវត្តការងារ របស់គ្រូបង្រៀន ផែនការទប់ស្កាត់ភាពមិនប្រក្រតី សាលាកុមារមេត្រី ការចុះជួយរបស់ការិយាល័យ អប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡា។មានផែនការកសាងសមត្ថភាពគ្រូ ដោយរៀបចំកម្មវិធីបំប៉ន ការបញ្ជូនឱ្យទៅ ចូលរួមក្នុងវគ្គបំប៉ននានា។

**៦. ផែនការធនធានមនុស្ស:** នាយកសាលាត្រូចេះប្រើប្រាស់ធនធានឱ្យបានសមស្របតាមនិយាម ដូចជា ស្ថានភាពបុគ្គលិកអប់រំក្នុងសាលារៀន បុគ្គលិកបង្រៀនសុទ្ធសាធ ផលធៀបសិស្ស-គ្រូ សិស្ស-ថ្នាក់ បន្ទប់រៀន-គ្រូ-ថ្នាក់ នាយក នាយរង បណ្ណារក្ស គណនេយ្យករ បេឡា លេខាធិការ។

**៧. ផែនការសម្ភារបង្រៀននិងរៀន:** នាយកសាលារៀបចំច្នៃប្រឌិតសម្ភារឧបទ្ទេស សៀវភៅសិក្សាគោល សៀវភៅគ្រូតាមមុខវិទ្យា និងតាមកម្រិតថ្នាក់ សៀវភៅតាមស្តង់ដាបណ្ណាល័យ។

**៨. ផែនការហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន:** នាយកសាលារៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា កសាងនិងជុសជុល ថ្នាក់រៀន បន្ទប់រៀន ផ្ទះគ្រូ បន្ទប់រដ្ឋបាល អគារ បន្ទន់អនាម័យ របងខ្លោងទ្វារសាលារៀន ផ្លូវ ប្រព័ន្ធលូរ បន្ទប់ទឹក ប្រព័ន្ធទឹក អណ្តូង រៀបចំកែលម្អសួនច្បារ សួនកសិកម្ម និងសួនជីវចម្រុះ ទីធ្លាសាលារៀន ខឿន ទីលានគោរពទង់ជាតិ ព្រមទាំងរូបសំណាកផ្សេងៗ។

**៩. ផែនការហេរញ្ញប្បទាននិងការគ្រប់គ្រងហិរញ្ញវត្ថុ:** នាយកសាលារៀបចំចាត់ចែងនិង ប្រើប្រាស់ថវិកាប្រចាំឆ្នាំ (ថវិការដ្ឋ សហគមន៍ សប្បុរសជន...)។ នាយកសាលាគប្បីរៀបចំផែនការសកម្មភាពអនុវត្តផែនការ ត្រួតពិនិត្យផែនការ និងវាយតម្លៃផែនការ ដើម្បីមានមូលដ្ឋានអនុវត្តបន្ត។

**ខ. មន្ត្រីរដ្ឋបាល៖** នាយកសាលាជាអ្នកណែនាំអនុវត្តរដ្ឋបាលសិក្សាទាំងអស់ដែលជានាធ្វើឱ្យសម្រេចគោលនយោបាយអប់រំ ចាត់ចែងសកម្មភាព និងបែងចែកភារកិច្ចឱ្យបុគ្គលិកដោយរិះរកគ្រប់មធ្យោបាយ និងវិធានការចាំបាច់ដើម្បីធ្វើឱ្យសកម្មភាពប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

***១. ការគ្រប់គ្រង និងការប្រើប្រាស់ថវិកាតាមកម្មវិធី៖*** នាយកសាលាត្រូវរៀបចំគម្រោងថវិកានិងគម្រោងចំណាយប្រចាំឆ្នាំ តាមផែនការ រួចដកថវិកាមកប្រើប្រាស់តាមគម្រោងប្រកបដោយតម្លាភាពដោយមានគណៈកម្មាគ្រប់គ្រង និងប្រើប្រាស់ថវិកានិងទូទាត់ថវិកាឱ្យទាន់ពេលវេលា។ កិច្ចបញ្ជីការគណនីត្រូវរៀបចំសៀវភៅតាមដានថវិកា មានប័ណ្ណចំណូល ប័ណ្ណចំណាយ ប័ណ្ណបញ្ចូលឃ្លាំង មានបញ្ជីបញ្ចេញសម្ភារ និងបញ្ចូលសម្ភារ ត្រួតពិនិត្យបញ្ជីសារពើភ័ណ្ឌ ការទិញសម្ភារត្រូវមានវិក័យបត្រ

ច្បាស់លាស់ ធ្វើតុល្យភាពចំណូលនិងចំណាយដោយមានរបាយការណ៍និងចងក្រងសំណុំឯកសារឱ្យបាន ត្រឹមត្រូវ។

*២. ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ* ៖នាយកសាលាត្រូវពិនិត្យទំហំផ្ទៃដីសាលារៀននិងធ្វើប្លង់កាន់កាប់ឱ្យបានទាន់ពេលវេលា ពិនិត្យអគារឱ្យបានគ្រប់គ្រាន់(ស្អាតឬទេ) រៀបចំបន្ទប់ពត៌មានវិទ្យាមានបំពាក់កុំព្យូទ័រ និងសេវាអ៊ីនធើណែត មានបន្ទប់ទីចាត់ការសមរម្យ បន្ទប់សាស្ត្រាចារ្យ បន្ទប់ពិសោធន៍ បន្ទប់កាត់ដេរ បន្ទប់រោងជាង មានបន្ទប់វប្បធម៌សិល្បៈ ព្រមទាំងមានការតាំងពិពណ៌ស្នាដៃសិស្ស មានឃ្លាំងសម្ភារប្រកបដោយសុវត្ថិភាព មានផ្ទះបាយ អាហារដ្ឋានស្អាត មានបន្ទន់អនាម័យ និងមានការថែទាំ មានប្រភពទឹកស្អាត អគ្គិសនីប្រើប្រាស់គ្រប់គ្រាន់រៀបចំទីលានកីឡានិងអត្តពលកម្ម រៀបចំប្រព័ន្ធលូរទឹករបងព័ទ្ធជុំវិញ ខ្លោងទ្វារផ្លូវទៅកាន់អគារនីមួយៗមានដង់ទងជាតិឈរលើទីតាំងសមរម្យរៀបចំសួន ច្បារសមរម្យ និងទាក់ទាញ សួនកសិកម្ម។

*៣. ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារនានា៖* នេះគឺជាផ្នែកមួយដ៏សំខាន់បំផុត នៃការងារលិខិតបទដ្ឋាន ដែលនាយកសាលាត្រូវរៀបចំទុកដាកើឱ្យបានត្រឹមត្រូវ ដូចជា៖សៀវភៅកតើត្រាលិខិតចេញ សៀវភៅកត់ត្រាលិខិតចូល មានប្រើប្រាស់កម្រងលិខិតចេញ និងកម្រងលិខិតចូល សៀវភៅទទួលនិងបែងចែកសម្ភារៈ សៀវភៅបំណែងចែកភារកិច្ចបុគ្គលិក សៀវភៅអត្តលេខសិស្ស សៀវភៅកម្រងអត្តបទតាមថ្នាក់ សៀវភៅតាមដានស្រង់វត្តមានរបស់បុគ្គលិក សៀវភៅតាមដានការសិក្សារបស់សិស្ស សៀវភៅបញ្ជូនលិខិត សៀព្យាបាលរោគ សៀវភៅបែងចែកផែនការបង្រៀន សៀវភៅទំនាក់ទំនងមាតាបិតាសិស្ស សៀវភៅប្រជុំក្រុមបច្ចេកទេស សៀវភៅប្រជុំប្រចាំខែប្រចាំឆមាស សៀវភៅកត់ត្រាការអនុវត្តកម្មវិធីសិក្សា សៀវភៅកត់ត្រាកម្រងស្នាដៃសិស្ស តារាងលិខិតផ្សេងៗ បញ្ជីនានាតាមប្រភេទ។

**គ. ជាទីប្រឹក្សាគរុកោសល្យ៖** ក្នុងឋានៈជានាយកនិងជាគ្រូបង្រៀនមានបទពិសោធ ត្រូវយកចិត្តទុកដាក់ផ្តល់ព័ត៌មាន និងមានសិទ្ធិអំណាចណែនាំគរុកោសល្យដល់គ្រូបង្រៀនក្រោមឱវាទអំពីល្បិច/វិធីបង្រៀន និងគន្លឹះល្អៗនៃការបង្រៀនព្រមទាំងស័យសិក្សានិងអភិវឌ្ឍសម្បាទាចិត្តគរុកោសល្យដោយខ្លួនឯងឈប់ឈរ។ គ្រូបង្រៀនតែងផ្តល់កិត្តិយសនិងគោរពនាយកសាលាណាដែលមានសម្បទាអាចជានា

ការរៀបចំគរុកោសល្យបានល្អ។ជាអ្នកផ្តល់យោបល់បច្ចេកទេស និងណែនាំដល់បុគ្គលិក និងគ្រូបង្រៀនឱ្យជឿជាក់លើការគ្រប់គ្រង ព្រមទាំងយល់ដឹងពីចិត្តគំនិត រិយាបថអាកប្បកិរិយារបស់បុគ្គលិក និងគ្រូបង្រៀន ដែលអាចមានផលប៉ះពាល់ដល់អង្គការ។ រាល់សំណួរឬសំណូមពររបស់បុគ្គលិក និងគ្រូបង្រៀនត្រូវមានចម្លើយនិងមិនត្រូវធ្វើអាកប្បកិរិយាធុញទ្រាន់ក្រអើតក្រទម រើសអើងឡើយ ពីព្រោះគ្រប់សំណូមពរឬចម្ងល់ទាំងអស់បង្ហាញឱ្យឃើញនូវសេចក្តីត្រូវការ ចង់ចេះ ចង់ដឹងរបស់អ្នកប្រើប្រាស់សេវា ហើយទាំងអស់នេះវាមានសារៈសំខាន់ចំពោះការប្រតិបត្តការងាររបស់យើងផ្ទាល់ និងធ្វើការកែលម្អ នូវចំណុចខ្វះខាតសំដៅសេវាដែលផ្តល់ឆ្លើយតបទៅនឹងតម្រូវការរបស់ បុគ្គលិក គ្រូបង្រៀន។

**ឃ. ជាអធិការអប់រំ៖** នាយកសាលារៀបចំផែនការធ្វើអធិការកិច្ចច្បាស់លាស់ រួចផ្សព្វផ្សាយដល់គ្រូបង្រៀននិងមានសិទ្ធិត្រួតពិនិត្យកែលម្អសកម្មភាព អប់រំ ជាពិសេសសេវាកម្មបង្រៀន និងរៀន។ បន្ទាប់ពីធ្វើអធិការកិច្ចរួច នាយកសាលាតែងតែធ្វើការណែនាំ ដើម្បីជួយកែលម្អ និងវាយតម្លៃឱ្យមានការអភិវឌ្ឍ។

*១. ការសង្កេតការងារបង្រៀន និងរៀន៖* ដើម្បីជួយទ្រទ្រង់ គឺជាការស្វែងយល់ពីការបង្រៀននិងបញ្ហានានាដែលទាក់ទងទៅនិងការរៀន និងរកដំណោះស្រាយទៅលើបញ្ហាដែលកើតមានឡើង មិនមែនជាឱកាសសម្រាប់អ្នកត្រួតពិនិត្យ មកធ្វើការវិនិច្ឆ័យគ្រូ ឬ រកកំហុសទៅលើការបង្រៀនទេគឺ ដើម្បីជួយកែលម្អនូវការបង្រៀនរបស់ពិសេសត្រូវផ្តោតទៅលើការសិក្សារបស់សិស្ស ថាតើសិស្សបានរៀនអ្វីខ្លះនិងត្រូវរកឱ្យឃើញថាតើគ្រូបង្រៀនត្រូវជួយនូវអ្វីបន្ថែមទៀតសម្រាប់ការរៀន របស់ពួកគេដូចនេះ នាយកសាលារៀបចំផែនការធ្វើអធិការកិច្ចច្បាស់លាស់និង ផ្សព្វផ្សាយដល់គ្រូបង្រៀនបានត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ព្រមទាំងមានការប្រមូលទិន្នន័យនិងវិភាគទិន្នន័យដែលស្រង់បានតារាងទម្រង់សង្កេតងាយស្រួលក្នុងការផ្តល់ព័ត៌មានត្រឡប់។ដើម្បីឱ្យការសង្កេតថ្នាក់ទទួលបានប្រសិទ្ធភាពខ្ពស់អ្នកសង្កេតការបង្រៀន និងរៀនគប្បីអនុវត្តដូចខាងក្រោម៖

- សូមពិនិត្យរកនូវគ្រប់សកម្មភាពរបស់គ្រូបង្រៀនដែលលើកទឹកចិត្តឱ្យសិស្សគិតកម្រិតខ្ពស់ ហើយកត់ត្រាចំណុចនេះគ្រូប៉ុនប្រសព្វប្រើសំណួរបើកៗរកបន្ត ឱ្យសិស្សគិតជាដៃគូរ ហៅ

សិស្សឆ្លើយដោយចៃដន្យ ឱ្យសិស្សពន្យល់សមាជិករបស់ពួកគេ ឱ្យសិស្សសង្ខេបដើម្បីលើកម្ពស់ការស្តាប់និងផ្តល់យោបល់វិញឱ្យសិស្សម្នាក់ៗសួរសិស្សម្នាក់ទៀត។

- កត់ត្រានូវរាល់ការសរសើររបស់គ្រូចំពោះសិស្សដែលគិតបានល្អ
- កត់ត្រានូវចំនួនសំណួរបិទ និងសំណួរបើកដែលគ្រូសួរសិស្ស
- ពិនិត្យមើលចំនួនសិស្សដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀន និងបង្ហាញនូវការប្រមូលអារម្មណ៍ពេញលេញក្នុងការរៀន(សិស្សមានសកម្មភាពស្តាប់ មើល អាន ពិភាក្សា សួរ ឆ្លើយ សង្ខេប សំដែងតួ...ដោយភាពរីករាយ)
- កត់ត្រានូវអ្វីទាំងអស់ដែលគ្រូធ្វើដើម្បីទ្រទ្រង់ការរៀនជាបុគ្គលរបស់សិស្ស គ្រូមានសកម្មភាពជួយសិស្សពូកែអោយកាន់តែពូកែ ជួយសិស្សរៀនយឺតដោយហៅសិស្សដែលរៀនយឺតអោយបានញឹកញាប់ លក់ទឹកចិត្តសិស្សពូកែ ជួយសិស្សរៀនយឺត...។
- ពិនិត្យមើល និងកត់ត្រានូវវិធីដែលគ្រូប្រើដើម្បី កែលម្អ វិធីដែលគាត់ជូនសិស្ស អោយគិតកាន់តែជ្រៅ *(គិតកម្រិតខ្ពស់ ឧស្សាហ៏ដើរទៅជិតសិស្សអោយបានគ្រប់ៗគ្នា)*។

*២. ការផ្តល់ព័ត៏មានត្រឡប់៖* គឺជាការទទួលស្គាល់ភាពវិជ្ជមាន ឬ ការរិះគន់ស្ថាបនាទៅលើបំណិន ឬកិច្ចការដែលបានបំពេញដើម្បីធ្វើការកែលំអ្អនូវចំណុចខ្វះខាត ព្រមទាំងផ្តល់នូវអនុសាសន៏បន្ទាប់ពីសង្កេតការបង្រៀន នូវព័ត៏មានជាក់លាក់អំពីអិរិយាបថរបស់គ្រូបង្រៀនដើម្បីជួយគាត់ ថាតើគាត់គួរបន្តរក្សាអិរិយាបថដដែល ឬត្រូវផ្លាសប្តូចេញ។ ការផ្តល់ព័ត៏មានត្រឡប់មានសារៈសំខាន់ជួយដល់គ្រូបង្រៀនបានធ្វើស្វ័យវាយតម្លៃខ្លួនឯង ដើម្បីកែលំអរនូវចំណុចខ្វះខាត ហើយទទួលយកនូវបទពិសោធ និងការណែនាំថ្មី សម្រាប់ពង្រឹងបន្ថែមលើចំណុចល្អៗដែលមានព្រមទាំងបណ្តុះគំនិតច្នៃប្រឌិតថ្មីៗ និងទទួលបានការលើកទឹកចិត្តអោយមានបម្រែបម្រួលអិរិយាបថ។ ដើម្បីអោយការផ្តល់ព័ត៏មានត្រឡប់ទទួលបានប្រសិទ្ធភាពខ្ពស់ នាយកសាលាគប្បីអនុវត្តដូចខាងក្រោម៖

- ផ្តល់ឳកាសអោយគ្រូបង្រៀនបានសម្តែងនូវការយល់ឃើញរបស់គាត់នូវចំណុចខ្លាំង និង ចំណុចខ្វះខាត អំពីការបង្រៀននោះ ហើយនាយកសាលា ត្រូវស្តាប់គាត់និយាយដោយយកចិត្តទុកដាក់បំផុត។

- ផ្តល់ជូនគ្រូបង្រៀននូវសេចក្តីសង្កេតជាវិជ្ជមាន (ផ្តោតលើចំណុចខ្លាំង)
- ផ្តល់នូវព័ត៌មានត្រឡប់ក្នុងន័យស្ថាបនាលើចំណុចខ្សោយ (ផ្តោតការយកចិត្តទុកដាក់ដែលអាចយកទៅអនុវត្តបាន)។
- បញ្ចប់ការប្រជុំដោយផ្តល់ជូនគ្រូបង្រៀននូវសេចក្តីសង្កេត ជាវិជ្ជមានថែមទៀត (បង្ហាញនូវសេចក្តីសង្កេតជាវិជ្ជមានច្រើនទៀត និងកំណត់ពេលវេលាជាក់លាក់សម្រាប់កែលម្អទៅអនាគត)។

បទបញ្ជារសំខាន់ៗមួយចំនួនក្នុងការផ្តល់ព័ត៌មានត្រឡប់៖

*១. ស្វែងរកចំណុចវិជ្ជមាន*

*២. ធានាអោយប្រាកដថា គ្រូបង្រៀនមានអារម្មណ៍ផាសុខភាព និងធូរស្រាលក្នុងចិត្ត*

*៣. លើកទឹកចិត្តគ្រូបង្រៀនអោយនិយាយអំពីការគិតផ្ទាល់ខ្លួនរបស់គេ។*

*៤. កំណត់នូវចំណុចដែលត្រូវធ្វើកំណែលម្អ*

*៥. ឱ្យគ្រូមើលកំណត់ត្រានាយកសាលា...ធ្វើដូចនេះគ្រូនឹងឃើញថាមិនមានការសម្ងាត់ទេ*

*៦. ជំពោះការទិតៀនសុំធ្វើដោយទន់ភ្លន់*

*៧. ការប្រជុំផ្តល់ព័ត៌មានត្រឡប់អាចមានរយះប្រមាណ១៥នាទី (អាចយូរជាងនេះបន្តិច)*

**ខ. ជាអ្នកចរចារ៖** នាយកសាលាជាអ្នកមានទេពកោសល្យក្នុងការដោះស្រាយវិវាទបុគ្គលិក និងវិវាទផ្សេងៗដោយសន្តិវិធីដែលកើតមាននៅក្នុងអង្គភាព។

**ច. ជាអ្នកផ្តល់សេវាកម្ម៖** នាយកសាលាជាអ្នកផ្តួចផ្តើមគំនិត និងផ្តល់សេវាកម្មឱ្យបុគ្គលិកកុំឱ្យនៅទំនេរឥតប្រយោជន៍។

**ឆ. ជាអ្នកអប់រំ៖** នាយកសាលាជាអ្នកដឹកនាំគ្រប់គ្រងអប់រំនិងបណ្តុះបណ្តាលបុគ្គលិកគ្រូបង្រៀន ដើម្បីអភិវឌ្ឍធនធានមនុស្ស។ មានការបណ្តុះបណ្តាលមិនផ្លូវការ និងផ្លូវការ ការតម្រង់ទិសការបណ្តុះ-បណ្តាលនៅកន្លែងការងារបណ្តុះបណ្តាល ផ្នែកបច្ចេកទេស ឬមិនមែនបច្ចេកទេសតាមរយៈការប្រជុំ ឬសិក្ខាសាលានានានៅក្នុងអង្គភាពឬក្រៅអង្គភាព។ ដូចនេះនាយកសាលាត្រូវតាំងខ្លួនជាប្រធានអ្នករៀន។

**ជ. ជាអ្នកផ្តល់សេវាកម្ម៖** នាយកសាលាជាអ្នកផ្តួចផ្តើមគំនិតនិងផ្តល់សកម្មភាពជាសេវាកម្មឱ្យបុគ្គលិកកុំឱ្យនៅទំនេរឥតប្រយោជន៍។

**ឈ. ជាអ្នកពិគ្រោះយោបល់៖** នាយកសាលាជាអ្នកជួយបុគ្គលិក គ្រូបង្រៀនឱ្យចេះដោះស្រាយបញ្ហាផ្ទាល់ខ្លួនធ្វើការងារឡើង ដោយប្រើវិចារណញ្ញាណឆ្ពោះទៅរកការឯកភាពគ្នានិងជួយគ្នាទៅវិញទៅមក។

**ញ. ជាភ្នាក់ងារអភិវឌ្ឍសហគមន៍៖** នាយកសាលាមានទំនាក់ទំនងល្អជាមួយគ្រួសារ សហគមន៍ អាជ្ញាធរដែនដី និងស្ថាប័ននានាដើម្បីជាគុណប្រយោជន៍ដល់បុគ្គលិក គ្រូបង្រៀននិងអង្គភាពរបស់ខ្លួន ជាភ្នាក់ងារដ៏សំខាន់និងចាំបាច់របស់សហគមន៍ជាពិសេសអភិឌ្ឍចិត្តគំនិតនិងស្មារតីព្រមទាំងមានសិទ្ធិចូលរួមគ្រប់សកម្មភាពរបស់សហគមន៍ពីតួនាទីនិងភារកិច្ចរបស់។ (*សៀវភៅ៖ការគ្រប់គ្រងរដ្ឋបាល សម្រាប់បំប៉ននាយកសាលារៀនបឋមសិក្សា និងមធ្យមសិក្សា,នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ឆ្នាំ២០០៩*)។

*ដ្យាក្រាម៖ តួនាទីរបស់នាយកសាលា*



## ២.៣ គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ

លទ្ធផលសិក្សារបស់សិស្ស ដែលទទួលបានពីការធ្វើវង្វាយតម្លៃសិស្ស និងសាលារៀន ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបញ្ជាក់ពី **គណនេយ្យភាពលើការប្រតិបត្តិរបស់សាលារៀន**។ វាជាការពិតណាស់ គណនេយ្យភាពនាយកសាលាបាននឹងកំពុងដើរតួយ៉ាងសំខាន់ ក្នុងការជួយដល់ដំណើរការបង្រៀន និងរៀន ពិសេសគឺការពង្រឹងនូវ គុណភាពអប់រំ។នាយកគឺជាអ្នកដឹកនាំការងារបង្រៀន និងរៀន (កំណែទម្រង់សាលារៀននៅកម្ពុជា, Instructional Leader,២០២២)។នាយកសាលាគឺជាបេះដូងសាលារៀន។បើនាយកជាអ្នកដឹកល្អ នោះសាលានោះ ក៏រីកចម្រើន ប៉ុន្តែបើនាយកសាលានោះ គ្មានឆន្ទៈ និងគណនេយ្យភាពទេ សាលារៀននោះក៏មិនរីកចម្រើនដែរ ពោលគឺគុណភាពអប់រំ និងការកែលម្អសាលារៀន ក៏គ្មានដែរ។ ភាពទទួលខុសត្រូវខ្ពស់របស់គណៈគ្រប់គ្រងសាលារៀន លើការដឹកនាំ និងគ្រប់គ្រង គឺជាគណនេយ្យភាពនាយកសាលា។ខាងក្រោមនេះគឺជាភាពទទួលខុសត្រូវរបស់នាយកសាលា ចំពោះការបំពេញនូវតួនាទី និងភារកិច្ច ក្នុងការងារដឹកនាំ និងគ្រប់គ្រង លើដំណើរការបង្រៀន និងបង្រៀន និងរៀន។ខាងក្រោមនេះគឺជា តួនាទី និងភារកិច្ចរបស់នាយកសលាលើដំណើរការបង្រៀនរបស់គ្រូដែលផ្តោតលើចំណុចសំខាន់ៗចំនួន៤យ៉ាងគឺៈ

១. ការបង្រៀន និងរៀន

២. វប្បធម៌សាលារៀន ឬការរៀបចំរបៀបរបបដំណើរការ

៣. ការគ្រប់គ្រងធនធានមនុស្ស

៤. ការរៀបចំ និងការអនុវត្តផែនការ

### ២.៣.១ ការបង្រៀន និង រៀន

នាយក គឺជាអ្នកដឹកនាំការរៀន និងការបង្រៀន (Instructional Leader) ដើម្បីអនុវត្តកម្មវិធីសិក្សាឱ្យបានល្អប្រសើរ ដោយរៀបចំផែនការ ជានានូវការអនុវត្តយុទ្ធសាស្រ្តបង្រៀន ការរៀបចំថ្នាក់រៀន និងការធ្វើវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ការងាររបស់នាយកត្រូវផ្តោតលើការរៀបចំបរិស្ថាន

សិក្សាល្អ ការរៀបចំថ្នាក់រៀន ការផ្តល់សម្ភារឧបទេស បន្ទប់ពិសោធការរៀបចំកាលវិភាគបង្រៀន ការអនុវត្តកម្មវិធីសិក្សា ការអនុវត្តវិធីសាស្ត្របង្រៀន ការប្រជុំក្រុមបច្ចេកទេសដើម្បីផ្តល់យោបល់កែលម្អសាលារៀន។

ការងារទាំងអស់នេះត្រូវបានបែងចែកជាបួនចំណែកៈ

១. **ការអនុវត្តកម្មវិធីសិក្សាៈ** នាយកត្រូវដឹងពី ក្របខ័ណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងយុទ្ធសាស្ត្របង្រៀន ដើម្បីជួយដល់គ្រូអនុវត្តកម្មវិធីសិក្សា និងសម្រេចបាននូវលទ្ធផលសិក្សា ដោយចែកកម្មវិធិសិក្សាជាមេរៀនដែលមានគោលដៅច្បាស់លាស់ សកម្មភាពល លទ្ធផលសិក្សារបស់សិស្ស និងវង្វាយតម្លៃសម្រាប់មេរៀននីមួយៗ ទៅតាមចំណាត់ចំណេះដឹងរបស់ (BLOOM)។ គ្រូត្រូវយកចិត្តទុកដាក់បង្រៀនមេរៀនដែលលំបាក ដោយប្រើប្រាស់លទ្ធផលនៃការធ្វើវង្វាយតម្លៃ ដើម្បីកែលម្អការបង្រៀន។

២. **ការបង្រៀននៅក្នុងថ្នាក់ៈ** នាយកត្រូវអនុវត្តយុទ្ធសាស្ត្របង្រៀន ដោយធានាឱ្យបាននូវថ្នាក់រៀនមួយដែលមានសម្ភារឧបទេស មានបរិស្ថានស្អាត និងជួយគាំទ្រគ្រូ និងសិស្ស ក្នុងការបង្រៀន និងរៀនដើម្បីទទួលបានលទ្ធផលសិក្សាតាមការរំពឹងទុក តាមរយៈការត្រួតពិនិត្យ និងវិធានការកែលម្អជាប្រចាំ។ នាយកត្រូវពិនិត្យថាវិធីសាស្ត្រមួយណា ដែលជួយឱ្យសិស្សខិតខំប្រឹងប្រែងរៀនសូត្រ សម្រេចបាននូវលទ្ធផលសិក្សា ជាចំណេះដឹង បំណិនបច្ចេកទេស និងបំណិនទន់ បំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហា។ គ្រូត្រូវមានគុណវុឌ្ឍិ បំណិន និងវិធីសាស្ត្របង្រៀន ដើម្បីជួយសិស្សទាំងអស់ឱ្យសម្រេចបានតាមគោលដៅរំពឹងទុក។ នាយកត្រូវរៀបចំឱកាសឱ្យគ្រូទទួលបាននូវការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ តាមរយៈការធ្វើវិក្រិតការរយៈពេលខ្លី ការបំប៉ននៅនឹងកន្លែង ការចូលរួមក្នុងវគ្គសិក្សាវែង។នាយកត្រូវបង្កើតនូវសហគមន៍ផ្លាស់ប្តូរបទពិសោធវិជ្ជាជីវៈ(PLC) ដើម្បីឱ្យគ្រូអាចកែលម្អវិធីសាស្ត្របង្រៀន និងចែករំលែកបទពិសោធថ្មីៗបាន។នាយកត្រូវស្រាវជ្រាវ និងផ្តួចផ្តើមគំនិត ដើម្បីអនុវត្តបិធីសាស្ត្រថ្មីៗដើម្បីឆ្លើយតបទៅនឹងនិន្នាការបច្ចុប្បន្នលើសកលលោក។ នាយកត្រូវត្រួតពិនិត្យជាប្រចាំនូវលទ្ធផលសិក្សារបស់សិស្ស ជាពិសេសដោយផ្តោតលើទស្សនទាន បំណិ

នបច្ចេកទេស និងបំណិនទន់។នាយកត្រូវរៀបចំប្រជុំបច្ចេកទេស និងផ្តល់ឱកាសឱ្យគ្រូចូលរួមប្រជុំ និងពិក្សាដើម្បីកែលម្អវិធីសាស្ត្របង្រៀន។

៣. **ការវិភាគទិន្នន័យះ** នាយកត្រូវប្រមូលទិន្នន័យស្តីពីវត្តមានរបស់សិស្ស និងគ្រូ ការគោរពវិន័យ លទ្ធផលសិក្សារបស់សិស្សតាមថ្នាក់ និងតាមមុខវិជ្ជា ដោយប្រើប្រាស់រង្វាយតម្លៃសិក្សា ហើយដាក់ចេញនូវវិធានការកែលម្អ ដោយមានការចូលរួមពីសំណាក់គ្រូ និងសិស្ស។នាយកត្រូវមានយន្តការ ដើម្បីឱ្យគ្រូទទួលខុសត្រូវ ចំពោះលទ្ធផលសិក្សារបស់សិស្ស។នាយកប្រើនូវទិន្នន័យស្តីពីពិន្ទុប្រចាំខែ ប្រចាំឆមាស ប្រចាំត្រីមាស ប្រចាំឆ្នាំ និងលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ តាមមុខវិជ្ជា ដើម្បីដាក់ចេញនូវវិធានការ កែលម្អការបង្រៀន និងរៀន។នាយកត្រូវតាមដានសិស្សរបស់ខ្លួន ដែលរៀនចប់នៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីវាយតម្លៃ និងរៀបចំផែនការកែលម្អ ដោយផ្តោតលើចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្ស។នាយកត្រូវបង្កលក្ខណៈឱ្យគ្រូអាចចូលរួម ដាក់ចេញនូវ វិធានការកែលម្អ ដោយលើឡើងពី ឧត្តមានុវត្តន៍ និងវិធានការកែតម្រូវ។

៤ **.ការអនុវត្តវិធីសាស្ត្របង្រៀនទៅតាមសមត្ថភាពសិស្សះ**នាយកត្រូវជួយគ្រូ ក្នុងការប្រើវិធីសាស្ត្របង្រៀន ដែលឆ្លើយតបទៅនឹងសិស្សផ្សេងៗគ្នា។នាយកត្រូវធ្វការជាមួយគ្រូ ដើម្បីសិស្សខ្សោយតាមមុខវិជ្ជា ហើយដាកើចេញនូវវិធានការជួយសិស្សខ្សោយ ដោយបង្កើតឱកាសសិក្សាម៉ោងបន្ថែម និងផ្តល់ការលើកទឹកចិត្ត ដល់គ្រូក្នុងការជួយសិស្សរៀនបន្ថែមម៉ោងបំពេញបន្ថែមនូវចំណុចខ្វះខាត របស់សិស្ស កាត់បន្ថយហានិភ័យផ្សេងៗ។

## ២.៣.២ វប្បធម៌សាលារៀន ឬការរៀបចំរបៀបរបបដំណើរការ

វប្បធម៌សាលារៀន គឺជាមូលដ្ឋានគ្រឹះនៃកិច្ចដំណើរការនៃសាលារៀនល្អ។ ដើម្បីបង្កើតឱ្យមានវប្បធម៌ការសិក្សារៀនសូត្រ និងការសម្រេចបាននូវ ឧត្តមភាព នាយកត្រូវរៀបចំបញ្ចីលទ្ធផលសិក្សាដែលត្រូវសម្រេចបាន និងវិធានការដែលគណៈគ្រប់គ្រង និងសាស្ត្រាចារ្យត្រូវអនុវត្ត ដើម្បីសម្រេចបានតាមគោលដៅដែលបានដាក់ចេញ។

ការគ្រប់គ្រងធនធានមនុស្ស៖សាលាល្អ គឺជាសាលាដែលមាននាយកល្អ ចេះទាក់ទាញគ្រូល្អ ជ្រើសរើសគ្រូដែលមានសមត្ថភាព បទពិសោធ ជួយគាំទ្រ និងចេះរក្សាគ្រូល្អ តាមរយៈការលើកទឹកចិត្តខាងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។នាយកត្រូវកំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមបច្ចេកទេសតាមមុខវិជ្ជា ការជ្រើសរើសប្រធាន អនុប្រធានក្រុមបច្ចេកទេសដែលមានសមត្ថភាពខ្ពស់។ការគ្រប់គ្រងធនធានមនុស្សត្រូវផ្តោតលើបួនចំណុចខាងក្រោម៖

- ការជ្រើសរើស និងបំប៉នគ្រូ
- ការបង្កើតក្រុមបច្ចេកទេស
- ការត្រួតពិនិត្យនិងការវាយតម្លៃការងាររបស់គ្រូ
- ការអភិវឌ្ឍវិជ្ជាជីវៈនិងសហប្រតិបត្តិការ

**១. ការជ្រើសរើសនិងបំប៉នគ្រូ៖** សាលាត្រូវជ្រើសរើសគ្រូ បំប៉នគ្រូ និងបង្កលក្ខណៈឱ្យគ្រូអាចបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធខ្ពស់។នាយកត្រូវចេះជ្រើសរើសគ្រូ ដែលជឿលើបេកសកម្មភាពសាលា មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការជួយសិស្សក្នុងការរៀនសូត្រ និងខិតខំប្រឹងប្រែងបន្តអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន។

**២. ការបង្កើតក្រុមបច្ចេកទេស៖** សាលាត្រូវបង្កើតក្រុមបច្ចេកទេសដែលមានសមត្ថភាពដឹកនាំការជួយគាំទ្រដល់គ្រូ ក្នុងការកែលម្អការបង្រៀន និងរៀន។ប្រធានអនុប្រធានក្រុមបច្ចេកទេសមានតួនាទីយ៉ាងសំខាន់ ក្នុងការជួយសិស្សឱ្យទទួលបានលទ្ធផលសិក្សាល្អ។ ដូច្នេះនាយកត្រូវចេះបង្កលក្ខណៈឱ្យគ្រូជ្រើសរើសប្រធានក្រុមបច្ចេកទេសមានសមត្ថភាពដែលអាចជួយសាលាឱ្យសម្រេចបានតាមបេសកកម្មរបស់ខ្លួន។

**៣. ការត្រួតពិនិត្យនិងវាយតម្លៃការងាររបស់គ្រូ៖**នាយកសាលា ត្រូវបង្កើតយន្តការវាយតម្លៃលទ្ធផលការងាររបស់គ្រូម្នាក់ៗ តាមរយៈយន្តការពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងារ និងការផ្តល់មតិយោបល់ត្រឡប់ដើម្បីឱ្យគ្រូអាច កែលម្អការបង្រៀន និងរៀន ឱ្យមានប្រសិទ្ធភាពខ្ពស់។

**៤. ការអភិវឌ្ឍវិជ្ជាជីវៈនិងសហប្រតិបត្តិការៈ** សាលាត្រូវបង្កើតសហគមន៍វិជ្ជាជីវៈ (PLC) ដែលបង្កលក្ខណៈឱ្យគ្រូអាចកែលម្អវិធីសាស្ត្របង្រៀន និងការគ្រប់គ្រងថ្នាក់រៀន ចែករំលែកឧត្តមានុភាព និងអនុវត្តនូវវិធីសាស្ត្រនវានុវត្តន៍នៅក្នុងសាលារៀន។សាលាល្អ គឺសាលាដែលអនុវត្តវិធីសាស្ត្រល្អនៅក្នុងថ្នាក់។

**ការរៀបចំ និងការអនុវត្តផែនការៈ** ការរៀបចំផែនការត្រូវចែកចេញជាបួនដំណាក់កាលគឺៈ

- **ការប្រើប្រាស់ទិន្នន័យក្នុងការកំណត់បញ្ហា**
- **ការកំណត់អាទិភាព**
- **ការដាក់ចេញគោលដៅ ការកំណត់យុទ្ធសាស្ត្រ និងការរៀបចំផែនការសកម្មភាព**
- **ការត្រួតពិនិត្យនិងការកែលម្អផែនការសកម្មភាព**
- **ការប្រើប្រាស់ទិន្នន័យក្នុងការកំណត់បញ្ហាៈ** ការរៀបចំផែនការត្រូវចាប់ផ្តើមពីៈ ១)លទ្ធផលតេស្ត(Summative assessment) តាមកម្រិតថ្នាក់ តាមមុខវិជ្ជា និងតាមក្រុមសិស្ស ២) លទ្ធផលវង្វាយតម្លៃក្នុងថ្នាក់រៀនដោយគ្រូប្រចាំថ្នាក់(Formative assessment) ៣)ទិន្នន័យសិស្សផ្ទេរចូល និងផ្ទេរចេញ ៤) អត្រាវត្តមានតាមកម្រិតថ្នាក់ ៥)អត្រាសិស្សត្រួតថ្នាក់ និង ៦)មធ្យមភាគពិន្ទុ។តាមរយៈទិន្នន័យទាំងនេះ គេអាចកំណត់ថាសិស្សខ្សោយ គណិតវិទ្យា ការសរសេរ ឬអំណាន។នាយកត្រូវអង្គុយមើលការបង្រៀន ពិនិត្យកិច្ចតែងការបង្រៀន ការងាររបស់សិស្ស និងប្រជុំវាយតម្លៃការរៀន និងការបង្រៀន។នាយកត្រូវជួបពិភាក្សាជាមួយមាតាបិតា ដើម្បីស្វែងយល់ពីការរំពឹងទុក ពីលទ្ធផលសិក្សារបស់សិស្សផង។
- **ការកំណត់អាទិភាពៈ** នាយកត្រូវដាក់ចេញផែនការសកម្មភាពជាអាទិភាព តាមមុខព្រួញនីមួយៗ និងដាក់ចេញការវាយតម្លៃថា សម្រេច ឬមិនសម្រេចបាន(លទ្ធផលគណិតវិទ្យា លទ្ធផលអំណាន ផែនការ និងការអនុវត្ត ការរៀន និងការបង្រៀន ការគ្រប់គ្រងបុគ្គលិក។

- **ការដាក់ចេញគោលដៅ ការកំណត់យុទ្ធសាស្ត្រ និងការរៀបចំផែនការសកម្មភាព៖** ផែនការត្រូវមាន៖១)ការកំណត់បញ្ហា ដូចជាអត្រាសិស្សដែលមិនចេះគណិតវិទ្យា ឬ អំណានតាមស្តង់ដារ ២)បង្កើនអត្រាសិស្សអាចស្ទាត់ចំនួន១៥ភាគរយ ក្នុង១ឆ្នាំ តាមរយៈការជួយបំប៉នបន្ថែមសិស្សក្នុងការអាន និងសរសេរ និង៣)ការដាក់ចេញនូវសកម្មភាពជាក់ស្តែង ប្រចាំសប្តាហ៍ដើម្បីជួយសិស្ស។
- **ការត្រួតពិនិត្យនិងការកែលម្អផែនការសកម្មភាព៖** ត្រង់ចំណុចនេះ នាយកត្រូវផ្តោតលើ៖ ១)ការវាយតម្លៃសភាពបច្ចុប្បន្ននៃការបង្រៀនសិស្ស និងការរៀន ២)ការកំណត់អាទិភាពក្នុងការកែលម្អ និងដោះស្រាយបញ្ហា និងទី ៣)ការរៀបចំយុទ្ធសាស្ត្រ ដើម្បីសម្រេចបានតាមអាទិភាព ដែលបានដាក់ចេញ និងកំណត់សូចនាករ ដែលត្រូវសម្រេចបានតាមពេលវេលាកំណត់។

**ការដឹកនាំសាលារៀន៖** ភាពជាអ្នកដឹកនាំសាលារៀន ត្រូវបែងចែកចេញជា ៥ផ្នែកគឺ៖

- **ការដឹកនាំឈរលើមូលដ្ឋានជំនឿជឿជាក់ និងគោលដៅ៖** អ្នកដឹកនាំត្រូវជឿជាក់ថាសិស្សម្នាក់ៗ សុទ្ធតែអាចទទួលបានលទ្ធផលសិក្សាល្អ។
- **ការដឹកនាំផ្តោតលើសមធម៌៖** អ្នកដឹកនាំត្រូវបំបាត់នូវការអនុវត្តដែលគ្មានសមធម៌ និងបង្កើតនូវបរិស្ថានដែលជួយសិស្សគ្រប់រូប ទាំងមាន ទាំងក្រឱ្យបានរៀនសូត្រ និងសម្រេចបាននូវជោគជ័យ ក្នុងការសិក្សា។
- **.ការដឹកនាំផ្តោតលើទំនាក់ទំនងបុគ្គល៖** អ្នកដឹកនាំត្រូវបង្កើតនូវទំនាក់ទំនងដែលគេជឿ និងជួយសិស្សឱ្យខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីសម្រេចជោគជ័យក្នុងការសិក្សា។
- **ការដឹកនាំដែលប្រែប្រួលទៅតាមសភាពការណ៍៖** អ្នកដឹកនាំត្រូវកៀរគរគ្រប់ភាគីទាំងអស់ ឱ្យជម្នះគ្រប់ឧបសគ្គ និងបញ្ហាប្រឈម ដែលទាមទារឱ្យមានការផ្លាស់ប្តូរតម្លៃ ជំនឿ សម្មតិកម្ម និងទម្លាប់។

- **ការដឹកនាំដែលធន់និងជម្នះឧបសគ្គ៖** អ្នកដឹកនាំត្រូវបង្ហាញពី ការយល់ដឹងបញ្ហារបស់ខ្លួនមានគំនិតរៀនពេញមួយជីវិត មានការអត់ធន់ និងខិតខំកែលម្អជាប្រចាំ។*(កំណែទម្រង់សាលារៀន នៅកម្ពុជា,ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន, ២០២០)។*

## ២.៣.៣ ការដឹកនាំ និងការគ្រប់គ្រង (ស្វ័យភាព និងគណនេយ្យភាព)

គុណភាពអប់រំត្រូវផ្ដើមចេញពីគុណភាពគ្រូបង្រៀន និងគុណភាពនាយកនាយកសាលា។នាយកសាលាត្រូវដឹងពីមុខងារ តួនាទី និងភារកិច្ចរបស់ខ្លួនជាអ្នកគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ។ ការគ្រប់គ្រងគ្មានរូបមន្តជាក់លាក់ងាយស្រួលណាមួយដោយក្រោយពីរៀនចេះទៅ អាចជួយអ្នកគ្រប់គ្រងឱ្យធ្វើអ្វីត្រូវជានិច្ច ឬសម្រេចតាមគោលបំណងរហូតនោះទេ។អ្វីជាការដឹកនាំ? អ្វីជាការគ្រប់គ្រង? នាយកសាលាត្រូវធ្វើកិច្ចការអ្វីខ្លះ ដើម្បីអោយការដឹកនាំ និងគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព?

**ការដឹកនាំ៖** គឺសំដៅដល់ការឈានមុខមនុស្សទាំងឡាយ ធ្វើជាគំរូដល់មនុស្សទាំងឡាយធ្វើគ្រប់សកម្មភាព ដូចជាការដេក ដើរ ឈរ អង្គុយ និយាយ ស្ដាប់ គិត ផ្នត់គំនិតវិជ្ជមាន ភាពឆ្លាតវៃ រហ័សរហួន។ល។ ការដឹកនាំមនុស្សអោយធ្វើទង្វើល្អ ដើរផ្លូវល្អ ផ្លូវត្រឹមត្រូវ មិនបំផ្លាញផលប្រយោជន៍មនុស្សជាតិ ឬសង្គម មិនបំផ្លាញអ្នកដ៏ទៃ ឬដៃគូប្រកួតប្រជែង ហើយមានចក្ខុវិស័យត្រឹមត្រូវ។

**ការគ្រប់គ្រង៖** គឺសំដៅដល់ការធ្វើផែនការ ការរៀបចំផែនការ ការរៀបចំចាត់ចែង ការដឹកនាំ និងការត្រួតពិនិតធនធានមនុស្ស និងធនធានដទៃទៀត និងកិច្ចសហការគ្នា ជាមួយបុគ្គលិក ដើម្បីអោយសម្រេចនៅគោលដៅរបស់អង្គភាព សាលារៀន ឬស្ថាប័នប្រកមដោយប្រសិទ្ធភាព។

នាយកសាលាត្រូវតែធ្វើការរៀបចំចាត់ចែងនានា ដើម្បីប្រើមនុស្សទាំងឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន អោយធ្វើការជូនធង្គភាពយ៉ាងមានប្រសិទ្ធភាព និងមានប្រសិទ្ធផលខ្ពស់ រួមបញ្ចូលថែមនូវការឈានមុខមនុស្សទាំងឡាយ ធ្វើជាគម្រូដល់មនុស្សទាំងឡាយលើគ្រប់សកម្មភាព និងនាំឱ្យអោយមនុស្សបុក្គលិក ធ្វើទង្វើល្អ ដើផ្លូវល្អ គិតប្រយោជន៏សាលារៀន សង្គម និងប្រទេសជាតិ។ ក្នុងន័យនេះ នាយកសាលារៀនដែលល្អ គឺជានាយកដែលគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព ដែលធ្វើអោ

យសម្រេចបាននូវគោលបំណង និងគោលដៅអប់រំស្របទៅនឹងគោលនយោបាយអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈកិច្ចការសំខាន់ៗ ចំនួន៣ ធំផងដែរ រួមមាន៖

**ការគ្រប់គ្រង៖**
→ **១. ការគ្រប់គ្រងរដ្ឋបាល**
→ **២. ការគ្រប់គ្រងបុគ្គលិក**
→ **៣. ការគ្រប់គ្រងហិរញ្ញវត្ថុ**

**១. ការគ្រប់គ្រងរដ្ឋបាល៖** គឺជាសមាសភាពនៃការគ្រប់គ្រងតាមសាលារៀន ប្រកបដោយប្រសិទ្ធភាព។នាយកសាលារៀនជាអ្នកអនុវត្តដោយផ្ទាល់ក្នុងការគ្រប់គ្រងសាលារៀន ត្រូវបានអនុវត្តសម្រាប់ជួយការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលារៀន ដើម្បីជានាដល់ប្រសិទ្ធភាពការងារក្នុងការផ្តល់សេវាអប់រំ ដោយមានការចូលរួមពីសហគន៍មូលដ្ឋាន ឆ្លើយតបទៅនិងតម្រូវការចាំបាច់លើការអភិវឌ្ឍចំណេះដឹង។ នៅក្នុងស្ថប័ន ឬអង្គភាពនីមួយៗទាមទាចាំបាច់ត្រូវរៀបចំផ្នែករដ្ឋបាលទូទៅជាមួយឱ្យបានល្អមានវិន័យ មានរបៀបរៀបរយតាមលំដាប់ឋានានុក្រមច្បាប់ និងលិខិតបទដ្ឋាន ជាមធ្យោបាយសមត្ថកិច្ចនៃក្រសួងស្ថាប័ន ឬអង្គភាពរបស់ខ្លួន។ ការងាររដ្ឋបាលទូទៅមានការងាររៀបចំ ការងារពិធីការ ការងារតាក់តែងលិខិត ការងារសណ្តាប់ធ្នាប់សន្តិសុខ ការងារឯកសារ និងព័ត៌មានពាក់ព័ន្ធនិងសមត្ថកិច្ចរបស់ក្រសួងជាដើម។ចំណែកឯការគ្រប់គ្រងរដ្ឋបាលតាមការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM)មាន៣ផ្នែកសំខាន់ៗដែលមានតួនាទី ខុសៗគ្នាគឺ៖

- **គណៈកម្មការគ្រប់គ្រងសាលារៀន/គណៈកម្មការទ្រទ្រង់អភិវឌ្ឍសាលារៀន៖**មានសមាសភាពគណៈនាយកសាលា ប្រធានក្រុមសាលា ក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់/ចៅសង្កាត់រង អាជ្ញាធរ មេភូមិជាដើម ទទួលខុសត្រូវក្នុងការចូលរួមរាល់កិច្ចការទាំងឡាយ និងតាមដានការងារផ្សេងៗដូចជា៖ (១) ការចូលរួមដោះស្រាយបញ្ហាអវិជ្ជមាននៅតាមសាលារៀននីមួយៗនៅពេលជួបប្រទះគ្រោះមហន្តរាយធម្មជាតិ (២) ការចូលរួមឃោសនាក្នុងយុទ្ធនាការប្រមូលសិស្សចូលរៀន ការឃោសនាអប់រំ និងបណ្តុះបណ្តាលដល់សហគមន៍មាតាបិតាសិស្ស (៣) ជួយសង្គ្រោះដល់កុមារងាយរងគ្រោះ កុមារពិការ កុមារក្នុងគ្រួសារក្រីក្រ ជួបការលំបាក កាប្រើអំពើហិង្សាក្នុងគ្រួសាលើផ្លូវកាយ ផ្លូវចិត្ត និងការប្រព្រឹត្តលើកុមារ ក្នុងនោះមាន

សមាសភាពក្រុមប្រឹក្សាសង្កាត់ដែលទទួលបន្ទុកការងារស្ត្រី និងកុមារដែលត្រូវយកចិត្តទុកដាក់ក្នុងកិច្ចការនេះ (៤) ចូលរួមពិនិត្យតាមដាន និងលើកទឹកចិត្តដល់លោកគ្រូអ្នកគ្រូក្នុងការអនុវត្តតួនាទីនិងភារកិច្ចបង្រៀនរបស់ខ្លួនឱ្យមានប្រសិទ្ធិភាពខ្ពស់ក្នុងការផ្តល់សេវាអប់រំក្នុងមូលដ្ឋានរបស់ខ្លួន (៥) ការចូលរួមគ្រប់គ្រងទិន្នន័យស្ថិតិគ្រូ សិស្ស ការបោះបង់ការសិក្សា អត្រាត្រួតថ្នាក់ ឡើងថ្នាក់ និងការចូលរៀនឡើងវិញ (៦) រៀបចំការផ្តល់សេវាសុវត្ថិភាព និងបរិយាកាសសិក្សាក្នុងសាលារៀន ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយមេត្រីភាព សម្រាប់ទាំងអស់គ្នា។

- **គណៈកម្មការគ្រប់គ្រងថ្នាក់រៀន៖** មានសមាសភាពគណៈនាយកទទួលបន្ទុក គ្រូទទួលបន្ទុកថ្នាក់គ្រូជំនួយបន្ទុកថ្នាក់ គ្រូប្រចាំមុខវិជ្ជា ប្រធាន/អនុប្រធានថ្នាក់ ត្រូវរួមគ្នាតានដាន និងស្វែងយល់ (១) ការសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ តាមរយៈការសង្កេតតាមថ្នាក់ សួរព័ត៌មានពីគ្រូ សិស្ស ការប្រជុំលើការមករៀនទៀងទាត់ ការផ្តល់ព័ត៌មានត្រឡប់ទៅគ្រូ សិស្ស និងអាណាព្យាបាលសិស្ស (២) ការប្រើប្រាស់ និងការផលិតសម្ភារឧទ្ទេស បង្រៀន និងរៀន (៣) បរិស្ថាន អនាម័យសិក្សាក្នុងនិងក្រៅថ្នាក់ (៤) ការប្រឡង តេស្ត និងលិទ្ធផលរបសើសិស្ស

- **គណៈកម្មការក្រុមប្រឹក្សាកុមារនិងយុវជនសម្រាប់សាលារៀន៖** គឺការជួយឱ្យកុមារយុវជនមានសម្ថភាពជួយខ្លួនឯង និងអ្នកដទៃ តាមរយៈការសិក្សាតាមក្រុម ក្លឹប និងក្នុងបណ្ណាល័យនិងជួយសម្របសម្រួលដោះស្រាយបញ្ហាវិជ្ជមាន ក្នុងសាលារៀន ក្នុងថ្នាក់ និងក្រៅថ្នា ការចូលរួមធ្វើផែនការ ដើម្បីប្រយោជន៍ដល់ការសិក្សារបស់កុមារ យុវជន ព្រមទាំងធ្វើរបាយការណ៍និងរាយការណ៍និងផ្លូវការ និងមិនផ្លូវការដល់គណៈគ្រប់គ្រងនិងគ្រូទទួលបន្ទុកការងារក្រុមប្រឹក្សាកុមារ និងយុវជន។

- **គណៈកម្មការផ្សេងៗ៖** រួមមានគណៈកម្មការប្រឡងប្រណាំង គណៈកម្មការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងក្មេងទំនើងក្នុងសាលារៀន គណៈកម្មការប្រយុទ្ធប្រឆាំង និងការជួញដូរ រត់ពន្ធធ្វើអាជីវកម្មពលកម្មលើកុមារ និងស្រីក្នុងសាលារៀន សមាសភាពទាំអស់នេះត្រូវមានគណៈនាយក ចៅសង្កាត់ក្រុបប្រឹក្សាសង្កាត់ អាជ្ញាធរ មេភូមិ មាតាបិតាសិស្សចូលរួមតាមលទ្ធភាពរបស់ពួកគាត់ ដើម្បីឱ្យ

សាលារៀនក្នុងមូលដ្ឋានទទួលបានសុវត្ថភាពនិងភាពប្រសើរឡើងក្នុងការធ្វើឱ្យសេវាអប់រំក្នុងមូលដ្ឋានបានល្អឆ្លើយតបទៅនិងតម្រូលការជាក់ស្តែងក្នុងរស់នៅ។

២. **ការគ្រប់បុគ្គលិកៈ** នាយកសាលាត្រូវមានឥរិយាបថល្អៗក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួនប្រកបដោយភាពទទួលខុសត្រូវៈ

- ស្វែងយល់ពីសុខទុក្ខរបស់គ្រូ និងបុគ្គលិកក្នុងសាលា ដោយសិក្សាពីស្ថានភាពជីវភាពរបស់គ្រូព័ត៌មាននានាដែលពាក់ព័ន្ធនឹងគ្រូបង្រៀន (ប្រវត្តិកន្លែងស្នាក់នៅ ឈ្មោះ លេខទូរស័ព្ទ ចំណង់ចំណូលចិត្ត និងថ្ងៃ ខែ ឆ្នាំចូលនិវត្តន៍)។
- ការលើកទឹកចិត្តអ្នកដែលមានស្នាដៃល្អ ដោយស្នើដំឡើងថ្នាក់ ឋានន្តរស័ក្តិ ផ្តល់ប័ណ្ណសរសើរ។
- ការណែនាំឱ្យគ្រូចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ។
- ការវាយតម្លៃការបំពេញការងារគ្រូបង្រៀនប្រកបដោយតម្លាភាព។
- ការបង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់ នៅក្នុងសាលារៀនឱ្យទទួលបានការសិក្សាបន្ថែម (ជំរុញឱ្យធ្វើការស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹង លើមុខវិជ្ជាបង្រៀន និងគរុកោសល្យ)។
- ការលើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូនង្រៀន។

៣. **ការគ្រប់គ្រងហិរញ្ញវត្ថុៈ** សាលារៀនមួយ ទោះធំក្តី តូចក្តី សុទ្ធតែទទួលបាននូវកញ្ចប់ថវិកាថេសម្រាប់ដំណើរសាលារៀន និងថវិកាអថេដែលទទួលបានតាម ចំនួនសិស្ស តាមតំបន់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការធ្វើផែនការថវិការប្រចាំងតាមសាលារៀននីមួយៗ ដើម្បីអោយការគ្រប់គ្រងថវិកាប្រចាំឆ្នាំតាមសាលារៀននីមួយៗ ដើម្បីអោយការគ្រប់គ្រងថវិកាដំណើការសាលារៀនបានល្អ មានតម្លាភាព មានសុច្ឆ្ទិតភាព និងចំទិសដៅតាមផែនការរបស់សាលាដែលបានគ្រោងទុកក្នុងការរួមចំណែកអភិវឌ្ឍន៍ កែលំអរសោភ័ណភាពសាលា ការបង្រៀន និងការរៀនអោយទទួលបានលទ្ធផលល្អប្រសើរនោះត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធ ដូចជាលោកគ្រូអ្នកគ្រូ សហគមន៏ មាតាបិតា អាជ្ញាធរ ក្នុងការប្រើប្រាស់

ថវិកា ឱ្យមានប្រសិទ្ធភាព ឆ្លើយតបទៅនិងការធ្វើកំណែទម្រង់ស៊ីជម្រៅរបសើ ក្រសួងអប់រំ យុវជន និងកីឡា។ ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ ជាកត្តាយ៉ាងសំខាន់ក្នុងការជួយគាំទ្រឱ្យសាលារៀនសម្រេចបាននៅផែនកា និងជានាអោយបាននីការសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាពនៃអ្នកដឹកនាំរបស់នាយកសាលា ឆ្លើយតបទៅនិងតម្រូវការខាងសេដ្ឋកិច្ចសង្គម ជីវភាពរស់នៅ និងការរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មាន។ ការគ្រប់គ្រងហិរញ្ញវត្ថុតាមសាលារៀនបានល្អប្រសិទ្ធភាពខ្ពស់តម្លាភាព និងត្រឹមត្រូវ សាលារៀនទាំងអស់ត្រូវរៀបចំអោយមានគណៈកម្មកាគ្រប់គ្រង និងប្រើប្រាស់ជាលាយលក្ខណ៏អក្សរ ក្នុការអនុវត្តតួនាទី និងភារកិច្ចរបស់សមាជិកនីមួយៗក្នុងគណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ថវិកា និងអនុគណៈកម្មកាតាមផ្នែកនីមួយៗ ដើម្បីចូលរួមអនុវត្តក្នុងការសម្រេចចិត្ត និងពិនិត្យតាមដាន និងធ្វើរបាយការស្តីពីវឌ្ឍនៈភាព តាមរយៈការពង្រឹងការទទួលខុសត្រូវតាមតួនាទីរបស់ខ្លួនក្នុងគោលបំណងសម្រេចគោលដៅអប់រំប្រកបដោយ ចីរភាព និងបរិយាបន្ន នឹងផ្តល់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ការគ្រប់គ្រងហិរញ្ញវត្ថុគឺផ្តោតលើ ការពិនិត្យតាមដាន និងវាយតម្លៃ លើលទ្ធផលនៃការអនុវត្តផែនការកែលម្អរសាលារៀន (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ)។នៅក្នុងបរិបទនៃវិមកាលមជ្ឍការ ការផ្តល់ធន

ជាន និងយន្តការសមស្រប ដើម្បីតម្លាភាពការងារដល់ប្រព័ន្ធអប់រំ គឺជាកត្តាសំខាន់ក្នុងការលើកកម្ពស់លទ្ធផល និងបច្ច័យនៃសកម្មភាពអប់រំ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ បានចូលរួមបញ្ចូលទាំងវិធានការកែលំអរថវិកាឱ្យមានប្រសិទ្ធភាព ប្រសើរជាងមុន (បង្កើនស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុនៅក្នុងសាលារៀន) និងការផ្សាភ្ជាប់ទំនាក់ទំនងលទ្ធផល និងធនធានហិរញ្ញវត្ថុ។ ការអនុវត្តក្រមសីលធម៏វិជ្ជាជីវៈគ្រូបង្រៀន ការអភិវឌ្ឍសម្ថភាពរបស់បុគ្គលិកនៅគ្រប់កម្រិត ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាពនិងស្តង់ដាច្បាស់លាស់ និងនាំមកនៅអភិបាលកិច្ចល្អ។ ដើម្បីគាំទ្រដល់សាលារផននិងបន្តអនុវត្តការពង្រឹងភាពជាដៃគូររវាងរដ្ឋាភិបាល សហគមន៏ មាតាបិតាសិស្ស ដៃគូអភិវឌ្ឍន៏វិស័យឯកជន និងបណ្តាលអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននិងផែនការប្រតិបត្តិប្រចាំឆ្នាំ ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹង

តម្រូវការអប់រំ និងដើម្បីបញ្ជាក់អោយបានច្បាស់លាស់នូវទំនាក់ទំនងរវាងគោលនបាយជាតិ និងគោលនយោបាយវិស័យអប់រំ។ ផែនការនេះបង្ហាញពីទំនាក់ទំនងពិតប្រាកដ រវាងគ្របខណ្ឌយុទ្ធសាស្ត្រ កម្មវិធីសកម្មភាពព្រមទាំងធនធានមនុស្សនិងហិរញ្ញវត្ថុ។ផែនការទាំងនេះក៏ជាផែនទីបង្ហាញផ្លូវអភិវឌ្ឍប្រកបដោយជីវភាពសម្រាប់ការអប់រំនៅកម្ពុជាឆ្នាំ២០៣០។ដូច្នេះនាយកសាលា មានតម្លាភាព គណនេយ្យភាព និងស្វ័យភាពលើដំណើរការបង្រៀន និងរៀន ពិសេសនាយកសាលាត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ស្របតាមស្តង់ដារនាយកល្អ ដើម្បីឱ្យដំណើរការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាពខ្ពស់។

ស្តង់ដារនាយកសាលាល្អទាំង៦គឺ៖

**ស្តង់ដារទី១៖** កម្រិតវប្បធម៌ និងបទពិសោធការងារ

**ស្តង់ដារទី២៖** សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន

**ស្តង់ដារទី៣៖** បំណិនត្រិះរិះពីចារណា និងនវានុវត្តន៍

**ស្តង់ដារទី៤៖** ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន

**ស្តង់ដារទី៥៖** ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន

**ស្តង់ដារទី៦៖** ការផ្សាភ្ជាប់សាលារៀន ទៅនឹងសហគមន៍

## ២.៤ សារៈសំខាន់ លើគណនេយ្យភាពនាយសាលា

គណនេយ្យភាពនាយកសាលា ពិតជាមានសារសំខាន់បំផុតក្នុងការធ្វើកំណែទម្រង់អបរំ និងកែលម្អសាលា។ ទោះបីជាសាលារៀនដែលស្ថិតនៅក្នុងស្រុកតែមួយ មានគ្រូដែលរៀនចប់ពីសាលាគរុកោសល្យតែមួយ ទទួលបានធនធានថវិការដូចគ្នា តែប្រសិទ្ធភាព និងលទ្ធផលសិក្សារបស់សាលារបស់សាលារៀនមិនដូចគ្នាទេ។ នាយកសាលាល្អ ពង្រឹងគុណភាពអប់រំ មានន័យថា បើសាលារៀនមួយល្អទៅបាន វាអាស្រ័យលើនាយក ជាអ្នកដឹកនាំល្អ។នាយកសាលា ដែលមានគណនេយ្យភាព គឺជានាយកសាលាដែលមានសមត្ថភាពក្នុងការដឹកនាំ និងគ្រប់គ្រង ហើយជាអ្នកដែលចេះកសាងផែនការអភិវឌ្ឍសាលារៀន។ ជាពិសេសសាលារៀនល្អ ត្រូវផ្តើមចេញពី ការរៀបចំផែនការអភិវឌ្ឍសាលារៀន ផែនការអភិវឌ្ឍសាលារៀន ត្រូវរៀបចំឡើងដោយមានការចូលរួមពីសំណាក់ គណៈគ្រប់គ្រងសាលា ប្រធានក្រុម

បច្ចេកទេស សាស្ត្រាចារ្យ មាតាបិតា សហគមន៍ ក្រុមប្រឹក្សាយុវជន និងអាជ្ញាធរដែលពាក់ព័ន្ធ។ផែនការនេះត្រូវកំណត់អាទិភាព កម្មវិធី និងផែនការសកម្មភាពឱ្យបានច្បាស់លាស់ ដែលគាំទ្រដោយធនធានមនុស្ស ធនធានថវិកា និងការគាំទ្រដោយដៃគូ។ការជួបជាមួយមាតាបិតា និងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន នៅក្នុងការគ្រប់គ្រងសាលារៀន និងការរៀបចំ អនុមតិ និងការអភិវឌ្ឍផែនការសាលារៀន ដោយផ្ទៀងផ្ទាត់ជាមួយលទ្ធផលសិក្សារបស់សិស្ស បានធ្វើឱ្យមានការផ្លាស់ប្តូរនូវវប្បធម៌ និងបរិយាកាសនៅក្នុងសាលារៀន គោលដៅនៃគម្រោងកែលម្អការអប់រំមធ្យមសិក្សា ទុតិយភូមិ។យើងឃើញថា ឥរិយាបថរបស់មាតាបិតាមានការប្រែប្រួល ទំនាក់ទំនងរវាងមាតាបិតាកាន់តែល្អ មាតាបិតាយកចិត្តទុកដាក់ជំពោះការមករៀនទៀងទាត់របស់ សិស្ស អាជ្ញាធរមូលដ្ឋាលក៏ចូលរួមយ៉ាងសកម្ម។

**២.៥ សរុប**

គណនេយ្យភាពនាយកសាលា គឺពិតជាបានដើរតួយ៉ាងសំខាន់ ក្នុងការពង្រឹងដល់គុណភាពអប់រំនៅតាមសាលារៀន។ សាលារៀនល្អ គឺជាសាលារៀនដែលមាន គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូគោរពនិងបំពេញនូវតួនាទី បានយ៉ាងពេញលេញនូវតម្លៃជាមូលដ្ឋាន មានបេសកម្មច្បាស់ កំណត់នូវលទ្ធផលខ្ពស់ ដែលគ្រូ និងសិស្ស សម្រេចឱ្យបាន ហើយនាយក គឺជាបុគ្គលដែលមានសម្ថភាព ខ្ពស់ក្នុងការដឹកនាំ និងគ្រប់គ្រង លើដំណើរការបង្រៀន ឱ្យមានប្របសិទ្ធភាព និងគុណភាពអប់រំខ្ពស់។លទ្ធផលសិក្សារបស់សិស្សល្អ ផ្អែកលើកត្តាធំៗ ចំនួន៤ គឺ៖**១)នាយកល្អ ២)គ្រូល្អ ៣)សិស្សល្អ ៤)មាតាបិតា និងសហគមន៍ល្អ** ។ដូច្នេះនាយកល្អ គឺជានាយកដែលមានគណនេយ្យភាព ស្វ័យភាព និងតម្លាភាព ក្នុងការដឹកនាំ និងគ្រប់គ្រង ហើយត្រូវចេះធ្វើផែនការអភិវឌ្ឍសាលារៀន។ការពង្រឹងគណនេយ្យភាពរបស់សាលារៀន គឺជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស។

# ជំពូក៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រតាមបែបចម្រុះ(បរិមានវិស័យ និងគុណវិស័យ)ដើម្បីឆ្លើយតបទៅតាមវត្ថុបំណង និងសំណួរខាងលើ ដែលបានកំណត់រួចនៅក្នុងជំពូក១។ ការស្រាវជ្រាវនេះប្រើកម្រងសំណួរដែលមានសំណួរបែបទម្រង់បិទ និងទម្រង់បើកដើម្បីប្រមូលទិន្នន័យពី នាយក នាយិកានៃវិទ្យាល័យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍ ដែលស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពី គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ តាមរយៈការគ្រប់គ្រងរបស់ខ្លួន និងរកឱ្យឃើញនូវលទ្ធផលជាចំនួនជាក់លាក់ ព្រមទាំងវិភាគឱ្យបានស៊ីជម្រៅពីចំណុចខ្លាំង ចំណុចប្រឈម និងគិតជាភាគរយតាមចំនួនពាក់ព័ន្ធនៃការអនុវត្តការងារបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពដើម្បីពង្រឹងគុណភាពអប់រំ។

## ៣.២ គម្រោងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានចាប់ផ្តើមចុះប្រមូលទិន្នន័យពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ ដោយយោងតាមលិខិតលេខ ២៣៤១ អយក.វជអ និង លិខិតឧទ្ទេសនាមលេខ២៤៥ អយក.ឧទន ចុះថ្ងៃទី២៩ ខែមេសាឆ្នាំ២០២២របស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៣.៣ វិធីសាស្ត្របែបបរិមានវិស័យ

ប្រើកម្រងសំណួរក្នុងការប្រមូលទិន្នន័យដោយរៀបចំកម្រងសំណួរជា៤ផ្នែក៖ ១)ព័ត៌មានទូទៅ ២) គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ៣)ការយល់ឃើញរបស់គ្រូចំពោះការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា ៤)បញ្ហាប្រឈមដែលជាឧបសគ្គក្នុងការដឹកនាំ និងគ្រប់គ្រងលើដំណើរការបង្រៀនរបស់គ្រូ។

### ៣.៤ វិធីសាស្ត្របែបគុណវិស័យ

ប្រើសំណួរសម្ភាសន៍ ពីអ្នកផ្តល់ទិន្នន័យរួមមានៈនាយកសាលាវិទ្យាល័យទាំង៥ និងលោកគ្រូអ្នកគ្រូ ចំនួន១០នាក់ ដើម្បីទទួលបាននូវទស្សនៈយល់ឃើញសំខាន់ៗ និងផ្ទៀងផ្ទាត់ខ្លឹមសារជាមួយកម្រងសំណួរ។

### ៣.៥ ការប្រមូលទិន្នន័យ

ដើម្បីប្រមូលទិន្នន័យឱ្យបានគ្រប់គ្រាន់ យើងបានអនុវត្តដំណើរតាមដំណាក់កាលនីមួយៗដោយយកលិខិតលេខ២៣៤១ អយក.វជអ និងលិខិតឧទ្ទេសនាមលេខ ២៤៦៥ អយក.ឧទន ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈវិទ្យាស្ថានជាតិអប់រំ (NIE) បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ សុំគោលការណ៍លោកប្រធានមន្ទីរអប់រំចេញលិខិតជម្រាបនាយកសាលាវិទ្យាល័យទាំង៥ ដែលស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងអង្គភាពពាក់ព័ន្ធតាមគោលដៅ។ យើងបានស្នើលិខិតអនុញ្ញាតពីមន្ទីរអប់រំ ជូននាយកសាលា ដើម្បីសុំការអនុញ្ញាតចុះប្រមូលទិន្នន័យដោយផ្ទាល់តាមសំណាកទាំងអស់ដែលត្រូវបំពេញកម្រងសំណួរ និងសំណួរសម្ភាសន៍ ព្រមទាំងពន្យល់ពីគោលបំណងរបស់ខ្លួននៃការចុះស្រាវជ្រាវ។

### ៣.៦ ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះ យើងប្រើកម្រងសំណួរដើម្បីប្រមូលទិន្នន័យតាមបែបបរិមានវិស័យ និងសំណួរសម្ភាសន៍តាមបែបគុណវិស័យ។កម្រងសំណួរទាំងអស់ ត្រូវបានបែងចែកសម្រាប់ នាយកសាលា គ្រូ និងសិស្សានុសិស្សៈ

**៣.៦.១. កម្រងសំណួរសម្រាប់នាយកសាលាៈ** កម្រងសំណួរសម្រាប់នាយកសាលាមានកម្រងសំណួរបិទ និងកម្រងសំណួរសម្ភាសន៍ ហើយត្រូវបានបែងចែកជា៤ផ្នែកៈ

**ផ្នែកទី១ៈ ព័ត៌មានទូទៅ** មាន៦សំណួរៈទាក់ទងទៅនឹងព័ត៌មានផ្ទាល់ខ្លួន ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ និងកម្រិតវដ្ឋាជីវៈ។

**ផ្នែកទី២៖ អំពីសាលា** មាន៤សំណួរៈ ទាក់ទងទៅនឹង ចំនួនសិស្ស អត្រាឡើងថ្នាក់ គិតជាភាគរយ (%) អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា។

**ផ្នែកទី៣៖ គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូៈ** មាន៩សំណួរ ទាក់ទងទៅនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការធ្វើផែនការ ការចុះអធិការកិច្ចតាមថ្នាក់រៀន ការបែងចែកភារកិច្ចដល់បុគ្គលិក ការបែងចែកសៀវភៅរដ្ឋបាល និងការតុបតែងថ្នាក់រៀនជាដើម។

**ផ្នែកទី៤៖ ការយល់របស់លោកនាយកសលា និងបញ្ហាប្រឈមនានា៖** មាន១០សំណួរដែលសំណួរទាំងអស់ ទាក់ទងទៅនឹងភាពទទួលខុសត្រូវ ក្នុងកាដឹកនាំ និងគ្រប់គ្រង លើដំណើរការបង្រៀនរបស់គ្រូ ការធ្វើផែនការសកម្មភាពប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ និងបញ្ហាប្រឈមនានា។

**៣.៦.២. កម្រងសំណួរសម្រាប់គ្រូ៖**កម្រងសំណួរសម្រាប់គ្រូ មានកម្រងសំណួរបិទ និងកម្រងសំណួរសម្ភាសន៍ ហើយមាន៣ផ្នែកគឺៈ

**ផ្នែកទី១៖ ព័ត៌មានទូទៅៈ**មាន៨សំណួរដែលទាក់ទងទៅនឹង មុខវិជ្ជាបង្រៀន ទីកន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ កម្រិតវជ្ជាជីវៈ និងបទពិសោធន៍ការងារ។

**ផ្នែកទី២៖ គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ** ក្នុងនេះដែរមានកម្រងសំណួរចំនួន ៩សំណួរ ដែលទាក់ទងនឹង សកម្មភាពផ្សេងៗរបស់នាយកសាលាលើដំណើរការបង្រៀនរបស់គ្រូ និងសិស្ស។

**ផ្នែកទី៣៖ ការយល់ឃើញរបស់គ្រូចំពោះការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាៈ** នៅក្នុងផ្នែកនេះដែរ មានកម្រងសំណួរសរុបចំនួន១០ ដែលទាក់ទងទៅនឹង ការយល់ឃើញរបស់លោកគ្រូ អ្នកគ្រូលើការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលានៅក្នុងអង្គភាពរបស់ខ្លួន។

**៣.៦.៣. កម្រងសំណួរសម្រាប់សិស្សៈ** កម្រងសំណួរសម្រាប់សិស្ស មានកម្រងសំណួរបិទ និងកម្រងសំណួរសម្ភាសន៍ ហើយចែកចេញជា២ផ្នែក៖

**ផ្នែកទី១៖** មាន៣សំណួរ ដែលទាក់ទងទៅនឹង ទីកន្លែងកំពុងរៀន ថ្នាក់រៀន ភេទ និងអាយុ។

**ផ្នែកទី២៖**មាន៥សំណួរ ដែលទាក់ទងទៅនឹងសកម្មភាពរបស់នាយកសាលា គ្រូបង្រៀន លទ្ធផលសិក្សារបស់សិស្ស និងវិន័យសាលា។

## ៣.៧ ការជ្រើសរើសសំណាក

ស្រុកមេមត់ ជាស្រុកដែលស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ ហើយមានវិទ្យាល័យចំនួន៥ គឺ៖ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន លាចលើ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្រែតានងកើត និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ដារ។ ក្នុងការចុះប្រមូលទិន្នន័យ នៅតាមវិទ្យាល័យគោលដៅខាងលើគឺ ចំនួនសំណាកដែលត្រូវប្រមូលទិន្នន័យនោះរួមមាន៖ នាយកសាលា គ្រូបង្រៀន និងសិស្សានុសិស្ស។

**តារាងទី១៖ចំនួនសំណាកប្រមូលទិន្នន័យពីនាយកសាលា**

| ល.រ | ឈ្មោះស្រុក | ឈ្មោះគ្រឹះស្ថាន | ចំនួន នាយក | ចំនួន គ្រូ | ចំនួន សិស្ស | សរុប |
|---|---|---|---|---|---|---|
| ១ | ស្រុកមេមត់ | វិ.ប.ន.ហ.ស.មេមត់<br>វិ.ប.ន.ហ.ស.ក្តុលផ្សារ<br>វិ.ប.ន.ហ.ស.លាចលើ<br>វិ.ប.ន.ហ.ស.ស្រែតានងកើត<br>វិ.ប.ន.ហ.ស.ដារ | ៥ | 52 | 250 | 307 |
| សរុប | ១ | ៥ | ៥ | 52 | 250 | 307 |

## ៣.៨ ការវិភាគទិន្នន័យ

វិធីសាស្ត្រនៃការវិភាគទិន្នន័យ គឺបកស្រាយតាមសំណួរស្រាវជ្រាវដែលបានកំណត់។

- ការបកស្រាយសំណួរទី១៖តើហេតុអ្វីបានជាគណនេយ្យភាពនាយកសាលាមានសារៈសំខាន់លើដំណើរការបង្រៀនរបស់គ្រូ ក្នុងការពង្រឹងនូវគុណភាពអប់រំ?

- ការបកស្រាយសំណួរទី២៖តើនាយកសាលាមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តគណនេយ្យភាពរបស់ខ្លួន លើដំណើរបង្រៀនរបស់គ្រូ?

ទិន្នន័យដែលប្រមូលបានពី នាយក លោកគ្រូ អ្នកគ្រូ និងសិស្ស តាមរយៈកម្រងសំណួរ ត្រូវបានធ្វើតាមប្រព័ន្ធកុំព្យូទ័រដោយប្រើកម្មវិធី Microsoft Excel ហើយធ្វើការបកស្រាយដោយប្រើកម្មវិធី Microsoft Word ដូចខាងក្រោម៖

- ការវិភាគតាមបរិមាណវិស័យ និងគុណវិស័យ (ការសិក្សាអង្គហេតុ case study ស្ថិតិប្រើតារាក្រាហ្វ បរិមាណវិស័យ Quantity)
- ពន្យល់លទ្ធផលបញ្ជាក់៖(គុណវិស័យ quality)

ការកំណត់ពិន្ទុលើតម្លៃមធ្យម គឺយកតាមលំនាំកម្រិតពិន្ទុ៖

- Mean =1.00 ដល់ 1.80 ខ្សោយណាស់
- Mean =1.81 ដល់ 2.60 ខ្សោយ
- Mean=2.61 ដល់ 3.40 មធ្យម
- Mean =3.41 ដល់ 4.20 ល្អ
- Mean=4.21 ដល់ 5.00 ល្អណាស់

## ៣.៩ ក្រមសីលធម៌នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ ក្នុងនាមខ្ញុំជាអ្នកស្រាវជ្រាវត្រូវតែយកចិត្តទុកដាក់ពីក្រមសីលធម៌នៃការស្រាវជ្រាវ ត្រូវរក្សាការសម្ងាត់នូវរាល់ចម្លើយ របស់អ្នកចូលរួម មាននាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្ស ដោយមិនប្រាប់ព័ត៌មាន អ្នកចូលរួមឡើយ។ក្រោយពីពេលស្រាវជ្រាវរួច អ្នកស្រាវជ្រាវត្រូវមានភាពស្មោះត្រង់ចំពោះការបញ្ចូលទិន្នន័យនូវចម្លើយអ្នកចូលរួម ដោយមិនបំផ្លើស និងបំពេញបន្ថែម លើចំណុចណាមួយឡើយ។ការធ្វើបែបនេះ ក្នុងនាមអ្នកស្រាវជ្រាវនឹងទទួលបាននូវភាពជឿទុកចិត្ត ហើយជាភស្តុតាងមួយ បញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យប្រកបដោយភាពត្រឹមត្រូវ សុច្ចរិតភាព និងក្រមសីលធម៌ខ្ពស់។

# ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ និងពិភាក្សា

ក្នុងជំពូក៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ និងធ្វើការបកស្រាយលទ្ធផល ពិភាក្សានូវអ្វីដែលបានរកឃើញ តាមរយៈការបំពេញកម្រងសំណួរ តាមបែប បរិមាណវិស័យ និងគុណវិស័យ លើក្រុមគោលដៅដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវរួមមាន៖ លោកនាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៃវិទ្យាល័យទាំង៥ គឺ៖ **វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនមេមត់ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនគុលផ្សារ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន លាចលើ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនស្រែតានងកើត និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនដារ**។ជំពូក៤នេះ នឹងបង្ហាញនូវចំណុចសំខាន់ៗ ដែលបានចោទសួរក្នុងសំណួរស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទ៖**គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**។ ការបកស្រាយ និងការពិភាក្សាទៅលើទិន្នន័យដែលទទួលបាននេះ គឺលើកយកមកវិភាគ និងសំយោគទៅតាមគោលបំណងនៃការស្រាវជ្រាវចំនួន២(ពីរ)គឺ៖១)ដើម្បីសិក្សាស្រាវជ្រាវពីគណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។២) ដើម្បីសិក្សាស្រាវជ្រាវពីបញ្ហាប្រឈម និងដំណោះស្រាយពីគណនេយ្យភាពរបស់នាយកសាលា លើដំណើរការបង្រៀនរបស់គ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

## ៤.១ ព័ត៌មានទូទៅនៃសំណាក

នៅក្នុងជំពូក៤នេះ អ្នកសិក្សាស្រាវជ្រាវបានកំណត់បង្ហាញព័ត៌មានទូទៅនៃសំណាកដែលចូលរួមការសិក្សាស្រាវជ្រាវតាមបែប បរិមាណវិស័យ និងគុណវិស័យ។អ្នកចូលរួមសំណាកទាំងអស់រួមមាន៖ នាយកសាលា ៥នាក់ លោកគ្រូ អ្នកគ្រូ ៥២នាក់និងសិស្សានុសិស្ស ចំនួន២៥០ នាក់ ដោយមានព័ត៌មានលម្អិតពីកម្រិតថ្នាក់ ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារក្នុងការដឹកនាំគ្រប់គ្រង និងការងារបង្រៀន និងរៀន ដែលមានបង្ហាញជូននូវផ្នែកនីមួយៗខាងក្រោមនេះ៖

តារាងទី១៖ *ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ*

| អ្នកចូលរួមឆ្លើយ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| នាយកសាលា | ៥ | ០ | ៥ |
| គ្រូបង្រៀន | ៤១ | ១១ | ៥២ |
| សិស្ស | ៨៩ | ១៦១ | ២៥០ |
| សរុប | ១៣៥ | ១៧២ | ៣០៧ |

### ៤.១.១ ព័ត៌មានទូទៅរបស់នាយកសាលា

តាមរយៈការជ្រើសរើសសំណាកយកមកសិក្សាស្រាវជ្រាវ លើប្រធានបទ៖ (**គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**) ក្នុងករណីសិក្សាស្រាវជ្រាវនេះដែរ មាននាយកចូលរួមចំនួន៥ រូប ត្រូវបានជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងជំពូក៣។យោងតាមទិន្នន័យដែលទទួលបានពីនាយកសាលា នៃវិទ្យាល័យទាំង៥ដែលស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំបានឱ្យដឹងថានាយកសាលាទាំង៥ សុទ្ធតែភេទ ប្រុសដែលប្រកបអាជីបជាគ្រូបង្រៀនមានបទពិសោធន៍ការងារច្រើនឆ្នាំ។នាយកសាលាចំនួនន ៤នាក់មានបទពិសោធន៍ការងារចន្លោះពី ២០ ដល់ ២៥ឆ្នាំ ៨០% ហើយមាននាយកសាលា១នាក់ដែលមានបទពិសោធន៍ចន្លោះពី ១៦ ដល់ ២០ ឆ្នាំ ស្មើនឹង ២០%។នាយកសាលាទាំងអស់មានបទពិសោធន៍ការងារជានាយកចន្លោះពី ១១ ដល់១៥ ឆ្នាំដូចគ្នាស្មើនឹង ១០០%។នាយក៤រូបមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ស្មើនឹង៨០% ហើយនាយក១រូបទៀតមានកម្រិតវប្បធម៌ បរិញ្ញាបត្រជាន់ខ្ពស់ ស្មើនឹង២០% ។នាយកមានកម្រិតវិជ្ជាជីវៈគ្រូកម្រិតឧត្តម មានចំនួន ៣នាក់ ស្មើនឹង ៦០% និងគ្រូកម្រិតមូលដ្ឋាន មានចំនួន២នាក់ស្មើនឹង ៤០%។នាយកសាលា ៤នាក់ដែលមានអាយុចន្លោះពី ៤០ ដល់ ៥០ឆ្នាំ ស្មើនឹង ៨០% ហើយមាននយក១នាក់ដែលមានអាយុលើសពី ៥០ឆ្នាំ ស្មើនឹង២០%។

តារាងទី ២៖ *ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន*

| ល.រ | បរិយាយ | | សរុប | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | បទពិសោធន៍ជាគណៈគ្រប់គ្រង | ១ ទៅ ៥ឆ្នាំ | ០ | ០% |
| | | ៦ ទៅ ១០ឆ្នាំ | ០ | ០% |
| | | ១១ ទៅ ១៥ឆ្នាំ | ០ | ០% |
| | | លើសពី ១៥ឆ្នាំ | ៥ | ១០០% |
| | | សរុប | ៥ | ១០០% |
| ២ | ភេទ | ប្រុស | ៥ | ១០០% |
| | | ស្រី | ០ | ០% |
| | | សរុប | ៥ | ១០០% |
| ៣ | អាយុ | ២០ ទៅ ៣០ឆ្នាំ | ០ | ០% |
| | | ៣១ ទៅ ៤០ឆ្នាំ | ០ | ០% |
| | | ៤១ ទៅ ៥០ឆ្នាំ | ៤ | ៨០% |
| | | ៥១ ទៅ ៦០ឆ្នាំ | ១ | ២០% |
| | | សរុប | ៥ | ១០០% |
| ៤ | កម្រិតវប្បធម៌ | បរិញ្ញាបត្រ | ៤ | ៨០% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | ១ | ២០% |
| | | បណ្ឌិត | ០ | ០% |
| | | សរុប | ៥ | ១០០% |

### ៤.១.២ ព័ត៌មានទូទៅរបស់គ្រូបង្រៀន

ទាក់ទងទៅនឹងប្រធានបទដែលអ្នកសិក្សាស្រាវជ្រាវកំពុងលើកយកមកសិក្សា គឺផ្តោតសំខាន់លើភាពទទួលខុសត្រូវរបស់នាយកសាលា ក្នុងការការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនលើដំណើរបង្រៀន និងរៀននៅតាមអង្គភាពនីមួយ តាមតយៈការវាយតម្លៃរបស់គ្រូបង្រៀនលើសកម្មភាពគ្រប់គ្រង និងដឹកនាំរបស់នាយកសាលាម្នាក់ៗ។ក្នុងករណីសិក្សាស្រាវជ្រាវនេះ ចំនួនសំណាកដែលបានមកពីសាលាវិទ្យាល័យទាំង៥ មានលោកគ្រូ អ្នកគ្រូចូលរួមសរុបចំនួន ៥២នាក់។តាមទិន្នន័យដែលទទួលបានពីគ្រូបង្រៀនសរុបចំនួន៥២នាក់ គ្រូបង្រៀនជាបុរសមានចំនួន ៤១នាក់ ស្មើនឹង ៧៨.៨៤% គ្រូបង្រៀនជាស្រីមានចំនួន ១១នាក់ស្មើនឹង២១.១៦%។គ្រូបង្រៀនដែលមានអាយុ ក្រោម៤០ឆ្នាំ មានចំនួន ៣៦នាក់ស្មើនឹង ៦៩.២៣% គ្រូបង្រៀនមានអាយុចន្លោះពី៤០ ដល់ ៤៩ មាន១៣នាក់ ស្មើនឹង ២៥% និងគ្រូបង្រៀនដែលមានអាយុលើសពី៥០ឆ្នាំ មានចំនួន ៣នាក់ ស្មើនឹង៥.៧៦%។

តារាងទី៣៖ ***ព័ត៌មានទូទៅរបស់គ្រូបង្រៀន***

| ល.រ | បរិយាយ | | សរុប | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | គ្រូបង្រៀន | ថ្នាក់ទី១០ | N/A | N/A |
| | | ថ្នាក់ទី១១ | N/A | N/A |
| | | ថ្នាក់ទី១២ | N/A | N/A |
| | | សរុប | N/A | N/A |
| ២ | ភេទ | ប្រុស | ៤១ | ៧៨.៨៤% |
| | | ស្រី | ១១ | ២១.១៦ |
| | | សរុប | ៥២ | ១០០% |
| ៣ | អាយុ | ២០ ទៅ ៣០ឆ្នាំ | 0 | 0% |

| | | | | |
|---|---|---|---|---|
| | | ៣១ ទៅ ៤០ឆ្នាំ | ៣៦ | ៦៩.២៣% |
| | | ៤១ ទៅ ៥០ឆ្នាំ | ១៣ | ២៥% |
| | | ៥១ ទៅ ៦០ឆ្នាំ | ៣ | ៥.៧៦% |
| | | សរុប | ៥២ | ១00% |
| ៤ | កម្រិតវប្បធម៌ | បរិញ្ញាបត្រ | ៥២ | ១00% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 0 | 0% |
| | | បណ្ឌិត | 0 | 0% |
| | | សរុប | ៥២ | ១00% |
| ៥ | បទពិសោធន៍បង្រៀន | ១ ទៅ ៥ឆ្នាំ | 0 | 0% |
| | | ៦ ទៅ ១0ឆ្នាំ | | |
| | | ១១ ទៅ ១៥ឆ្នាំ | | |
| | | លើសពី ១៥ឆ្នាំ | | |
| | | សរុប | | |

### ៤.១.៣ ព័ត៌មានទូទៅរបស់សិស្ស

តាមទិន្នន័យទទួលបានពីសិស្សានុសិស្សទាំងអស់ដែលកំពុងសិក្សានៅថ្នាក់ទី ១០ ១១ ១២ មានចំនួន ២៥០នាក់ នៃវិទ្យាល័យទាំង៥។តាមទិន្នន័យបានបង្ហាញថា សិស្សប្រុសមានចំនួន ៨៩នាក់ ស្មើនឹង ៣៥.៦% សិស្សស្រីសរុប ១៦១នាក់ ស្មើនឹង ៦៤.៤%។សិស្សមានអាយុចន្លោះពី ១៥ដល់ ១៧ឆ្នាំ មានចំនួន ១២៦នាក់ ស្មើនឹង ៥0.៤% សិស្សមានអាយុលើសពី១៧ឆ្នាំមានចំនួន ១២៤នាក់ ស្មើនឹង ៤៩.៦%។

តារាងទី៤៖ ***ព័ត៌មានទូទៅរបស់សិស្ស***

| ល.រ | បរិយាយ | | សរុប | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | សិស្ស | ថ្នាក់ទី១០ | ១០០ | ៤០% |
| | | ថ្នាក់ទី១១ | ១០០ | ៤០% |
| | | ថ្នាក់ទី១២ | ៥០ | ២០% |
| | | សរុប | ២៥០ | ១០០% |
| ២ | ភេទ | ប្រុស | ៨៩ | ៣៥.៦% |
| | | ស្រី | ១៦១ | ៦៤.៦% |
| | | សរុប | ២៥០ | ១០០% |
| ៣ | អាយុ | ១០ ទៅ ១៥ឆ្នាំ | 0.00 | 0.00% |
| | | ១៥ ទៅ ២០ឆ្នាំ | ១២៦ | ៥០.៤% |
| | | ២០ ទៅ ២៥ឆ្នាំ | ១២៤ | ៤៩.៦% |
| | | លើសពី២៥ឆ្នាំ | 0.00 | 0.00% |
| | | សរុប | ២៥០ | ១០០% |

## ៤.២ ព័ត៌មានទូទៅអំពីសាលារៀនទាំង៥

យោងតាមទិន្នន័យ ដែលប្រមូលបានពីនាយកសាលាទាំង៥ បានបង្ហាញថា៖វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ (២០២១- ២០២២) មានសិស្សសរុប ៣១៧០នាក់ សិស្សស្រី ១៧៣២នាក់ ស្មើនឹង ៥៤.៦៣% នៃសិស្សប្រុស គ្រូបង្រៀនសរុប ១១៥នាក់ ស្រី ៤៤នាក់ ស្មើនឹង ៣៨.២៦% នៃគ្រូបង្រៀនប្រុស។ អត្រាបោះបងការសិក្សា មាន ៦.៧៥% អត្រាត្រួតថ្នាក់មាន ៤.៥០% និងអត្រាឡើងថ្នាក់មាន ចំនួន ៨៨.៧៥%។វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនដារ (២០២១- ២០២២)មានសិស្សសរុប ៨៦៩នាក់

សិស្សស្រីសរុប ៤៦២នាក់ ស្មើនឹង ៥៣.១៤% នៃសិស្សប្រុស គ្រូបង្រៀនមានចំនួន ៤៤នាក់ គ្រូបង្រៀនស្រី ១៩នាក់ ស្មើនឹង ៤៣.១៨% នៃគ្រូបង្រៀនប្រុស។អត្រាសិស្សបោះបង់ការសិក្សាមានចំនួន ១០% អត្រាត្រួតថ្នាក់មានប្រមាណ ២% និងអត្រាឡើងថ្នាក់មានចំនួន ៨៨%។វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្រែតានងកើត (២០២១-២០២២) មានសិស្សសរុប ៤៥៣នាក់ សិស្សស្រី មានចំនួន ២៤៧នាក់ ស្មើនឹង ៥៤.៥២% នៃសិស្សប្រុស គ្រូបង្រៀនមានចំនួន ១៥នាក់ ស្រី៤នាក់ ស្មើនឹង ២៦.៦៦%នៃគ្រូបង្រៀនប្រុស។អត្រាបោះបង់ការសិក្សា មាន១០.៥% អត្រាត្រួតថ្នាក់មានចំនួន ៩.៧១% អត្រាឡើងថ្នាក់មានចំនួន ៧៩.៧៩%។វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន លាចលើ (២០២១ -២០២២) មានសិស្សសរុប ៦៥១នាក់ សិស្សស្រី ៣២៦នាក់ ស្មើនឹង ៥០.០៧% នៃសិស្សប្រុស គ្រូបង្រៀនមានចំនួន ០៩នាក់គ្រូបង្រៀនស្រីមានចំនួន ០១នាក់។ អត្រាសិស្សបោះបង់ការសិក្សា មាន ចំនួន ៥% អត្រាត្រួតថ្នាក់មានចំនួន ០% អត្រាឡើងថ្នាក់មានចំនួន ៩៥%។ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ (២០២១ ដល់ ២០២២) មានសិស្សសរុបចំនួន ៧៣៤នាក់ សិស្សស្រីមាន ៤០៤នាក់ស្មើនឹង
៥៥.០៤% នៃសិស្សប្រុស គ្រូបង្រៀនមានចំនួន២៩នាក់ គ្រូបង្រៀនស្រីមានចំនួន ០៦នាក់ស្មើនឹង ២០.៦៨%។អត្រាបោះបង់ការសិក្សា មាន៤.៤៩% អត្រាត្រួតថ្នាក់មានចំនួន ៩.១៤% និងអត្រាឡើងថ្នាក់មានចំនួន ៨៦.០៤%។

## ៤.៣ គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ

គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ គឺផ្តោតសំខាន់លើការអនុវត្តការងារ (*តួនាទី ភារកិច្ច ការដឹកនាំ និងការគ្រប់គ្រង*)របស់នាយកសាលាគ្រប់រូប ពិសេសត្រូវយកចិត្តទុកដាក់លើការបំពេញនូវ តួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយស្របតាមស្តង់ដារនាយកល្អត្រង់ចំណុចទី៥ ឬ**ស្តង់ដារទី៥៖ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន** ដើម្បីអោយដំណើរការបង្រៀន និងរៀននៅអង្គភាពរបស់ខ្លួន ប្រកបដោយគុណភាពអប់រំ និងមានប្រសិទ្ធភាពខ្ពស់។ តារាងទិន្នន័យបានបង្ហាញថា៖

តារាងទី៥៖ *គណនេយ្យភាពនាយសាលា លើដំណើរការបង្រៀនរបស់គ្រូ*

| ល.រ | បរិយាយ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតបកស្រាយ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតបកស្រាយ |
| ១ | តើនាយករបស់លោកគ្រូអ្នកគ្រូ ធ្លាប់បានការរៀបចំប្រជុំក្រុម បច្ចេកទេសទាក់ទងនិងវិធីសាស្ត្របង្រៀនដែរឬទេ ? | 3.52 | 0.50 | ល្អ | 4.00 | 0.00 | ល្អ |
| ២ | តើលោកនាយករបស់លោកគ្រូ អ្នកគ្រូ បានចុះអធិការកិច្ច អចិន្ត្រៃយ៍តាមថ្នាក់រៀនជាប្រចាំ ដែរឬទេកន្លងមក? | 3.13 | 0.34 | មធ្យម | 4.00 | 0.00 | ល្អ |
| ៣ | តើនាយកសាលារបស់លោកគ្រូ អ្នកគ្រូ បានបំប៉នវិធីសាស្ត្រនិង ផ្តល់ប្រឹក្សាបច្ចេកទេសដល់ លោកគ្រូ អ្នកគ្រូដែរឬទេ? | 2.98 | 0.37 | ខ្សោយ | 3.00 | 0.00 | មធ្យម |
| ៤ | តើលោកគ្រូ អ្នកគ្រូ បានធ្វើកិច្ច តែងការបង្រៀន ដែរឬទេ មុននឹងដំណើរការបង្រៀនរបស់ លោកគ្រូ អ្នកគ្រូ? | 3.12 | 0.32 | មធ្យម | 3.40 | 0.55 | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | តើការធ្វើរដ្ឋបាលថ្នាក់រៀន មុនដំណើរការបង្រៀន មានសារៈសំខាន់ដែរឬទេ? | 3.96 | 0.19 | ល្អ | 3.80 | 0.45 | ល្អ |
| ៦ | តើនាយកសាលារបស់ លោកគ្រូអ្នកគ្រូ បានបែងចែកសេវាម៉ោងបង្រៀនទៅតាមសមត្ថភាព និងឯកទេសបានត្រឹមត្រូវ ដែរឬទេ? | 3.77 | 0.43 | ល្អ | 4.00 | 0.00 | ល្អ |
| ៧ | តើនាយកសាលា របស់លោកគ្រូអ្នកគ្រូ បានត្រួតពិនិត្យ និងវាយតម្លៃការបង្រៀន និងរៀនជាប្រចាំដែរឬទេ? | 3.31 | 0.47 | ល្អ | 3.60 | 0.55 | ល្អ |
| ៨ | តើសាលារៀន របស់លោកគ្រូអ្នកគ្រូ មានការចូលរួមគាំទ្រពីសហគមន៍ ឬសាធារណៈជនកម្រិតណាដែរ?ចូរពន្យល់? | 3.08 | 0.27 | មធ្យម | 3.00 | 0.00 | មធ្យម |
| ៩ | តើនៅសាលារៀនរបស់លោកគ្រូអ្នកគ្រូ មានទទួលចំណាត់ថ្នាក់សាលារៀនល្អ ឬទទួលប័ណ្ណសរសើរពីថ្នាក់ដឹកនាំដែរឬទេ? | 3.06 | 0.42 | មធ្យម | 3.00 | 0.00 | មធ្យម |
| សរុប | | **3.74** | **0.37** | **ល្អ** | **3.98** | **0.17** | **ល្អ** |

**តាមតារាងទី៥៖** ខាងលើបានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **គណនេយ្យភាពនាយសាលា លើដំណើរការបង្រៀនរបស់គ្រូ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៧៤)

។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "ការធ្វើរដ្ឋបាលថ្នាក់រៀន មុននឹងដំណើរបង្រៀន "ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៩៦)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "នាយក នាយិកា បានបំប៉នវិធីសាស្រ្តបង្រៀន និងប្រឹក្សាបច្ចេកទេស ដល់លោកគ្រូ អ្នកគ្រូ" ក្នុងកម្រិត "ខ្សោយ" (មធ្យមភាគពិន្ទុ=២.៩៨)។

គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុប ក្នុងកម្រិត"ល្អ" (មធ្យមភាគពិន្ទុ=៣.៩៨)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "ការរៀបចំប្រជុំក្រុមបច្ចេកទេស ទាក់ទងនឹងវិធីសាស្រ្តបង្រៀន ការធ្វើអធិការកិច្ចអចិន្រ្តៃយ៍ នៅតាមថ្នាក់រៀន និងការបែងចែកសេវាម៉ោងបង្រៀនបានត្រឹមត្រូវ ទៅតាមសមត្ថភាព និងឯកទេស" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.០០)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "ការបំប៉នវិធីសាស្រ្តបង្រៀន និងផ្តល់ប្រឹក្សាបច្ចេកទេស ដល់លោកគ្រូ អ្នកគ្រូ ការចូលរួមគាំទ្រពីសហគមន៍ និងការទទួលបានប័ណ្ណសរសើរពីថ្នាក់ដឹកនាំ ជាសាលារៀនល្អ " ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.០០)។

តារាងទី៦ ៖ ***ទស្សនៈរបស់លោកគ្រូ អ្នកគ្រូ ចំពោះការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា***

| ល.រ | បរិយាយ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដារ | កម្រិតបង្ហាញលទ្ធផល | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដារ | កម្រិតបង្ហាញលទ្ធផល |
| ១ | តើនាយកសាលារបស់លោកគ្រូ អ្នកគ្រូ មានតម្លាភាពក្នុងការអនុវត្តផែនការសាលារៀនកម្រិតណាដែរ ? | 3.60 | 0.50 | ល្អ | 4.00 | 0.00 | ល្អ |
| ២ | តើលោកនាយកសាលា របស់លោកគ្រូ អ្នកគ្រូ មានចំណាត់ការ យ៉ាងដូចម្តេច ចំពោះបុគ្គលិកដែល | 3.27 | 0.45 | មធ្យម | 4.00 | 0.00 | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | អសកម្ម ? | | | | | | |
| ៣ | តើនាយកសាលា របស់លោកគ្រូ អ្នកគ្រូ បានអនុវត្តច្បាប់យ៉ាងដូចម្ដេចចំពោះសិស្សអវត្តមានច្រើនដង ? | 3.33 | 0.47 | មធ្យម | 4.00 | 0.00 | ល្អ |
| ៤ | តើនាយកសាលារបស់ លោក លោកស្រីមានការលើកទឹកចិត្តដល់បុគ្គលិកដែលសកម្មដែរឬទេ ? | 3.94 | 0.24 | ល្អ | 4.00 | 0.00 | ល្អ |
| ៥ | តើនាយក នាយិកា របស់លោកគ្រូ អ្នកគ្រូបានធ្វើផែនការអភិវឌ្ឍសាលារៀនដែរឬទេ ? | 3.27 | 0.45 | មធ្យម | 3.80 | 0.45 | ល្អ |
| ៦ | តើលោកគ្រូ  យល់ឃើញយ៉ាងដូចម្ដេចខ្លះ ចំពោះនាយកសាលាដែលគ្មានទំនួលខុសត្រូវចំពោះតួនាទីរបស់ខ្លួន ? | 2.00 | 0.00 | ខ្សោយ | 3.60 | 0.55 | ល្អ |
| ៧ | តើលោកគ្រូ អ្នកគ្រូ ចង់បាននាយកសាលា ដែលមានគណនេយ្យភាព ស្វ័យភាព និងតម្លាភាពដែរឬទេ ? | 4.00 | 0.00 | ល្អ | 4.00 | 0.00 | ល្អ |
| ៨ | តើការដឹកនាំ និងគ្រប់គ្រង លើដំណើរការបង្រៀន និងរៀននៅក្នុងសាលារបស់លោកគ្រូ អ្នកគ្រូ បានល្អកម្រិតណាដែរ ? | 3.87 | 0.34 | ល្អ | 4.00 | 0.00 | ល្អ |
| ៩ | តើលោកគ្រូ អ្នកគ្រូ បានជួបបញ្ហាប្រឈមអ្វីខ្លះក្នុងដំណើរការបង្រៀន | 3.00 | 0.00 | មធ្យម | 3.00 | 0.00 | មធ្យម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | នៅក្នុងអង្គភាពរបស់លោកគ្រូ អ្នកគ្រូ? | | | | | | |
| ១០ | តើលោកគ្រូ អ្នកគ្រូ មានសំណូមពរអ្វីខ្លះដល់ថ្នាក់ដឹកនាំ ក្រសួងអប់រំ មន្ទីរអប់រំដើម្បីធ្វើឱ្យដំណើរការបង្រៀន និងរៀននៅសាលារបស់លោកគ្រូ អ្នកគ្រូ ទទួលបានប្រសិទ្ធភាពខ្ពស់? | 3.46 | 0.50 | ល្អ | 4.00 | 0.00 | ល្អ |
| **សរុប** | | **3.37** | **0.29** | **ល្អ** | **3.84** | **0.10** | **ល្អ** |

**តាមតារាងទី៦៖** ខាងលើបានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ទស្សនរបស់គ្រូ ចំពោះការអនុវត្តគណនេយ្យភាព លើដំណើរការបង្រៀនរបស់គ្រូ** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.២២)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "លោកគ្រូ អ្នកគ្រូ ចង់បាននាយក នាយិកាសាលារៀន ដែលមានគណនេយ្យភាព ស្វ័យភាព និងតម្លាភាព"ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០០)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "នាយក ដែលគ្មានភាពទទួលខុសត្រូវក្នុងការបំពេញនូវភារកិច្ច និងតួនាទីរបស់ខ្លួនក្នុងការដឹកនាំ និងគ្រប់គ្រង" ក្នុងកម្រិត "ខ្សោយ" (មធ្យមភាគពិន្ទុ=២.០០)។ គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុប ក្នុងកម្រិត"ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៨០)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "សូចនាករទី១ សូចនាករទី២ សូចនាករទី៣ សូចនាករទី៤ សូចនាករទី៧ សូចនាករទី៨ និងសូចនាករទី១០" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.០០)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "ការជួបនូវបញ្ហាប្រឈមផ្សេងៗ ក្នុងដំណើរការបង្រៀន របស់លោកគ្រូ អ្នកគ្រូនៅតាមអង្គភាព" ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.០០)។តាមរយៈតារាង ៤.១ តារា៤.២ និង តារាង ៤.៣ ការវិភាគទិន្នន័យខាងលើបានបង្ហាញថា៖នាយកសាលាទាំង៥ មានគណនេយ្យភាពល្អ ក្នុងកម្រិត (មធ្យមភាគ ៣.៧៤ និង៤.២២) ក្នុងការដឹកនាំ និងគ្រប់គ្រង លើដំណើរការបង្រៀនរបស់គ្រូ និងរៀន

នៅតាមអង្គភាពនីមួយៗ។លទ្ធផលនៃការវិភាគទិន្នន័យ ទាំងនេះបានមកពីកម្រងសំណួរបិទ និងកម្រងសំណួរសម្ភាសន៍របស់នាយកសាលា និងគ្រូបង្រៀនតាមសាលាវិទ្យាល័យទាំង៥។ចំពោះគ្រូបង្រៀន ក៏បានបំពេញតួនាទី និងភារកិច្ចបានក្នុងកម្រិតល្អដែរ គឺមធ្យមភាគ ៣.៩៧ និង ៤.៨០)។ទិន្នន័យទាំងនេះទទួលបានពីកម្រងសំណួរបិទ និងកម្រងសំណួរសម្ភាសន៍រវាងនាយកសាលា និងគ្រូបង្រៀននៅតាមវិទ្យាល័យ ទាំង៥។

## ៤.៤ បញ្ហាប្រឈមនានា ក្នុងការអនុវត្ត គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ

ភាពទទួលខុសត្រូវរបស់នាយកសាលា ពិតជាដើរតួយ៉ាងសំខាន់ក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀន ពីព្រោះវាធ្វើឱ្យដំណើរការបង្រៀន និងរៀនមានប្រសិទ្ធភាព ហើយជួយពង្រឹងដល់គុណភាពអប់រំផងដែរ។ទន្ទឹមនឹងនេះដែរ នាយកសាលាគ្រប់រូប តែងតែជួបប្រទះនូវបញ្ហាប្រឈមនានាក្នុងការបំពេញនូវ តួនាទី និងភារកិច្ចរបស់ខ្លួន។ឆ្លងតាមរយៈកម្រងសំណួរ និងកម្រងសំណួរសម្ភាសន៍របស់លោកនាយកសាលាទាំង៥បានបង្ហាញថា៖ នាយកសាលាមានបញ្ហាប្រឈមដូចខាងក្រោម៖

### ៤.៤.១ បញ្ហាប្រឈមរបស់នាយក លើកដំណើរការបង្រៀនរបស់គ្រូ

ឆ្លងតាមការចុះប្រមូលទិន្នន័យផ្ទាល់ តាមរយៈកម្រងសំណួរបិទ និងកម្រងសំណួរ សម្ភាសន៍ជាមួយលោកនាយកសាលា គ្រូបង្រៀន និងសិស្សានុសិស្ស បានបង្ហាញថា៖សាលាវិទ្យាល័យតាំង៥សុទ្ធតែមានបញ្ហាប្រឈម ក្នុងការអនុវត្តនូវគណនេយ្យភាពរបស់ខ្លួន។ តាមរយៈការចុះសម្ភាសន៍ផ្ទាល់ជាមួយលោកនាយកសាលា ទាំង៥ ចំពោះការអនុវត្តនូវគណនេយ្យភាពលើដំណើរបង្រៀន បានបង្ហាញថាៈនាយកសាលា ទាំងអស់មាន មានបញ្ហាប្រឈមមួយចំនួន៖P#1« *គ្រូបង្រៀនមួយចំនួនមិនគោរពវិន័យ ដែលបង្កឱ្យមានការលំបាកដល់ដំណើរបង្រៀន និងរៀនមិនចូលរួមធ្វើការងារបរិស្ថាន និងបំពេញការងារមិនបានល្អ ដែលជាហេតុ បង្កឱ្យមានភាពអសកម្មខ្លះៗក្នុង ដំណើរបង្រៀន និងរៀន នៅអង្គភាពរបស់គាត់» ។*

P#2« *បញ្ហាប្រឈមសម្រាប់សាលារៀនខ្ញុំរបស់គឺៈ ខ្វះគ្រូបង្រៀន នាយកបង្រៀនច្រើនម៉ោងដែរ គ្រូបង្រៀនឯកទេសមកហើយ ផ្ទេរចេញទៅវិញ ដោយមូលហេតុ សហព័ន្ធ ខ្វះអាគារសិក្សា ។*

P#3« *បញ្ហាប្រឈមសម្រាប់សាលារៀនរបស់ខ្ញុំគឺៈខ្វះគ្រូឯកទេស គ្រូមួយចំនួន បំពេញភារកិច្ចមិនបានល្អ សិស្សមួយចំនួន ឡើងមកពីថ្នាក់ក្រោម មិនសូវចេះ»។*

P#4 «*បញ្ហាប្រឈមសម្រាប់សាលារៀនរបស់ខ្ញុំគឺៈបុគ្គលិកមួយចំនួន អសកម្មបំពេញការងារមិនបានល្អ ហើយតែងតែយកមូលហេតុផ្សេងៗដាក់មុខ ពិសេស ការបំពេញភារកិច្ចមិនស្មើដៃគ្នា»។*

P#5 «*បញ្ហាប្រឈមនៅក្នុងសាលារៀនខ្ញុំគឺៈសាលារៀនរបស់ខ្ញុំ ខ្វះគ្រូបង្រៀនឯកទេស (គីមី ជីវៈ បំណិនជីវិត) និងខ្វះសៀវភៅសិក្សាគោល។*

ដើម្បីឆ្លើយតមទៅនឹងបញ្ហាប្រឈមខាងលើ ការសិក្សាស្រាវជ្រាវ សូមសំណូមពរមួយចំនួនៈ (១)ក្រសួងអប់រំ គួរតែផ្តល់គ្រូឯកទេសដល់សាលាណា ដែលមានតម្រូវការ (២) ក្រសួង អប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ ចុះអធិការកិច្ចតាមសាលារៀន (៣)ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យ អប់រំស្រុក អាជ្ញាធរដែនដី និងអង្គភាពពាក់ព័ន្ធ ចូលរួមសហការ គាំទ្រ ដល់ការគ្រប់គ្រងសាលារៀន ឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព ដើម្បីឆ្លើយតបទៅនឹង គោលនយោបាយអប់រំ និងតម្រូវការមូលដ្ឋាន។

**តារាងទី៧ៈបញ្ហាប្រឈមរបស់នាកសាលា លើដំណើរការបង្រៀនរបស់គ្រូ**

| ល.រ | បរិយាយ | គ្រូបង្រៀន | | |
|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | តើគ្រូបង្រៀន នៅក្នុងអង្គភាពលោកនាយក បានបំពេញ តួនាទី និងភារកិច្ច កម្រិតណាដែរ? | 4.00 | 0.00 | 5 |
| ២ | តើលោកនាយកមានបញ្ហាប្រឈម ក្នុងការដឹកនាំ និងគ្រប់គ្រង | 4.00 | 0.00 | 5 |

| | | | | |
|---|---|---|---|---|
| | នៅក្នុងអង្គភាពកម្រិតណាដែរ ? | | | |
| ៣ | តើលោកនាយកមានសំណូមពរដល់ ថ្នាក់ដឹកនាំ ក្រសួងអប់រំ មន្ទីរ និងការិយាល័យអប់រំស្រុកនិងអង្គភាពដែលពាក់ព័ន្ធកម្រិតណាដែរ ? | 4.80 | 0.45 | 5 |
| សរុប | | 1.60 | 0.15 | 5 |

តាមរយៈការចុះសម្ភាសន៍ផ្ទាល់ជាមួយលោកនាយកសាលា ទាំង៥ ចំពោះការអនុវត្តនូវគណនេយ្យភាពលើដំណើរបង្រៀន បានបង្ហាញថា:នាយកសាលា ទាំងអស់មាន មានបញ្ហាប្រឈមមួយចំនួន៖P#1« *គ្រូបង្រៀនមួយចំនួនមិនគោរពវិន័យ ដែលបង្កឱ្យមានការលំបាកដល់ដំណើរបង្រៀន និងរៀនមិនចូលរួមធ្វើការងារបរិស្ថាន និងបំពេញការងារមិនបានល្អ ដែលជាហេតុ បង្កឱ្យមានភាពអសកម្មខ្លះៗក្នុង ដំណើរបង្រៀន និងរៀន នៅអង្គភាពរបស់គាត់» ។*

P#2« *បញ្ហាប្រឈមសម្រាប់សាលារៀនខ្ញុំរបស់គឺ៖ ខ្វះគ្រូបង្រៀន នាយកបង្រៀនច្រើនម៉ោងដែរ គ្រូបង្រៀនឯកទេសមកហើយ ផ្ទេរចេញទៅវិញ ដោយមូលហេតុ សហព័ន្ធ ខ្វះអាគារសិក្សា ។*

P#3« *បញ្ហាប្រឈមសម្រាប់សាលារៀនរបស់ខ្ញុំគឺ៖ខ្វះគ្រូឯកទេស គ្រូមួយចំនួន បំពេញភារកិច្ចមិនបានល្អ សិស្សមួយចំនួន ឡើងមកពីថ្នាក់ក្រោម មិនសូវចេះ»។*

P#4 «*បញ្ហាប្រឈមសម្រាប់សាលារៀនរបស់ខ្ញុំគឺ៖បុគ្គលិកមួយចំនួន អសកម្មបំពេញការងារមិនបានល្អ ហើយតែងតែយកមូលហេតុផ្សេងៗដាក់មុខ ពិសេស ការបំពេញភារកិច្ចមិនស្មើដៃគ្នា»។*

P#5 «*បញ្ហាប្រឈមនៅក្នុងសាលារៀនខ្ញុំគឺ៖សាលារៀនរបស់ខ្ញុំ ខ្វះគ្រូបង្រៀនឯកទេស (គីមី ជីវៈ បំណិនជីវិត) និងខ្វះសៀវភៅសិក្សាគោល។*

ដើម្បីឆ្លើយតមទៅនឹងបញ្ហាប្រឈមខាងលើ ការសិក្សាស្រាវជ្រាវ សូមសំណូមពរមួយចំនួន៖ (១) ក្រសួងអប់រំ គួរតែផ្តល់គ្រូឯកទេសដល់សាលាណា ដែលមានតម្រូវការ (២) ក្រសួង អប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ ចុះអធិការកិច្ចតាមសាលារៀន (៣)ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន

និងកីឡា ការិយាល័យ អប់រំស្រុក អាជ្ញាធរដែនដី និងអង្គភាពពាក់ព័ន្ធ ចូលរួមសហការ គាំទ្រ ដល់ការគ្រប់គ្រងសាលារៀន ឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព ដើម្បីឆ្លើយតបទៅនឹង គោលនយោបាយអប់រំ និងតម្រូវការមូលដ្ឋាន។

### ៤.៤.២ បញ្ហាប្រឈមរបស់គ្រូបង្រៀន

តាមរយៈកម្រងសំណួរសម្ភាសន៍ និងការចុះសម្ភាសន៍ផ្ទាល់ជាមួយលោកគ្រូ អ្នកគ្រូ ចំនួន១០នាក់ បានបង្ហាញថា៖នៅតាមសាលាវិទ្យាល័យទាំង ៥ ដែលស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូង មានបញ្ហាប្រឈមមួយចំនួន។បញ្ហាប្រឈមដែលទទួលបានពីការធ្វើសម្ភាសន៍ផ្ទាល់ជាមួយគ្រូបង្រៀននៅតាមអង្គភាពគោលដៅ មានដូចខាងក្រោម៖

*T#1 «នៅក្នុងសាលារៀនខ្ញុំមានបញ្ហាមួយចំនួនដូចជា៖ខ្វះខាតសម្ភារៈជំនួយដល់ការបង្រៀន (ស្លាយ ......ជាដើម)»។ T#2«នៅក្នុងសាលារៀនខ្ញុំមានបញ្ហាប្រឈមខ្លះៗដែរ ដូចជាៈសិស្សមិនយកចិត្តទុកដាក់ទាំងរៀន និងស្រាវជ្រាវ នាយកបំ ពេញតួនាទី និងភារកិច្ចរបស់ខ្លួន មិនបានល្អ (ប្រចាំគ្នា អនុវត្តការងារមិនស្មើដែគ្នា និងមើលបំណាំគ្នា.....ជាដើម)»។ T#3 «សាលារៀនមានបញ្ហាប្រឈមខ្លាំងជាងគេគឺសិស្សខ្សោយ សិស្សគ្មានមូលដ្ឋានគ្រឹះ»។T#4 «សាលារៀនក៏មានបញ្ហាប្រឈមខ្លះៗដែរ ដូចជា៖ខ្វះអាគារសិក្សា ខ្វះកន្លែងស្នាក់នៅរបស់គ្រូបង្រៀនមកពីឆ្ងាយ»។T#5 «បញ្ហាប្រឈមសម្រាប់សាលាខ្ញុំគឺ ៖ ខ្វះបន្ទប់ពិសោធន៍ ខ្វះសម្ភារៈឧបទេសបង្រៀន និងរៀន និងសិស្សមួយចំនួនមិនយកចិត្តទុកដាក់លើការសិក្សាទេ»។T#6«សាលារៀនខ្ញុំមានបញ្ហាមួយចំនួនដែរ ចូចជាៈការខ្វះខាតគ្រូ ប្រើគ្រូបង្រៀនខុសឯកទេស នាយកបង្រៀនច្រើនម៉ោង គ្រូបង្រៀនកីឡា ទៅបង្រៀនផែនដីជាដើម»។ T#7«សាលារៀនរបស់ខ្ញុំមានបញ្ហាប្រឈមគឺការខ្វះសម្ភារៈឧបទេស និងសម្ភារៈពិសោពធន៍»។ T#8 «នៅសាលាខ្ញុំ មានបញ្ហាខ្លះដែរដូចជា សិស្សមួយចំនួនមិនយកចិត្តទុកដាក់ និងផ្តោតលើការសិក្សារបស់ពួកគេឡើយ»។T#9 «សាលារៀនរបស់ខ្ញុំ មានបញ្ហាប្រឈមជាច្រើនដូចជាៈ សិស្សមួយចំនួនគេចម៉ោងរៀន ម៉ោងចេញ ម៉ោងចូលមិនច្បាស់លាស់ បង្កឱ្យដំណើរបង្រៀននិងរៀន មិនសូវល្អទេ»។T#10«នៅក្នុងសាលារៀនខ្ញុំ មានបញ្ហាប្រឈមជាច្រើន ដូចជាៈសិស្សអវត្តមានច្រើន សិស្សគេម៉ោងរៀន និងម៉ោងរៀនមិនមានតម្លាភាព ហើយ*

*នាយក នាយករង មិនមានដំណោះស្រាយ និងគ្មានវិធានការច្បាស់លាស់ ដែលធ្វើឱ្យសកម្មភាព បង្រៀន និងរៀន មិនប្រក្រតី»។*

ដើម្បីឆ្លើយតមទៅនឹងបញ្ហាប្រឈមខាងលើ ការសិក្សាស្រាវជ្រាវ សូមសំណូមពរមួយចំនួនៈ (១)ក្រសួងអប់រំ គួរតែផ្តល់គ្រូឯកទេសដល់សាលាណា ដែលមានតម្រូវការ (២) ក្រសួង អប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ ចុះអធិការកិច្ចតាមសាលារៀន (៣)ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យ អប់រំស្រុក អាជ្ញាធរដែនដី និងអង្គភាពពាក់ព័ន្ធ ចូលរួមសហការ គាំទ្រ ដល់ការគ្រប់គ្រងសាលារៀន ឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព ដើម្បីឆ្លើយតបទៅនឹង គោលនយោបាយអប់រំ និងតម្រូវការមូលដ្ឋាន។(៤)ក្រសួងអប់រំ មន្ទីរ ការិយាល័យអប់រំស្រុក និងអង្គភាពពាក់ព័ន្ធគួរតែ ជ្រើរើសនាយកសាលាដែលមាន គុណវុឌ្ឍិ មានកម្រិតវប្បធម៌ខ្ពស់ មានចំណេះដឹកផ្នែកបច្ចេកវិទ្យាព័ត៌មាន និងភាសាលាបរទេស ពិសេសមាន ភាពទទួលខុសត្រូវខ្ពស់ក្នុងការដឹកនាំ និងគ្រប់គ្រង ហើយមានឆន្ទះមុសមុតក្នុងការអនុវត្តការងារ។

**តារាងទី៨ ៖បញ្ហាប្រឈមរបស់គ្រូ ចំពោះការអនុវត្តគណនេយ្យភាពរបស់នាយកសាលា**

| ល.រ | បរិយាយ | គ្រូបង្រៀន | | |
|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | តើលោកនាយក ក្នុងអង្គភាពលោកគ្រូ បានបំពេញ តួនាទី និងភារកិច្ចកម្រិតណាដែរ? | 4.30 | 0.82 | 10 |
| ២ | តើលោកគ្រូមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងដំណើរការបង្រៀន និងរៀននៅក្នុងអង្គភាពរបស់លោកគ្រូ? | 3.30 | 0.48 | 10 |
| ៣ | តើលោកគ្រូ មានសំណូមពរអ្វីខ្លះដល់ថ្នាក់ដឹកនាំ ក្រសួង មន្ទីរ ការិយាល័យអប់រំស្រុក និងអង្គភាពដែលពាក់ព័ន្ធ៕ | 3.60 | 0.52 | 10 |

| សរុប | 1.40 | 0.61 | 10 |
|---|---|---|---|

តាមតារាខាងលើបានបង្ហាញថា៖លោកគ្រូ អ្នកគ្រូ មួយចំនួន មានបញ្ហាប្រឈមខ្លះៗដែរ ទាក់ទងទៅនឹងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការដឹកនាំ គ្រប់គ្រង។សូចនាករដែលមាន មធ្យមភាគកម្រិតខ្ពស់ជាងគេគឺ «តើនាយកសាលា នៅក្នុងអង្គភាពបានបំពេញ តួនាទី និងភារកិច្ចកម្រិតណា?»ដែលមានមធ្យមភាគ (៤.៣០%=ល្អ)។សូចនាករដែលមានមធ្យមភាគទាបជាងគេគឺ៖«តើលោកគ្រូ អ្នកគ្រូ មានបញ្ហាប្រឈមអ្វីខ្លះក្នុងដំណើរបង្រៀន និងរៀន នៅក្នុងអង្គភាពរបស់លោកគ្រូ?»ដែលមានកម្រិតមធ្យមភាគពិន្ទុ(៣.៣០%=មធ្យម)មានន័យថា លោកគ្រូ អ្នកគ្រូ មិនសូវមានបញ្ហាប្រឈមខ្លាំងទេនៅក្នុងដំណើរការបង្រៀន និងរៀន។

## ៤.៥ គណនេយ្យភាពនាយកសាលា ទទួលបានពីកម្រងសំណួរសិស្ស

ដើម្បីសិក្សាស្រាវជ្រាវឱ្យកាន់តែច្បាស់ ពីគណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សា ទុតិយភូមិ ក្នុងស្រុមមេមត់ ខេត្តត្បូងឃ្មុំ អ្នកសិក្សាស្រាវជ្រាវ បានបង្កើតកម្រងសំណួរ១សម្រាប់សិស្ស ដែលមាសូចនាករចំនួន៥ ដើម្បីឆ្លើយតបទៅនឹង គណនេយ្យភាព លើដំណើរការបង្រៀនរបស់គ្រូ។ជាលទ្ធផលដែលប្រមូលបានតាមទិន្នន័យបានបង្ហាញថា៖នាយកសាលារបស់ពួកគេ បានបំពេញ តួនាទី និងភារកិច្ចបានល្អប្រសើរ ។សិស្សដែលបានផ្ដល់សម្ភាសន៍តាមរយៈកម្រងសំណួរសម្ភាសន៍មានចំនួន២៥០នាក់ ពីសាលាវិទ្យាល័យទាំង៥ នៅក្នុងស្រុកមេមត់។ ខាងក្រោមនេះគឺជាតារាងទិន្នន័យដែលប្រមូលបានពីសិស្សនៃវិទ្យាល័យទាំង៥៖

តារាងទី៩៖ ***គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ ទទួលបានតាមរយកម្រងសំណួរសិស្ស***

| ល.រ | **បរិយាយ** | **បាទ / ចាស** | **ទេ** | **មិនច្បាស់** |
|---|---|---|---|---|
| ១ | តើនាយកសាលារបស់ប្អូនៗ ធ្លាប់ចុះពិនិត្យតាមថ្នាក់រៀន | 96 | 4 | 0 |

| | | | | |
|---|---|---|---|---|
| | ក្នុងពេលដំណើរការបង្រៀន និងរៀន ដែរឬទេ ? | | | |
| ២ | តើលោកគ្រូ អ្នកគ្រូបានមករៀនប្អូនៗគ្រប់ម៉ោងដែរឬទេ ? | 94.8 | 5.2 | 0 |
| ៣ | តើលោកគ្រូ អ្នកគ្រូបន្ទុកថ្នាក់របស់ប្អូនៗ បានចេញលទ្ធផលប្រចាំខែ ឆមាស និងប្រចាំឆ្នាំដល់ប្អូបៗទាន់ពេលវេលាដែរឬទេ ? | 93.2 | 6.8 | 0 |
| ៤ | តើសាលារៀនប្អូនៗ សិស្សមានការគោរពវិន័យ និងគោរពលោកគ្រូ អ្នកគ្រូកម្រិតណាដែរ ? | 92.8 | 7.2 | 0 |
| ៥ | តើសាលារៀនប្អូនៗមាន សម្អាតបរិស្ថាន(ម៉ោងពលកម្ម) ដែរឬទេ ? | 98.8 | 1.2 | 0 |
| **សរុប** | | **95.12** | **4.88** | **0** |

តាមតារាងខាងលើបានបង្ហាញថា សិស្សបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត«គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ» ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៩៥.១២)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "តើសាលារៀនរបស់ប្អូនៗ មានម៉ោងសម្អាតបរិស្ថានដែរឬទេ?"ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៩៨.៨)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "តើសាលារៀនប្អូនៗ សិស្សមានការគោរពវិន័យ និងគោរពលោកគ្រូ អ្នកគ្រូ កម្រិតណាដែរ?" ក្នុងកម្រិត "ខ្សោយ" (មធ្យមភាគពិន្ទុ=៩២.៨)។

យោងតាមទិន្នន័យខាងលើ នាយកសាលាទាំង៥នៃវិទ្យាល័យខាងលើពិតជាបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អប្រសើរ។ប៉ុន្តែនាយកសាលាក៏មានភាពតានតឹង និងបញ្ហាប្រឈមមួយចំនួនដែលទាក់ទងនឹងការអនុវត្តគណនេយ្យភាពនៅតាមសាលារៀននីមួយៗ។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

គណនេយ្យភាពនាយកសាលា ពិតជាដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងដល់គុណភាពអប់រំនៅតាមគ្រឹស្ថានសិក្សាទាំងអស់ ពីព្រោះថាបើនាយកសាលាគ្មានគណនេយ្យភាព ក្នុងការដឹកនាំ និងគ្រប់គ្រងទេ សាលារៀននោះ ក៏មិនមានការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់ដែរ។នាយកសាលា គឺជាសមាសភាពដ៏សំខាន់ ក្នុងការជួយដល់ការកែលម្អសាលារៀន និងជាអ្នកជួយដល់ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងនូវគុណភាពអប់រំ និងជួយដល់ការកែទម្រង់វិស័យអប់រំ។សាលារៀនមួយ រីកចម្រើនទៅបាន វាអាស្រ័យទៅលើសាលារៀននោះ មាននាយកជាអ្នកដឹកនាំល្អ។នាយកមានតួនាទីសំខាន់ៗដូចជា៖១. ជាអាជ្ញាធរ ២. ជាមន្ត្រីរដ្ឋបាល ៣. ជាទីប្រឹក្សាគរុកោសល្យ ៤. ជាអធិការអចន្ត្រៃយ៍ ៥. ជាអ្នកចរចារ ៦.ជាអ្នកអប់រំ ៧.ជាអ្នកផ្តល់សេវាកម្ម ៨.ជាអ្នកពិគ្រោះយោបល់ និងទី៩.ជាភ្នាក់ងារអភិវឌ្ឍសហគមន៍(សុផាន់ណា,តារា,ច័ន្ទដារ៉ា,២០១៧)។លើសពីនេះទៀតនាយកសាលាមានភារកិច្ចជាច្រើនទៀតដូចជា៖១.ការងាររដ្ឋបាល ២.ការងារបច្ចេកទេសគរុកោសល្យ ៣.ការងារទំនាក់ទំនង។នាយកគឺជាបេះដូងសាលារៀន ដូចនេះនាយកត្រូវតែមានភាពទទួលខុសត្រូវខ្ពស់ចំពោះអង្គភាពក្នុងការដឹកនាំ និងគ្រប់គ្រងធ្វើយ៉ាងណាដើម្បីឱ្យសម្រេចបាននូវគោលដៅរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព។ដោយមើលឃើញពីចំណុចទាំងនេះហើយ ទើបអ្នកស្រាវជ្រាវសម្រេចជ្រើសរើសយកប្រធានបទមួយស្តីពី៖ **(គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ខេត្តត្បូងឃ្មុំ)** ក្នុងគោលបំណងធំៗពីរគឺ៖ ១) ដើម្បីសិក្សាស្រាវជ្រាវពីគណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ២) ដើម្បីសិក្សាស្រាវជ្រាវពីបញ្ហាប្រឈម និងដំណោះស្រាយពីគណនេយ្យភាពរបស់នាយកសាលា លើដំណើរការបង្រៀនរបស់គ្រូនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ទាក់ទងនឹងប្រធានបទខាងលើ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ តាមវិធីចម្រុះគឺ បរិមាណវិស័យ និងគុណវិស័យ។ចំពោះបរិមានវិស័យ អ្នកស្រាវជ្រាវបានទៅប្រមូលទិន្នន័យដោយផ្ទាល់នៅតាមសាលាគោល

ដៅទាំង ៥ ដែលស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ ហើយទទួលបានកម្រងសំណួរត្រឡប់មកវិញមានចំនួន ៣០៧ ក្នុងនោះ នាយកសាលា៥នាក់ គ្រូបង្រៀន៥២នាក់ និងសិស្សានុសិស្សចំនួន២៥០នាក់។ ចំពោះគុណវិស័យ អ្នកស្រាវជ្រាវបានទៅសម្ភាសន៍ផ្ទាល់នៅតាមសាលាគោលដៅទាំង៥ ហើយទទួលបានទិន្នន័យមកវិញចំនួន ១៥នាក់ ក្នុងនោះនាយកសាលា៥នាក់ និងគ្រូបង្រៀន ១០នាក់។ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់សូចនាករគោលក្នុងការរៀបចំកម្រងសំណួរក្នុងការប្រមូលទិន្នន័យ ដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ ពីគណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ និងបញ្ហាប្រឈមរបស់នាយកសាលា ក្នុងដឹកនាំ និងគ្រប់គ្រង លើដំណើរបង្រៀន និងរៀន។ក្នុងការបង្កើតកម្រងសំណួរ អ្នកសិក្សាស្រាវជ្រាវបានកំណត់គោលបំណង៤ផ្នែកធំៗគឺ៖១)ព័ត៌មានទូទៅ មានសូចនាករចំនួន ៨ ផ្នែកទី២ មាន៩សូចនាករ ផ្នែកទី៣ មាន១០សូចនាករ និងផ្នែកទី៤មាន៣សូចនាករ (កម្រងសំណួរសម្ភាសន៍)ទាក់ទងនិងបញ្ហាប្រឈមនានាក្នុងអនុវត្តនូវគណនេយ្យភាពរបស់នាយកសាលា លើដំណើរបង្រៀនរបស់គ្រូមានចំនួន៣ សម្រាប់សម្ភាសន៏ផ្ទាល់ជាមួយនាយកសាលា និងគ្រូបង្រៀនមួយចំនួន។

ជាលទ្ធផលបានបង្ហាញថា គណនេយ្យនាយលសាលា ពិតជាដើរតួយ៉ាងសំខាន់ លើដំណើការបង្រៀនរបស់គ្រូ ក្នុងការក្នុងការពង្រឹងដល់គុណភាពអប់រំ។ទន្ទឹមនឹងនេះដែរ នាយកសាលាក៏មានបញ្ហាប្រឈមជាច្រើនដែរក្នុងការអនុវត្តន៏នូវគណនេយ្យភាពរបស់ខ្លួននៅតាមអង្គភាព ដែលជាឱបាសគ្គរាំងស្ទះដល់ដំណើរការបង្រៀន និងរៀន។បញ្ហាប្រឈមទាំងនោះរួមមាន៖គ្រូបង្រៀនមួយចុះនួនមិនគោរពវិន័យដែលបង្កអោយមានការលំបាកដល់ដំណើរបង្រៀន និងរៀនមិនចូលរួមធ្វើការបរិស្ថាន និងបំពេញការងារមិនបានល្អដែលជាហេតុ បង្កអោយមានភាពអសកម្មខ្លះៗក្នុង ដំណើរបង្រៀន និងរៀន នៅអង្គភាពរបស់គាត់ខ្វះគ្រូបង្រៀន នាយកបង្រៀនច្រើនម៉ោងដែរ គ្រូបង្រៀនឯកទេសមកហើយ ផ្ទេចេញទៅវិញ ដោយមូលហេតុ សហព័ន្ធ ខ្វះអគ្គាសិក្សា ខ្វះគ្រូឯកទេស គ្រូមួយចំនួន បំពេញភារកិច្ចមិនបានល្អ សិស្សមួយចំនួនឡើងមកពីថ្នាក់ក្រោម មិនសូវចេះបុគ្គលិកមួយចំនួន អសកម្មបំពេញការងារមិនបានល្អ ហើយតែងតែយកមូលហេតុផ្សេងៗដាក់មុខ ពិសេស ការបំពេញភារកិច្ចមិនស្មើរដៃគ្នា ខ្វះគ្រូបង្រៀនឯកទេស(គីមី ជីវៈ បំណិនជីវិត) និងខ្វះសៀវភៅសិក្សាគោល។

សរុបមក នាយកសាលាទាំងមានភាពទទួលខ្ពស់ ក្នុងកាតដឹកនាំ និងគ្រប់គ្រង លើដំណើរការបង្រៀននិងរៀននៅតាមអង្គភាពរបស់ខ្លួនលទ្ធផលទាំងនេះ គឺទទួលបានតាមរយៈការវិភាគទិន្នន័យរវាងគ្រូបង្រៀន និងសិស្សានុសិស្សនៅតាមសាលាវិទ្យាល័យទាំង៥ដែលស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឆ្លងតាមការវិភាគទិន្នន័យបានបង្ហាញថា គណនេយ្យភាពនាយក លើដំណើរការបង្រៀនរបស់គ្រូ ពិតជាបានកំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងផែនការអភិវឌ្ឍសាលារៀន ការកែរលំអរសាលារៀន និងការធ្វើកំណែរទម្រង់វិស័យអប់រំ។សាលារៀនល្អ ត្រូវចាប់ផ្ដើមពីការរៀបចំផែនការអភិវឌ្ឍសាលារៀន។ផែនការអភិវឌ្ឍសាលារៀន ត្រូវរៀនចំឡើង ដោយមានការចូលរួមពី គណៈគ្រប់គ្រងសាលា ប្រធានគ្រុមបច្ចេកទេស សាស្ត្រាចារ្យ (គ្រូបង្រៀន) មាតាបិតា សហគមន៏ និងអាជ្ញាធរដែលពាក់ពន្ធ័។សកម្មភាពទាំងនេះគឺជាភាពទទួលខុសត្រូវរបស់លោកនាយកសាលា ក្នុងការដឹកនាំ និងគ្រប់គ្រងរបស់ខ្លួន។ដូច្នេះ នាយកសាលាល្អ គឺជានាយកដែលមាន គណនេយ្យភាព ស្វ័យភាព និងតម្លាភាព។

## ៥.២ សំណូមពរ

យោតាមលទ្ធផលដែលបានរកឃើញតាមរយៈការប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវសូមលើកឡើងនូវសំណូមពរមួយចំនួនដល់គាគីពាក់ព័ន្ធ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពអប់រំ នៅតាមអង្គភាពនានា តាមរយៈ គណនេយ្យភាពនាយកសាលា លើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឱ្យកាន់តែប្រសើរឡើង និងមានប្រសិទ្ធភាពខ្ពស់ ក្នុងការដឹកនាំ និងគ្រប់គ្រង។ភាគីដែលពាក់ព័ន្ធរួមមាន៖

### ក. ក្រសួងអប់រំ យុវជន និងកីឡា

- ក្រសួងអប់រំ យុវជន និងកីឡា គួរគាប់បីបើកវគ្គបំប៉នដល់ នាយក នាយិកាឱ្យបានញឹកញាប់ជាគុណវុឌ្ឍិសម្រាប់ជាប្រយោជន៍ដល់ការដឹកនាំ និងគ្រប់គ្រងដើម្បីឱ្យសម្រេចបាននូវសូចនាករផ្សេងៗ និងពង្រឹងដល់គុណភាពអប់រំ ពិសេស ដើម្បីពង្រឹងដល់ស្តង់ដារនាយកសាលាល្អ
- ចុះទៅជួយផ្ទាល់ដល់សាលារៀនឱ្យបានច្រើនក្នុងការអនុវត្តការគ្រប់គ្រងសាលារៀន ប្រកបដោយប្រសិទ្ធភាព និងគុណភាព

- ផ្តល់កញ្ចប់សមត្ថភាពដល់នាយកឬនាយិកាដែលមានគុណវុឌ្ឍិ ជ្រើសរើសនាយក នាយិកា ដែលមានកម្រិតវប្បធម៌ កម្រិតវិជ្ជាជីវៈនិងមានឆន្ទៈច្បាស់លាស់
- ជួយលើកទឹកចិត្តដល់ លោកគ្រូ អ្នកគ្រូ ឱ្យមានមនសិការវិជ្ជាជីវៈ និងមានឆន្ទៈក្នុងការបំពេញនូវ តួនាទី និងភារកិច្ចខ្លួននៅតាមអង្គភាព។
- គួររៀបចំជ្រើសរើសសាលាស្អាត នាយកសាលាល្អ គ្រូល្អ ដោយផ្តោតលើសាលាដែលមានគណនេយ្យភាព។

**ខ. មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ**

- គួរតែចុះធ្វើអធិការកិច្ចនៅតាមសាលារៀនក្នុងខេត្តរបស់ខ្លួន ឱ្យបានញឹកញាប់ ដើម្បីពិនិត្យតាមដាន នូវការអនុវត្តការងារដឹកនាំ និងគ្រប់គ្រប់ របស់នាយកសាលា ប្រកបដោយតម្លាភាព និងសុក្រឹតភាព។
- ជួយសាលារៀបចំកម្មវិធីផ្សព្វផ្សាយ កម្មវិធីគ្រប់គ្រងសាលារៀន ឱ្យបានទូលំទូលាយដល់ សហគមន៍ និងអាណាព្យាបាលសិស្ស និងសហការជួយជំរុញអាជ្ញាធរដែនដី ឱ្យចូលរួមគ្រប់ពេលសាលាមានត្រូវការ
- គួរតែអនុវត្តច្បាប់ឱ្យបានតឹងរឹងចំពោះ នាយក នាយិកា ណាដែលបានប្រព្រឹត្តខុស និងបុគ្គលិកដែលអសកម្មក្នុងការងារ។

**គ. ការិយាល័យអប់រំ យុវជន និងកីឡាស្រុកមេមត់**

- ជួយជំរុញ និងលើកទឹកចិត្ត ដល់នាយកសាលាគ្រប់រូប ក្នុងការអនុវត្តការងារ របស់ពួកគាត់ កុំចាំតែស្តីបន្ទោស និងដាក់ទណ្ឌកម្ម
- ការិយាល័យអប់រំស្រុក គួរតែពង្រឹងភាពស្និតស្នាលជាមួយនាយកសាលា ដើម្បីដឹងពីសុខទុក្ខ និងបញ្ហាប្រឈម របស់នាយកសាលា ក្នុងការដឹកនាំ និងគ្រប់គ្រងរបស់គាត់
- ការិយាល័យ គួរតែមានការប្រជុំប្រចាំខែ ជាមួយនាយក នាយិកា ទាំងអស់ ដើម្បីវាយតម្លៃចំពោះការអនុវត្តផែនការប្រចាំខែ របស់សាលានីមួយៗ

- ជួយសាលារៀន ក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន និងផែនការកែលម្អសាលា

**ឃ. នាយកសាលា**

- នាយកសាលាគ្រប់រូប គួរតែចុះធ្វើអធិការកិច្ចអចិន្ត្រៃយ៍តាមថ្នាក់រៀន ដើម្បីជួយដល់ដំណើរការបង្រៀន និងរៀន
- នាយកសាលា គួរតែមានឆន្ទៈ និងចក្ខុវិស័យ ក្នុងការដឹកនាំ និងគ្រប់គ្រង ដើម្បីពង្រឹងដល់ការអនុវត្តផែនការអភិវឌ្ឍសាលារឱន
- នាយកសាលាទាំង គួរតែពង្រឹងនូវគុណវុឌ្ឍិខ្លួនជាប្រចាំ
- នាយកសាលា គួរតែមាន គណនេយ្យភាព តម្លាភាព និងស្វ័យភាព ក្នុងការដឹកនាំ និងគ្រប់គ្រង

## ៥.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ក្នុងសិក្សាស្រាវជ្រាវនេះ ផ្តោតលើ គណនេយ្យភាពនាយកសាលា លើដំណើរបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកមេមត់ខេត្តត្បូងឃ្មុំ ហើយធ្វើឡើងចំពោះតែសាលាវិទ្យាល័យចំនួន ៥ គឺៈវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនជារ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្រែតានងកើត វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនលាចលើ និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ តែប៉ុណ្ណោះ។សម្រាប់ការសិក្សាបន្ត អ្នកសិក្សាស្រាវជ្រាវដទៃទៀត អាចធ្វើការពិចារណាដូចតទៅៈ

សម្រាប់ប្រធានបទខាងលើនេះ អ្នកសិក្សាក្រោយៗ គួរតែពង្រីកនូវវិសាលាភាពនៃការសិក្សាស្រាវជ្រាវ ដោយកំណត់យក សាលាវិទ្យាល័យទាំងអស់នៅក្នុងខេត្តត្បូងឃ្មុំ។

# ឯកសារយោង

# ឯកសារយោង


កំណែទម្រង់សាលារៀន នៅកម្ពុជា ឆ្នាំ ២០២០ (បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន)

យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ ( ២០១៨-២០២៣)ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ដារសាលាមធ្យមសិក្សា( ២០១៨)

ក្រសួង អប់រំ យុវជន និងកីឡា(២០១៨) សៀវភៅប្រតិបត្តិស្តីពី ការគ្រប់គ្រងតាមសាលារៀន គម្រោងកែលម្អអប់រំ នៅមធ្យមសិក្សាឆ្នាំ២០១៨

សៀវភៅ «គ្រប់គ្រងបុគ្គលិកនៅតាមសាលារៀន» (នាយកដ្ឋានបុគ្គលិក ឆ្នាំ២០២២)

សៀវភៅ«គណនេយ្យភាពរបស់សាលារៀន»( ណូ ហ្វាតា ,ហេង គ្រេង ,មហាវិទ្យាល័យអប់រំ នៃសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ)

និក្ខេបបទនិស្សិតឯកទេសៈគ្រប់គ្រងអប់រំ ជំនាន់ទី៧ ប្រធានបទៈ«ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀន ផ្អែកលើលទ្ធផលនៅមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញ»

កំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្រ្តបង្រៀន(ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្រ្តី ហង់ ជួន ណារ៉ុន, ២០ មករា២០២០)

ក្រសួងអប់រំ យុវជន និងកីឡាៈកំណែទម្រង់ ការគ្រប់គ្រងអប់រំ ដើម្បីអភិវឌ្ឍធនធានមនុស្ស នៅកម្ពុជាសម្រាប់សតវត្សទី២១ (ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន,២៥មីនា ២០១៩)

ក្រសួង អប់រំ យុវជន និងកីឡា ៖«បរិវត្តកម្មឌីជីថលនៃការអប់រំ បំណិនសតវត្សទី២១ និងកំណែទម្រង់វិធីសាស្រ្តបង្រៀន,២០២១,ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្រ្តី ហង់ ជួនណារ៉ុន)

ផែនទីបង្ហាញផ្លូវរបស់ក្រសួងអប់រំនៅកម្ពុជាឆ្នាំ២០៣០

ការគ្រប់គ្រងរដ្ឋបាល សម្រាប់បំប៉ននាយកសាលារៀនបឋមសិក្សា និងមធ្យមសិក្សា( នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការឆ្នាំ២០០៩

របាយការណ៍ស្រាវជ្រាវស្តីពីៈ ប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលានៅមធ្យមសិក្សា( កង សុផាន់ណា, ប៉ែន តារា ,និង អ៊ី ច័ន្ទណារ៉ា,ខែធ្នូ ឆ្នាំ ២០១៧

*TomMaxwel : Accountability and principal: focus on improvement, July 2000.J.C.A Role and Duties of principal and vice-principal (Approved April2,1991,revised October18,1994)*

*Dyhou,I,1999.School Based-management: Fundamentals of educational planning, Paris: UNESCO :International Institute of Education Planning*

*Cheng,Y.C (1996).School effectiveness and school based- management: Dimension to Development. British: Routledge, Jan 11, 2013-Education-210pages*

*http:www.educationworld.com,Education world. what great principals do differently (2nd Edition )by Todd whitaker.*

*http:www.beautifulplainssed.ca.jcc-role and duties: Role and of principal and vice-principal(April2,1991,October 18,1994)*

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់នាយកសាលា

ខ្ញុំបាទ ឈ្មោះ ផាន់ ម៉ៅ ជានិសិត្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៃវិទ្យាស្ថានជាតិអប់រំ បាននឹងកំពុងធ្វើការសិក្សាស្រាវជ្រាវ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាក្រោមប្រធានបទ៖ (**គណនេយ្យភាពនាយកសាលាលើដំណើរការបង្រៀនរបស់គ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ**)។លោកគ្រូដឹកនាំបង្គោល បណ្ឌិត **សោន វណ្ណៈ** និងគ្រូដឹកនាំរង បណ្ឌិត **មឿន លិនណា**។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញ និងឆ្លើយកម្រងសំណួររបស់ខ្ញុំបាទ។ខ្ញុំបាទសូមធានាថា កម្រងសំណួរនេះនឹងត្រូវបានរក្សាការសម្ងាត់ ហើយព័ត៌មានដែលទទួលបាន សម្រាបយកមកប្រើសម្រាប់គូសសញ្ញា ( ) ឬឆ្លើយកម្រងសំណួរខាងក្រោម៖

- ការធ្វើគារវកិច្ច និងការជជែកគ្នាលេងមិននឹងចាប់ផ្ដើមកិច្ចសម្ភាសន៍
- ការណែនាំអំពីគោលបំណងនៃការស្រាវជ្រាវ (១)ស្វែងយល់ពី គណនេយ្យភាពនាយកសាលា (ការដឹកនាំ គ្រប់គ្រង តួនាទី ភារកិច្ច និងទំនួលខុសត្រូវរបស់នាយកសាលា)លើដំណើរបង្រៀនរបស់គ្រូ (២) អត្ថប្រយោជន៍ និងសារសំខាន់នៃការបំពេញតួនាទីបានគ្រប់ជ្រុងជ្រោយរបស់នាយកសាលាឈានទៅដល់ការលើកកម្ពស់គុណភាពអប់រំនៅកម្រិតមធ្យមទុតិយភូមិ។

គណនេយ្យភាពនាយកសាលា ពង្រឹងគុណភាពអប់រំ។

## ក.កម្រងសំណួរបិទ

### ផ្នែក ទី១ ៖ ព័ត៌មានទូទៅរបស់នាយកសាលា

ការណែនាំ៖សូមលោក លោកស្រី ឆ្លើយសំណួរ និងគូសសញ្ញា( ) ក្នុងប្រអប់នីមួយៗ ខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម៖

**១. ភេទ** ☐ ស្រី ☐ ប្រុស

**២. អាយុ** ☐ ក្រោម៤០ឆ្នាំ ☐ ៤០-៤៩ឆ្នាំ ☐ ៥០-៥៩ឆ្នាំ ☐ លើសពី៦០ឆ្នាំ

**៣. កម្រិតវប្បធម៌**

☐ កម្រិតបឋមសិក្សា ☐ កម្រិតអនុវិទ្យាល័យ ☐ កម្រិតវិទ្យាល័យ

☐ កម្រិតបរិញ្ញាប័ត្រ ☐ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ☐ កម្រិតបណ្ឌិត

**៤. កម្រិតវិជ្ជាជីវៈ**

☐ គ្រូមត្តេយ្យសិក្សា ☐ គ្រូបឋមសិក្សា

☐ គ្រូកម្រិតមូលដ្ឋាន ☐ គ្រូកម្រិតឧត្តម

**៥. បទពិសោធការងារ**

☐ ក្រោម៥ឆ្នាំ ☐ ៦ - ១០ ឆ្នាំ ☐ ១១ - ១៥ ឆ្នាំ ☐ ១៦ - ២០ ឆ្នាំ

☐ ២០ - ២៥ ឆ្នាំ ☐ ចាប់ពី២៦ឆ្នាំឡើងទៅ

**៦. តើលោក/លោកស្រី បម្រើការងារនៅក្នុងអង្គភាពនេះប៉ុន្មានឆ្នាំហើយ?**

☐ ក្រោម៥ឆ្នាំ ☐ ៦ - ១០ ឆ្នាំ ☐ ១១ - ១៥ ឆ្នាំ ☐ ១៦ - ២០ ឆ្នាំ

☐ ២០ - ២៥ ឆ្នាំ ☐ ចាប់ពី២៦ឆ្នាំឡើងទៅ

### ផ្នែក ២៖ គណនេយ្យភាពនាយសាលា លើដំណើរការបង្រៀនរបស់គ្រូ

៧. ក្នុងរយៈពេលបីឆ្នាំចុងក្រោយជាមធ្យមតើសាលារបស់អ្នកមានអត្រាបោះបង់ការសិក្សាប៉ុន្មានភាគរយ

..................%

៨. ក្នុងរយៈពេលបីឆ្នាំចុងក្រោយជាមធ្យមតើសាលារបស់អ្នកមានអត្រាត្រួតថ្នាក់ប៉ុន្មានភាគរយ?.................%

៩. ក្នុងរយៈពេលបីឆ្នាំចុងក្រោយជាមធ្យមតើសាលារបស់អ្នកមានអត្រាឡើងថ្នាក់ប៉ុន្មានភាគរយ?.................%

១០. ស្ថិតិសិស្ស គ្រូក្នុងឆ្នាំសិក្សា ២០២១ -២០២២...........................................................

**ការណែនាំ៖** សូមអានឃ្លាខាងក្រោមឱ្យបានច្បាស់លាស់ ជ្រើសរើសកម្រិតសូចនាករ ដែលឆ្លុះបញ្ចាំងពីផលជះនៃបរិវត្ត កម្មការអប់រំឌីជីថល លើការបំពេញការងាររបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ដែលលោកគ្រូ អ្នកគ្រូយល់ឃើញទៅតាមកម្រិតចង្អុលបង្ហាញ រួចគូសសញ្ញា (✓) ក្នុងប្រអប់នីមួយៗ។ សូមធ្វើការគូសយកកម្រិតណាមួយដែលទាក់ទងនឹងស្ថានភាពបច្ចុប្បន្ន នៃផលជះនៃបរិវត្តកម្មការអប់រំឌីជីថល លើការបំពេញការងាររបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តព្រៃវែង។

សូមចូលរួមផ្តល់ការគាំទ្រក្នុងការបំពេញចម្លើយ នូវរាល់គ្រប់សំណួរខាងក្រោម ស្របតាមការយល់ឃើញរបស់លោកគ្រូ អ្នកគ្រូ។

**កម្រិតចង្អុលបង្ហាញ៖**

១. មិនយល់ស្របខ្លាំង (Strongly disagree)

២. មិនយល់ស្រប (Disagree)

៣. យល់ស្របខ្លះ (Neutral)

៤. យល់ស្រប (Agree)

៥. យល់ស្របខ្លាំង (Strongly agree)

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | តើលោកនាយក នាយិកា បានការរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសាលាកម្រិតណាដែរ? | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | តើលោកនាយក នាយិកា បានចុះអធិការកិច្ចអចិន្ត្រៃយ៍តាមថ្នាក់រៀនជាប្រចាំ ដែរឬទេកន្លងមក? | | | | | |
| ៣ | តើលោកនាយក នាយិកា បានបំប៉នវិធីសាស្ត្របង្រៀន និងផ្តល់ប្រឹក្សាបច្ចេកទេសដល់បគ្គលិកកម្រិតណាដែរ? | | | | | |
| ៤ | តើលោកគ្រូ អ្នកគ្រូ របស់លោកនាយក នាយិកា បានធ្វើកិច្ចតែងការបង្រៀន ដែរឬទេ មុននឹងដំណើរការបង្រៀន? | | | | | |
| ៥ | តើលោកគ្រូ អ្នកគ្រូរបស់លោកនាយក នាយិកា បានធ្វើរដ្ឋបាលថ្នាក់រៀន មុនដំណើរការបង្រៀន កម្រិតណាដែរ? | | | | | |
| ៦ | តើលោកនាយក នាយិកា បានបែងចែកសេវាម៉ោងបង្រៀនទៅតាមសមត្ថភាព និងឯកទេសបានត្រឹមត្រូវ ដែរឬទេ? | | | | | |
| ៧ | តើលោកនាយក នាយិកា បានត្រួតពិនិត្យ និងវាយតម្លៃការបង្រៀន និងរៀនជាប្រចាំដែរឬទេ? | | | | | |
| ៨ | តើសាលារៀន របស់លោកនាយក នាយិកា មានការចូលរួមគាំទ្រពីសហគមន៍ ឬសាធារណៈជនកម្រិតណាដែរ? | | | | | |
| ៩ | តើសាលារៀនរបស់ លោកនាយក នាយិកា បានទទួលចំណាត់ថ្នាក់សាលារៀនល្អ ឬទទួលប័ណ្ណសរសើរពីថ្នាក់ដឹកនាំដែរឬទេ? បើទទួលមានកម្រិតណា? | | | | | |

## ផ្នែក៣៖ ទស្សនរបស់លោកគ្រូចំពោះនាយកយ ក្នុងការដឹកនាំ និងគ្រប់គ្រង

**ការណែនាំ៖** សូមអានឃ្លាខាងក្រោមឱ្យបានច្បាស់លាស់ ជ្រើសរើសកម្រិតសូចនាករ ដែលឆ្លុះបញ្ចាំងពីផលជះនៃបរិវត្ត កម្មការអប់រំឌីជីថល លើការបំពេញការងាររបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ដែលលោកគ្រូ អ្នកគ្រូយល់ឃើញទៅតាមកម្រិតចង្អុលបង្ហាញ រួចគូសសញ្ញា (✓) ក្នុងប្រអប់នី

មួយៗ។ សូមធ្វើការគូសយកកម្រិតណាមួយដែលទាក់ទងនឹងស្ថានភាពបច្ចុប្បន្ន នៃផលជះនៃបរិវត្តកម្ម ការអប់រំឌីជីថល លើការបំពេញការងាររបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តព្រៃវែង។

សូមចូលរួមផ្តល់ការគាំទ្រក្នុងការបំពេញចម្លើយ នូវរាល់គ្រប់សំណួរខាងក្រោម ស្របតាមការយល់ឃើញរបស់លោកគ្រូ អ្នកគ្រូ។

**កម្រិតចង្អុលបង្ហាញ៖**

១. មិនយល់ស្របខ្លាំង (Strongly disagree)

២. មិនយល់ស្រប (Disagree)

៣. យល់ស្របខ្លះ (Neutral)

៤. យល់ស្រប (Agree)

៥. យល់ស្របខ្លាំង (Strongly agree)

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | តើភាពទទួលខុសត្រូវរបស់ នាយក នាយិកា ក្នុងការដឹកនាំ និងគ្រប់គ្រង បានដើរតួយ៉ាងសំខាន់ លើដំណើរការបង្រៀន និងរៀនដែរឬទេ? | | | | | |
| ២ | តើលោកនាយក នាយិកា មានវិធីសាស្ត្រយ៉ាងណា ចំពោះដំណើរការបង្រៀនរបស់គ្រូ ដើម្បីឱ្យមានប្រសិទ្ធភាព ? | | | | | |
| ៣ | តើលោកនាយក នាយិកា មានវិធីសាស្ត្រ កម្រិតណាដែរ ក្នុងការជំរុញ និងលើកទឹកចិត្ត ដល់លោកគ្រូ អ្នកគ្រូ ដើម្បីឱ្យពួកគាត់គោរពពេលវេលា និងស្រឡាញ់វិជ្ជាជីវៈរបស់ខ្លួន? | | | | | |
| ៤ | តើលោកនាយក នាយិកា មានការលើកទឹកចិត្តដល់បុគ្គលិកដែលសកម្មកម្រិតណាដែរ? | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | តើលោកនាយក នាយិកា បានធ្វើផែនការអភិវឌ្ឍសាលារៀន កម្រិតណាដែរ ? | | | | | |
| ៦ | តើលោកនាយក នាយិកា យល់ឃើញយ៉ាងណាដែរចំពោះ សកម្មភាពសិក្សាបែបសិស្សមជ្ឈមណ្ឌល ? | | | | | |
| ៧ | តើ គណនេយ្យភាព ស្វ័យភាព និងតម្លាភាពមានសារៈសំខាន់ ក្នុងការដឹកនាំគ្រប់គ្រងសាលារៀន របស់លោកនាយក នាយិកា កម្រិតណាដែរ ? | | | | | |
| ៨ | តើលោកនាយក នាយិកា បានធ្វើការវាតតម្លៃក្នុងការបំពេញ ការងាររបស់លោកគ្រូ ជាប្រចាំកម្រិតណាដែរ ? | | | | | |
| ៩ | តើលោកនាយក នាយិកា បានជួបបញ្ហាប្រឈមកម្រិតណាដែរ ក្នុងការដឹកនាំ និងគ្រប់គ្រង ? | | | | | |
| ១០ | តើការដឹកនាំ និងគ្រប់គ្រង លើដំណើរការបង្រៀន និងរៀនបាន ល្អ ផ្តល់សារៈសំខាន់កម្រិតណារដែរដល់អង្គភាពរបស់លោក នាយក នាយិកា ? | | | | | |

## ខ.កម្រងសំណួរសម្ភាសន៍សម្រាប់នាយក

១.តើគ្រូបង្រៀន នៅក្នុងអង្គភាពលោកនាយក បំពេញ តួនាទី និងភារកិច្ចបានកម្រិតណាដែរ ?

.............................................................................................................................

.............................................................................................................................

.............................................................................................................................

២.តើលោកនាយក មានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការដឹកនាំ និងគ្រប់គ្រង អង្គភាពរបស់លោកនាយក ?

.............................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

៣.តើលោកនាយកមានសំណូមពរអ្វីខ្លះដល់ថ្នាក់ដឹកនាំ ក្រសួងអប់រំ មន្ទីរ ការិយាល័យអប់រំស្រុក និងអង្គភាពដែលពាក់ព័ន្ធ ?

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

ខ្ញុំបាទសូមថ្លែងអំណរគុណសារជាថ្មីដល់លោកនាយក នាយិកា ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីបំពេញកម្រងសំណួរ និងសម្ភាសន៍របស់ខ្ញុំបាទ។សូមគោរពជូនពរលោកនាយក នាយិកា ឱ្យជួបប្រទះតែ ពុទ្ធមង្គលពរទាំង ៤ប្រការគឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់គ្រូបង្រៀន

